គជអប NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
(គ.ជ.អ.ប.)

# សេចក្តីណែនាំសម្រាប់ការសាងល្បងអនុវត្ត

## គោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម និង
## គោលនយោបាយសមភាពយេនឌ័រ
## សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
## ក្នុងគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ឆ្នាំ២០២២

# អារម្ភកថា

លេខាធិការដ្ឋាន គ.ជ.អ.ប. មានតួនាទី និងការទទួលខុសត្រូវសំខាន់ក្នុងការជួយ គ.ជ.អ.ប. ដឹកនាំ និងសម្របសម្រួលការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការរៀបចំតាក់តែង និងការអនុវត្តកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយបានយកចិត្តទុកដាក់ក្នុងការបញ្ជ្រាប និងសមាហរណកម្មយ៉ាងពេញលេញនូវសមភាពយេនឌ័រ និងការលើកកម្ពស់សុវត្ថិភាពបរិស្ថាន និងសង្គមនៅក្នុងសកម្មភាពនានានៃកម្មវិធី។

នៅក្នុងឆ្នាំ២០១៩ លេខាធិការដ្ឋាន គ.ជ.អ.ប. បានទទួលស្គាល់ដោយមូលនិធិអាកាសធាតុបៃតង (GCF) ជាស្ថាប័នជាតិដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលបានថវិកាដោយផ្ទាល់ពី GCF សម្រាប់ការលើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះ រាល់គម្រោង និងកម្មវិធី នានាដែលស្ថិតក្រោមការគ្រប់គ្រង និងសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងទទួលបានការគាំទ្រមូលនិធិដោយ GCF ត្រូវអនុលោមតាមគោលនយោបាយ សៀវភៅណែនាំ និងសេចក្តីណែនាំនានាដែលបានរៀបចំ និងដាក់ឱ្យអនុវត្តដោយ គ.ជ.អ.ប. និងស្របតាមល័ក្ខខ័ណ្ឌនានានៃ GCF។

សេចក្តីណែនាំសម្រាប់ការអនុវត្តសាកល្បងគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម និងគោលនយោបាយសមភាពយេនឌ័រក្នុងគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងក្រោមជំនួយបច្ចេកទេសពីអង្គការ UNCDF ដើម្បីធ្វើការសាកល្បង និងដកស្រង់បទពិសោធន៍អំពីការអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម និងគោលនយោបាយសមភាពយេនឌ័រក្នុងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងតំបន់គោលដៅមួយចំនួនក្នុង គោលបំណងលើកកម្ពស់ និងពង្រីកការអនុវត្តគោលនយោបាយនេះនៅទូទាំងប្រទេស។

អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. សូមជំរុញ និងលើកទឹកចិត្តភាគីពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការចូលរួម សហការ និងអនុវត្ត ព្រមទាំងសូមស្វាគមន៍រាល់មតិយោបល់កែលម្អ ធាតុចូល និងអនុសាសន៍នានា ដើម្បីធានាឱ្យការសាកល្បងក្នុងការអនុវត្តគោលនយោបាយទាំងពីរនេះទទួលបានជោគជ័យជាផ្លែផ្កា និងសម្រេចបាននូវគោលបំណងតាមការគ្រោងទុក។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

លេខាធិការដ្ឋាន

ទីន់ ចិរីន

# បញ្ជីវាក្យសព្ទ

| វាក្យសព្ទ | អត្ថន័យ |
|---|---|
| CSF | មូលនិធិឃុំ សង្កាត់ |
| DMF | មូលនិធិក្រុង ស្រុក |
| ESIA | ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម |
| ESMP | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESS | សុវត្ថិភាពបរិស្ថាន និងសង្គម |
| FPIC | ដោយសេរី ជាមុន និងការសម្រេចចិត្តផ្អែកលើព័ត៌មាន |
| IPM (អាភីអឹម) | វិធានការចម្រុះគ្រប់គ្រងដំណាំ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoE | ក្រសួងបរិស្ថាន |
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MCFA | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| NCDD (គ.ជ.អ.ប.) | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCDD-S | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| PBCRG | មូលនិធិធន់នឹងអាកាសធាតុផ្អែកលើលទ្ធផលការងារ |
| PIM (ភីម) | ភីម ៖ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង |
| PMC | គណៈកម្មការគ្រប់គ្រងគម្រោង |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SNIF | មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |
| WCCC (គ.ក.ស.ក.) | គណៈកម្មការពិគ្រោះយោបល់ស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| CCWC (គ.ក.ន.ក.) | គណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ |
| NP-2 (កជទី២) | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ |
| GCF | មូលនិធិអាកាសធាតុបៃតង |

# មាតិកា


អារម្ភកថា............i

បញ្ជីពាក្យសព្ទ............ii

១. សេចក្តីផ្តើម............១

២. ការអនុវត្តគោលនយោបាយបរិស្ថាន និងសង្គមដោយថ្នាក់ក្រោមជាតិ............១

២.១. ទិដ្ឋភាពទូទៅនៃគោលនយោបាយបរិស្ថាន និងសង្គម............១

២.២. យុទ្ធសាស្ត្រទី១ ៖ ការវិភាគ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងហានិភ័យសង្គម............៣

២.៣. យុទ្ធសាស្ត្រទី២ ៖ ពលកម្ម និងលក្ខខណ្ឌការងារ............៦

២.៤. យុទ្ធសាស្ត្រទី៣ ៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន............៧

២.៥. យុទ្ធសាស្ត្រទី៤ ៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍............១០

២.៦. យុទ្ធសាស្ត្រទី៥ ៖ លទ្ធកម្មដីធ្លី និងតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត............១២

២.៧. យុទ្ធសាស្ត្រទី៦ ៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព............១៣

២.៨. យុទ្ធសាស្ត្រទី៧ ៖ ជនជាតិដើមភាគតិច............១៥

២.៩. យុទ្ធសាស្ត្រទី៨ ៖ បេតិកភណ្ឌវប្បធម៌............១៧

៣. ការអនុវត្តគោលនយោបាយយេនឌ័រដោយរដ្ឋបាលថ្នាក់ក្រោមជាតិ............១៨

៣.១. តម្រូវការនានានៃគោលនយោបាយយេនឌ័រ............១៨

៣.២. គម្រោងវិជ្ជមានយេនឌ័រ............១៩

៣.៣. ការពិនិត្យពិច័យយេនឌ័រ............២០

៤. សុវត្ថិភាពបរិស្ថាន និងយេនឌ័រក្នុងកិច្ចដំណើរការអនុវត្តគម្រោង............២១

៤.១. ទិដ្ឋភាពទូទៅ............២១

៤.២. ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង............២២

៤.៣. ការពិនិត្យពិច័យសុវត្ថិភាពបរិស្ថាន និងសង្គម............២២

៤.៤. ការពិនិត្យពិច័យយេនឌ័រ............២៦

៤.៥. ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ........ ២៩

៤.៦. ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ........ ៤០

៤.៧. ការសិក្សាជីធ្លី ........ ៤៤

៤.៨. របាយការណ៍ស្តីពីសិទ្ធិជនជាតិដើមភាគតិច ........ ៤៤

៤.៩. ទម្រង់ព័ត៌មានគម្រោង ........ ៤៥

៤.១០. ការអនុវត្ត ESMP របាយការណ៍សិក្សាជីធ្លី និងរបាយការណ៍ជនជាតិដើមភាគតិច ........ ៤៥

៥. តួនាទីលេខាធិការដ្ឋាន ក.ជ.អ.ប. ........ ៤៧

៥.១. ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន ក.ជ.អ.ប. ........ ៤៧

៥.២. ក្រុមការងារយេនឌ័រនៃលេខាធិការដ្ឋាន ក.ជ.អ.ប. ........ ៤៨

៦. ការត្រួតពិនិត្យ និងការវាយតម្លៃ ESMP ........ ៤៩

៧. ការសម្រុះសម្រួលដោះស្រាយបណ្តឹង ........ ៥០

៧.១. គោលការណ៍ ........ ៥០

៧.២. ការសម្រុះសម្រួលដោះស្រាយបណ្តឹងដោយការិយាល័យប្រជាពលរដ្ឋ ........ ៥០

៧.៣. ការសម្រុះសម្រួលដោះស្រាយបណ្តឹងដោយលេខាធិការដ្ឋាន ក.ជ.អ.ប. ........ ៥១

ឧបសម្ព័ន្ធ ៖ ទម្រង់សុវត្ថិភាពបរិស្ថាននិងសង្គម និងយេនឌ័រ ........ ៥៣

# ១. សេចក្តីផ្តើម

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) បានអនុម័តឯកសារគោលនយោបាយដែលមានសារសំខាន់ចំនួន២ក្នុងឆ្នាំ២០១៩ ៖

- គោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- គោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ហៅកាត់ត្រឹម គោលនយោបាយយេនឌ័រ)។

ជាមួយគ្នានេះដែរលេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានរៀបចំ និងដាក់ឱ្យអនុវត្តនូវឯកសារណែនាំនានាសម្រាប់ការអនុវត្តគោលនយោបាយខាងលើ ៖

- ឯកសារណែនាំស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម
- ផែនការសកម្មភាពយេនឌ័រ

គោលនយោបាយទាំង២ខាងលើ ត្រូវអនុវត្តនៅក្នុងសកម្មភាពនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងកម្មវិធីជាតិដំណាក់កាលទី២ (កជទី២) នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់រួមបញ្ចូលទាំងការអនុវត្តគម្រោង កម្មវិធីនានាដែលគាំទ្រមូលនិធិដោយមូលនិធិក្រុង ស្រុក(DMF) និងមូលនិធិឃុំ សង្កាត់ (CSF)។

ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប. បានក្លាយជាស្ថាប័នអនុវត្តនៃមូលនិធិអាកាសធាតុបៃតង(GCF)។ ដោយមានកិច្ចសហការជាមួយកម្មវិធី LoCAL ដែលគាំទ្រដោយអង្គការ UNCDF លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងកៀរគរធនធានពីមូលនិធិអាកាសធាតុបៃតង(GCF) ដើម្បីគាំទ្រការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ(SNA) តាមរយៈមូលនិធិធន់នឹងការប្រែប្រួលអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្ត(PBCRG)។ ការអនុវត្តគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គម និងគោលនយោបាយយេនឌ័រ គឺជាលក្ខខណ្ឌសម្រាប់ការប្រើប្រាស់មូលនិធិ GCF ។

ឯកសារណែនាំនេះរៀបរាប់អំពីនីតិវិធីនានាសម្រាប់ការអនុវត្តនូវគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គម និងគោលនយោបាយយេនឌ័រនៅក្នុងការអនុវត្តគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងគាំទ្រការអនុវត្តសាកល្បងអំពីនីតិវិធីនេះក្នុងឆ្នាំ២០២២។ ផ្អែកលើលទ្ធផលនៃការសាកល្បងនេះ នីតិវិធីនៃឯកសារណែនាំនេះត្រូវធ្វើការពិនិត្យ និងសមាហរណកម្មទៅក្នុងសៀវភៅណែនាំនានាស្តីពីការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលគាំទ្រដោយ DMF និង CSF។

# ២. ការអនុវត្តគោលនយោបាយបរិស្ថាន និងសង្គមដោយថ្នាក់ក្រោមជាតិ

## ២.១. ទិដ្ឋភាពទូទៅនៃគោលនយោបាយបរិស្ថាន និងសង្គម

គោលដៅរបស់គោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម (ESS) គឺជានានិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី ធនធានធម្មជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ជនជាតិដើមភាគតិច សមភាពយេនឌ័រ

សុខភាព សុវត្ថិភាព និងសុខុមាលភាពសង្គមនៅថ្នាក់ក្រោមជាតិ។ ចំណុចដៅនៃគោលនយោបាយនេះ គឺចៀសវាងផលប៉ះពាល់មិនល្អលើបរិស្ថាន និងសង្គម ដែលអាចចកើតចេញពីគម្រោងអភិវឌ្ឍនានានៅថ្នាក់ក្រោមជាតិ។ គោលនយោបាយនេះ មានវិសាលភាពគ្របដណ្តប់គម្រោងនានាដែលអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ព្រមទាំងគម្រោងផ្សេងទៀតដែលស្ថិតក្រោមក្របខ័ណ្ឌនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

គោលនយោបាយ ESS ត្រូវអនុវត្តតាមរយៈយុទ្ធសាស្ត្រចំនួន៨ គឺ៖

**យុទ្ធសាស្ត្រទី១៖** ការវិភាគ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានបរិស្ថាន និងហានិភ័យសង្គម
**យុទ្ធសាស្ត្រទី២៖** ពលកម្ម និងលក្ខខណ្ឌការងារ
**យុទ្ធសាស្ត្រទី៣៖** ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន
**យុទ្ធសាស្ត្រទី៤៖** សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍
**យុទ្ធសាស្ត្រទី៥៖** លទ្ធកម្មដីធ្លី និងការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្ត
**យុទ្ធសាស្ត្រទី៦៖** ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព
**យុទ្ធសាស្ត្រទី៧៖** ជនជាតិដើមភាគតិច
**យុទ្ធសាស្ត្រទី៨៖** បេតិកភណ្ឌវប្បធម៌

យុទ្ធសាស្ត្រទាំងនេះ និងវិធីសាស្ត្រសម្រាប់ការអនុវត្តនៅក្នុងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិមានរៀបរាប់នៅក្នុងផ្នែកមួយចំនួននៃសេចក្តីណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងមូលនិធិក្រុង ស្រុក ខណ្ឌដូចខាងក្រោម ៖

- សេចក្តីណែនាំស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន
- សេចក្តីណែនាំស្តីពីការសិក្សាដីធ្លី ការបរិច្ចាគដីដោយស្ម័គ្រចិត្ត លទ្ធកម្មដីធ្លី និងសំណងចំពោះអ្នកប្រើប្រាស់ដីធ្លី
- សេចក្តីណែនាំស្តីពីកិច្ចការពារសិទ្ធិជនជាតិដើមភាគតិច
- លក្ខខណ្ឌកិច្ចសន្យាសម្រាប់អនុវត្តច្បាប់ការងារ កិច្ចការពារបរិស្ថាន។ល។

សេចក្តីណែនាំថ្មីនេះបានធ្វើបច្ចុប្បន្នភាពវិធីសាស្ត្រទាំងនេះ ដើម្បីបញ្ចូលតម្រូវការនានាដែលពាក់ព័ន្ធនឹងគោនយោបាយ ESS។ ទោះបីជាយ៉ាងណាក៏ដោយ នីតិវិធីមួយចំនួនដែលមានស្រាប់ ដូចជាការសិក្សាដីធ្លី និងការសិក្សាអំពីសិទ្ធិជនជាតិដើមភាគតិចនឹងមិនមានការផ្លាស់ប្តូរទេ។

ក្រៅពីសៀវភៅណែនាំ PIM របស់ក្រុង ស្រុក និងឃុំ សង្កាត់ ក៏មានសៀវភៅណែនាំមួយចំនួនទៀតដែលបានបញ្ចូលការងារបរិស្ថាន និងសង្គមក្នុងការអនុវត្តគម្រោងដូចជា សៀវភៅណែនាំស្តីពីការអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិជាដើម។ ជារួមផ្នែកមួយចំនួននៃគោលនយោបាយថ្មីនេះត្រូវបានបញ្ចូល និង កំពុងអនុវត្តដោយគម្រោង និងកម្មវិធីនានាដែលកំពុងដំណើរការ។

គោលនយោបាយ ESS មានសង្គតិភាពជាមួយច្បាប់ និងលិខិតបទដ្ឋាននានារបស់ព្រះរាជាណាចក្រកម្ពុជា។ ការអនុវត្តគោលនយោបាយនេះ គឺជាការអនុវត្តច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ២.២. យុទ្ធសាស្ត្រទី១ ៖ ការវិភាគ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងហានិភ័យសង្គម

### ២.២.២. វិសាលភាពនៃយុទ្ធសាស្ត្រទី១

យុទ្ធសាស្ត្រទី១ គឺជាក្របខ័ណ្ឌសម្រាប់ការកំណត់ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ទាំងអស់ដែលពាក់ព័ន្ធនឹងសុវត្ថិភាពបរិស្ថាន និងសង្គម។ យុទ្ធសាស្ត្រនីមួយៗចាប់ពីយុទ្ធសាស្ត្រទី២រហូតដល់យុទ្ធសាស្ត្រទី៨ពាក់ព័ន្ធនឹងប្រភេទជាក់លាក់នៃហានិភ័យនីមួយៗ។ អាស្រ័យហេតុនេះ យុទ្ធសាស្ត្រទី១រួមបញ្ចូលនូវកិច្ចដំណើរការសម្រាប់ការអនុវត្តយុទ្ធសាស្ត្រទី២ដល់យុទ្ធសាស្ត្រទី៨។

**យុទ្ធសាស្ត្រទី១ ៖**

- សិក្សាហានិភ័យ និងផលប៉ះពាល់
- ប្រឹក្សាយោបល់ជាមួយប្រជាពលរដ្ឋប៉ះពាល់ដោយគម្រោង
- កំណត់ហានិភ័យគម្រោង ៖ ខ្ពស់ មធ្យម និងទាប
- រៀបចំផែនការស្តីពីការគ្រប់គ្រងហានិភ័យ
- តាមដាន និងវាយតម្លៃ
- បណ្តឹងអំពីផលប៉ះពាល់នៃគោលនយោបាយ ESS

យុទ្ធសាស្ត្រទី២ ៖ ពលកម្ម និងលក្ខខណ្ឌបំពេញការងារ

យុទ្ធសាស្ត្រទី៣ ៖ ប្រសិទ្ធភាពធនធាន និងការគ្រប់គ្រងការបំពុលបរិស្ថាន

យុទ្ធសាស្ត្រទី៤ ៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍

យុទ្ធសាស្ត្រទី៥៖ លទ្ធកម្មដីធ្លី និងការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្ត

យុទ្ធសាស្ត្រទី៦៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិដែលមានជីវិតដោយនិរន្តរភាព

យុទ្ធសាស្ត្រទី៧ ៖ ជនជាតិដើមភាគតិច

យុទ្ធសាស្ត្រទី៨ ៖ បេតិកភណ្ឌវប្បធម៌

យុទ្ធសាស្ត្រទី១រួមបញ្ចូលនូវ ៖

- កិច្ចដំណើរការពិនិត្យពិច័យគម្រោងទាំងអស់ ដើម្បីកំណត់អំពីហានិភ័យបរិស្ថាន និងសង្គមពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី២-៨
- ធ្វើចំណាត់ថ្នាក់គម្រោងទាំងអស់ជា ក (ហានិភ័យខ្ពស់) ខ (ហានិភ័យមធ្យម) ឬ គ (ហានិភ័យទាប) ផ្អែកលើលទ្ធផលនៃការពិនិត្យពិច័យ
- នីតិវិធីនានាសម្រាប់អនុវត្តការសិក្សាហានិភ័យ និងរៀបចំវិធានការគ្រប់គ្រងហានិភ័យ ដើម្បីចៀសវាង កាត់បន្ថយ ឬបន្ធូរបន្ថយ
- នីតិវិធីនានាសម្រាប់អនុវត្តវិធានការគ្រប់គ្រងហានិភ័យ
- នីតិវិធីនានាសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃសុវត្ថិភាពបរិស្ថាន និងសង្គម
- នីតិវិធីសម្រុះសម្រួលដោះស្រាយបណ្តឹងប្រជាពលរដ្ឋអំពីបញ្ហាបរិស្ថាន និងសង្គមដែលបណ្តាលមកពីគម្រោងនានា។

## ២.២.២. កិច្ចដំណើរការសម្រាប់ការកំណត់ និងការគ្រប់គ្រងហានិភ័យ

វាក្យសព្ទក្នុងតារាងខាងក្រោមពន្យល់អំពីពាក្យមួយចំនួនដែលមានសារសំខាន់សម្រាប់ការកំណត់ និងការគ្រប់គ្រងហានិភ័យ។

| វាក្យសព្ទ | អត្ថន័យ |
|---|---|
| **ផលប៉ះពាល់អវិជ្ជមាន** | ជាលទ្ធផលមិនល្អដែលអាចកើតមានឡើងពីការអនុវត្តគម្រោងអាចមានវិសាលភាពធំ មធ្យម ទាប។ |
| **ភាពអាចកើតមានឡើង** | លទ្ធភាពដែលអាចកើតមានឡើងនូវផលប៉ះពាល់ជាអវិជ្ជមាន ៖ អាចកើតមានឡើងច្រើន ឬតិច។ |
| **ហានិភ័យ** | ជាទំហំផលប៉ះពាល់ជាអវិជ្ជមាន និងភាពដែលកើតមានឡើង។គម្រោងអាចមានហានិភ័យខ្ពស់ ។ មធ្យម ឬទាប។ហានិភ័យអាចខ្ពស់ក្នុងករណីផលប៉ះពាល់ធំ ឬមធ្យមអាចកើតមានឡើងពិតប្រាកដ។ |
| **វិធានការគ្រប់គ្រងហានិភ័យ** | ជាសកម្មភាពនានាដែលអនុវត្ត ដើម្បីកាត់បន្ថយភាពអាចកើតមានឡើងនៃផលប៉ះពាល់ជាអវិជ្ជមាន ឬវិសាលភាពនៃផលប៉ះពាល់ ប្រសិនប់ផលប៉ះពាល់នេះកើតមានឡើង។ |
| **ចៀសវាង** | មានន័យថា យើងអាចផ្លាស់ប្តូរការរៀបចំគម្រោងបាន (ឬជ្រើសរើសគម្រោងថ្មី) ដើម្បីមិនឱ្យផលប៉ះពាល់ជាអវិជ្ជមានកើតមានឡើង។ |
| **ការកាត់បន្ថយ** | ជាវិធានការនានាដើម្បីកាត់បន្ថយទំហំផលប៉ះពាល់អវិជ្ជមាន ប្រសិនបើកើតមានឡើង។ ឧទាហរណ៍៖ ការរៀបចំគម្រោងឆ្លងកាត់តាមព្រៃដែលធ្វើឱ្យមានផលប៉ះពាល់តិចតួចដល់ដើមឈើ។ |
| **ការបន្ធូរបន្ថយ** | មានន័យថា នៅពេលផលប៉ះពាល់អវិជ្ជមានកើតមានឡើង យើងអនុវត្តវិធានការនានា ដើម្បីសងចំពោះផលប៉ះពាល់ជាអវិជ្ជមាន ដូចជាការសងម្ចាស់កាន់កាប់ដីធ្លីជាដើម។ |

ក្នុងកិច្ចដំណើរការអនុវត្តគម្រោង ការកំណត់ហានិភ័យបរិស្ថាន និងសង្គម និងការគ្រប់គ្រងហានិភ័យត្រូវអនុវត្តតាមរយៈកិច្ចដំណើរការដែលមានការចូលរួម។ នៅដំហាននីមួយៗប្រជាជនដែលអាចប៉ះពាល់ដោយសារគម្រោងត្រូវបានប្រឹក្សាយោបល់ និងជួយរៀបចំវិធានការនានាសម្រាប់ការគ្រប់គ្រងហានិភ័យ។

**ការពិនិត្យពិច័យ** ៖ គម្រោងថ្នាក់ក្រោមជាតិទាំងអស់ត្រូវឆ្លងកាត់ការពិនិត្យពិច័យអំពីហានិភ័យផ្នែកបរិស្ថាន និងសង្គម។ ការពិនិត្យពិច័យ ត្រូវអនុវត្តផ្អែកលើទម្រង់មួយដោយមានសំណួរមានលក្ខណៈសាមញ្ញ សំណួរនីមួយៗមានចម្លើយជា បាទ ឬ ទេ។

**ការពិនិត្យពិច័យ ៖** ផ្អែកលើលទ្ធផលនៃការពិនិត្យពិច័យ គម្រោងទាំងអស់ត្រូវកំណត់ចំណាត់ថ្នាក់ ក (ហានិភ័យខ្ពស់) ចំណាត់ថ្នាក់ ខ (ហានិភ័យមធ្យម) និងចំណាត់ថ្នាក់ គ (ហានិភ័យទាប)។

**សម្រាប់គម្រោងចំណាត់ថ្នាក់ ក ៖** រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រឹក្សាយោបល់ជាមួយក្រសួង ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធអំពីកិច្ចការដែលត្រូវអនុវត្តបន្ត។

**សម្រាប់គម្រោងចំណាត់ថ្នាក់ ខ ៖** គម្រោងត្រូវធ្វើការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម (ESIA) និងរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ឬការសិក្សាអំពីជនជាតិដើមភាគតិចអាស្រ័យលើប្រភេទហានិភ័យដែលបានកំណត់តាមរយៈការពិនិត្យពិច័យ។

**សម្រាប់គម្រោងចំណាត់ថ្នាក់ គ៖** គម្រោងមិនត្រូវការ ESIA និង ESMP ទេ ប៉ុន្តែត្រូវមានវិធានការមួយចំនួនផ្នែកបរិស្ថាន និងសង្គមដូចជា លក្ខខណ្ឌការងារជាស្តង់ដារសម្រាប់ការសាងសង់។

**គម្រោងចំណាត់ថ្នាក់ ក មិនទទួលបានការគាំទ្រមូលនិធិពីមូលនិធិអាកាសធាតុបៃតងទេ។**

ការវាយតម្លៃ ESIA មានលក្ខណៈស្រដៀងគ្នាទៅនឹងការវាយតម្លៃបរិស្ថាននៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ និងគម្រោងមូលនិធិក្រុង ស្រុក ដែលមានបច្ចុប្បន្ន ប៉ុន្តែការវាយតម្លៃនេះគ្របដណ្តប់យុទ្ធសាស្ត្រទាំងអស់នៃសុវត្ថិភាពបរិស្ថាន និងសង្គម លើកលែងតែយុទ្ធសាស្ត្រទី៥ដែលពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការផ្លាស់ប្តូរលំនៅដ្ឋាន និងយុទ្ធសាស្ត្រទី៧ស្តីពីជនជាតិដើមភាគតិច (យុទ្ធសាស្ត្រទាំងនេះមិនត្រូវអនុវត្តគ្រប់គម្រោងនោះទេ)។

ក្នុងករណី ការពិនិត្យពិច័យបានកំណត់យុទ្ធសាស្ត្រទី៥អំពីលទ្ធកម្មដីធ្លី ឬយុទ្ធសាស្ត្រទី៧អំពីជនជាតិដើមភាគតិច នោះការពិនិត្យពិច័យត្រូវអនុវត្តដូចនឹងនីតិវិធីដែលបានកំណត់នៅក្នុងសៀវភៅភី(PIM)ឃុំសង្កាត់ និងក្រុង ស្រុក។

ការរៀបចំផែនការ ESMP ត្រូវធ្វើឡើងផ្អែកលើលទ្ធផលនៃ ESIA។ ផែនការ ESMP ត្រូវពិនិត្យ និងអនុម័តដោយទីចាត់ការផែនការ និងវិនិយោគ រាជធានី ខេត្ត។

សម្រាប់គម្រោងស្ថិតក្នុងតំបន់ដែលមានហានិភ័យសង្គម ផែនការ ESMP ត្រូវពិនិត្យដោយក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។




| * មូលហេតុសម្រាប់ចំណាត់ថ្នាក់ ក និងក្រសួងជំនាញ | |
|---|---|
| ក្នុងតំបន់ស្នូល ឬតំបន់អភិរក្សនៃតំបន់ការពារបរិស្ថាន | ក្រសួងបរិស្ថាន |
| ប៉ះពាល់តំបន់វប្បធម៌ | ក្រសួងវប្បធម៌ |
| ផ្លាស់ប្តូរលំនៅដ្ឋានច្រើនជាង១០គ្រួសារ | ក្រសួងហិរញ្ញវត្ថុ |
| ប្រព័ន្ធធារាសាស្ត្រថ្មីធំជាង១០០ ហត | ក្រសួងធនធានទឹក |
| សាងសង់ទំនប់មានកម្ពស់ខ្ពស់ជាង១៥ម | ក្រសួងធនធានទឹក |

ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត និងក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងវាយតម្លៃផែនការ ESMP ។

ប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់អវិជ្ជមានពិតប្រាកដដោយគម្រោងអាចដាក់បណ្តឹង និងអាចទទួលបានសំណងតាមករណីជាក់ស្តែងនីមួយៗ។ នីតិវិធីសម្រុះសម្រួលដោះស្រាយបណ្តឹង ត្រូវអនុវត្តដោយការិយាល័យប្រជាពលរដ្ឋ។ ទោះជាយ៉ាងណាក្តី ប្រជាពលរដ្ឋក៏អាចដាក់បណ្តឹងរបស់ខ្លួនមកលេខាធិការដ្ឋាន

គ.ជ.អ.ប. ដោយផ្ទាល់ផងដែរ។ ការសម្រុះសម្រួលដោះស្រាយបណ្តឹង ត្រូវគោរពតាមគោលការណ៍សំខាន់មួយចំនួនដូចខាងក្រោម ៖

- ប្រជាជនដែលប៉ះពាល់ជាអវិជ្ជមានពីគម្រោងមានសិទ្ធិដាក់បណ្តឹង
- ប្រជាជនទទួលបានព័ត៌មានអំពីវិធីសាស្ត្រដាក់បណ្តឹង និងអំពីកិច្ចដំណើរការស្រាវជ្រាវ
- បណ្តឹងទាំងអស់ដែលទទួលបានត្រូវកត់ត្រាទុកជាឯកសារ និងធ្វើការស្រាវជ្រាវ
- មានវិធានការអនុវត្តសមស្របក្នុងករណីបណ្តឹងត្រូវបានរកឃើញថាមានលក្ខណៈសមហេតុផល
- កិច្ចដំណើរការត្រូវចងក្រងជាឯកសារ និងត្រូវបានធ្វើសវនកម្ម
- អ្នកប្តឹងត្រូវបានការពារពីអំពើសងសឹកផ្សេងៗ។

## ២.៣. យុទ្ធសាស្ត្រទី២ ៖ ពលកម្ម និងលក្ខខណ្ឌការងារ

### ២.៣.១. វិសាលភាពនៃយុទ្ធសាស្ត្រទី២

យុទ្ធសាស្ត្រទី២រួមបញ្ចូលនូវតម្រូវការសំខាន់ៗដូចខាងក្រោម ៖

- ផ្តល់នូវព័ត៌មានអំពីសិទ្ធិដល់កម្មករ និងនិយោជិតមានដូចជា ពេលវេលាអនុវត្តការងារ ការទូទាត់ការផ្តល់សំណង និងអត្ថប្រយោជន៍ផ្សេងៗដែលកម្មករត្រូវទទួលបាន
- ផ្តល់នូវសុវត្ថិភាព និងសុខុមាលភាពចំពោះពួកគាត់ក្នុងពេលបំពេញការងារ និងលក្ខខណ្ឌការងារដោយរួមបញ្ចូលទាំងគ្រោះថ្នាក់ក្នុងពេលបំពេញការងារផងដែរ
- ផ្អែកទៅលើគោលការណ៍ស្មើភាពគ្នា និងសមធម៌យេនឌ័រ ដោយមិនមានការរើសអើង ការផ្តល់សំណង ការផ្តល់ឱកាសការងារ ការគ្រប់គ្រង និងការបណ្តេញចេញពីការងារ
- មិនមានការរឹតត្បិតលើសិទ្ធិសេរីភាពកម្មករក្នុងការចូលរួមបង្កើតសហជីព ឬក្រុមតវ៉ា
- រៀបចំយន្តការទទួលបណ្តឹង និងឆ្លើយតបចំពោះកម្មករ
- ទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ផ្អែកតាមច្បាប់ការងារ និងកិច្ចការពារកុមារ)
- មិនមានការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ ឬការជួញដូរមនុស្ស
- មានការរក្សានូវសិទ្ធិ( លក្ខខណ្ឌការងារ )របស់កម្មករដែលត្រូវបានផ្តល់កិច្ចសន្យាដោយអ្នកទទួលការបន្ត ឬអ្នកផ្តល់សេវាកម្ម
- ការត្រួតពិនិត្យជាប្រចាំទៅលើការអនុវត្តការងារ ដោយគិតពីសុវត្ថិភាពជាចម្បង ដើម្បីកាត់បន្ថយហានិភ័យទៅលើការប្រើប្រាស់កម្លាំងពលកម្ម ។

ក្នុងករណីភាគច្រើន ការអនុវត្តតាមតម្រូវការនានានៃយុទ្ធសាស្ត្រទី២ មានលក្ខណៈដូចគ្នាទៅនឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានានៃព្រះរាជាណាចក្រកម្ពុជា។

### ២.៣.២. ការអនុវត្តយុទ្ធសាស្ត្រទី២ក្នុងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកលើលទ្ធផលនៃការពិនិត្យពិច័យ គម្រោងអាចត្រូវបានចាត់ចូលក្នុងចំណាត់ថ្នាក់ ខ ដែលពាក់ព័ន្ធនឹងពលកម្ម និងខណ្ឌខណ្ឌបំពេញការងារ ប្រសិនបើគម្រោងនោះជា ៖

- គម្រោងដែលត្រូវការកម្លាំងពលកម្មលើសពី៥០នាក់ ដើម្បីអនុវត្ត (ករណីនេះមិនរួមបញ្ចូលនូវការជួលប្រជាពលរដ្ឋក្នុងសហគមន៍សម្រាប់ការងារដូចជា ការដាំស្មៅនោះទេ)
- គម្រោងដែលត្រូវការកម្លាំងពលកម្មច្រើនជាង១០នាក់ សម្រាប់រយៈពេលលើសពី៣ខែ គម្រោងនោះត្រូវចាត់ទុកជាគម្រោងប្រភេទ ខ
- គម្រោងដែលមានការងារប្រកបដោយគ្រោះថ្នាក់ដល់កម្មករ លើកលែងតែការងារនោះត្រូវបានអនុវត្តដោយកម្មករដែលទទួលបានការបណ្តុះបណ្តាលពិសេស (ឧទាហរណ៍ ប្រសិនបើ កម្មករជាសហគមន៍មូលដ្ឋានត្រូវបានជួលឱ្យបំពេញការងារដែលមានគ្រោះថ្នាក់ គម្រោងនោះចាត់ទុកជាគម្រោងប្រភេទ ខ។

គម្រោងប្រភេទ ខ ត្រូវមានការសិក្សាវាយតម្លៃអំពីផលប៉ះពាល់បរិស្ថាន និងសង្គម (ESIA) និងត្រូវរៀបចំផែនការ ESMP សម្រាប់គ្រប់គ្រងហានិភ័យការងារ និងលក្ខខណ្ឌបំពេញការងារ។

ទោះបីជាយ៉ាងណាក៏ដោយ សុវត្ថិភាពពលកម្ម និងលក្ខខណ្ឌការងារត្រូវអនុវត្តចំពោះគម្រោងទាំងអស់ដែលមានជួលកម្មករអនុវត្តគម្រោង រួមបញ្ចូលទាំងគម្រោងដែលមានចំណាត់ថ្នាក់ គ។

លក្ខខណ្ឌកិច្ចសន្យា ត្រូវបញ្ជាក់ច្បាស់អំពីការទទួលខុសត្រូវរបស់អ្នកទទួលការក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងពលកម្ម និងលក្ខខណ្ឌការងារ។

អ្នកទទួលការត្រូវធានាការអនុវត្តតាមសុវត្ថិភាពពលកម្ម និងលក្ខខណ្ឌការងារ ដោយអ្នកទទួលការ និងអ្នកផ្គត់ផ្គង់។ ឧទាហរណ៍ ៖ អ្នកទទួលការមិនទិញឥដ្ឋពីសិប្បកម្មឡឥដ្ឋដែលប្រើកម្លាំងពលកម្មកុមារ។

មានប្រភេទគម្រោងមួយចំនួន ដែលទាមទារឱ្យមានវិធានការគ្រប់គ្រងហានិភ័យជាក់លាក់នៅក្នុងផែនការ ESMP ។

- ប្រសិនបើ ការអនុវត្តគម្រោងពាក់ព័ន្ធនឹងការងារដែលមានគ្រោះថ្នាក់
- ប្រសិនបើ ការអនុវត្តគម្រោងតម្រូវការកម្មករច្រើន ត្រូវការកន្លែងស្នាក់នៅដែលមានអនាម័យ និងសុវត្ថិភាព និងការរៀបចំនានា ដើម្បីចៀសវាងជម្លោះជាមួយប្រជាជនមូលដ្ឋាន

**ឧទាហរណ៍អំពីពលកម្ម និងលក្ខខណ្ឌការងារក្នុងការអនុវត្តគម្រោងថ្នាក់ក្រោមជាតិ**

- ពុំមានកុមារធ្វើការឱ្យអ្នកទទួលការ ឬអ្នកម៉ៅការបន្ត និងអ្នកផ្គត់ផ្គង់ លើកលែងតែបានអនុញ្ញាតដោយច្បាប់ការងារ។
- កម្មករសំណង់ទទួលបានឧបករណ៍សុវត្ថិភាពប្រើប្រាស់ (មួក ស្បែកជើង ម៉ាស)។ អ្នកទទួលការត្រូវទទួលខុសត្រូវឱ្យកម្មករប្រើប្រាស់ឧបករណ៍សុវត្ថិភាព។
- កម្មករទាំងអស់ដែលរស់នៅក្នុងការដ្ឋានគម្រោងត្រូវមានកន្លែងរស់នៅដែលមានអនាម័យ និងសុវត្ថិភាព។
- អ្នកទទួលការ និងអ្នកផ្គត់ផ្គង់ទាំងអស់ត្រូវគោរពគោលការណ៍ផ្តល់ប្រាក់ខែមានសមភាព និងឱកាសមានសមភាពចំពោះបុរស និងស្ត្រី។

## ២.៤. យុទ្ធសាស្ត្រទី៣ ៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន

### ២.៤.១. វិសាលភាពនៃយុទ្ធសាស្ត្រទី៣

យុទ្ធសាស្ត្រទី៣រួមបញ្ចូលនូវសម្រូវការសំខាន់ៗដូចខាងក្រោម ៖

- ប្រើប្រាស់ថាមពលក្នុងការអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព ក្នុងបរិមាណសមស្របដោយផ្អែកលើប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់
- ប្រើប្រាស់ទឹកសម្រាប់ការអនុវត្តគម្រោងក្នុងបរិមាណសមស្រប ដែលមិនបង្កផលប៉ះពាល់ដល់គុណភាពទឹក និងនិរន្តរភាពនៃប្រភពទឹកប្រើប្រាស់របស់សហគមន៍
- ការប្រើប្រាស់វត្ថុធាតុដើមសម្រាប់សំណង់ក្នុងបរិមាណសមស្រប ដែលអាចបង្កផលប៉ះពាល់ដល់បរិស្ថាន និងនិរន្តរភាពនៃការប្រើប្រាស់របស់សហគមន៍
- មិនមានការបំពុលបរិស្ថានដោយសារការអនុវត្តគម្រោងក្នុងសហគមន៍ ដោយត្រូវចៀសវាងរាល់សកម្មភាពនានាដែលបំពុលទៅលើខ្យល់ ទឹក និងដី ប្រសិនបើសកម្មភាពទាំងនោះមិនអាចចៀសផុតពីការបំពុលបរិស្ថានទេនោះ ត្រូវតែធ្វើផែនការកាត់បន្ថយការបំពុលទាំងនោះឱ្យនៅកម្រិតអប្បបរិមា ឬនៅកម្រិតទាបបំផុត
- ត្រូវចៀសវាងនូវការបង្កើនសំណល់នានា ទាំងសំណល់ប្រកបដោយគ្រោះថ្នាក់ និងសំណល់មិនគ្រោះថ្នាក់ ប្រសិនបើមិនអាចចៀសវាងបាន គួរកាត់បន្ថយសំណល់ទាំងនោះឱ្យនូវកម្រិតទាបបំផុត
- សម្ភារទាំងឡាយណាដែលអាចបង្កឱ្យមានគ្រោះថ្នាក់ និងមិនមានសុវត្ថិភាពក្នុងការប្រើប្រាស់សម្រាប់កម្មករ ឬអ្នកអនុវត្តគម្រោង ត្រូវតែជំនួសវិញដោយសម្ភារដែលមិនមានគ្រោះថ្នាក់ និងមានសុវត្ថិភាព និងត្រូវចៀសវាងនូវការផលិត ការដោះដូរ ការប្រើប្រាស់សារធាតុគីមីដែលច្បាប់បានហាមឃាត់
- គ្រប់គ្រងលើវិធានការចម្រុះគ្រប់គ្រងដំណាំអាយភីអឹម(IPM) ការពារដំណាំនានាដោយត្រូវធានាគ្រប់គ្រងលើការប្រើប្រាស់សារជាតុពុលក្នុងវិធានការនេះ និងមិនធ្វើឱ្យបំពុលដល់ជីវចម្រុះដែលមាននៅក្នុងតំបន់របស់សហគមន៍
- មានការទទួលការខុសត្រូវក្នុងការបំភាយឧស្ម័នផ្ទះកញ្ចក់ឱ្យមានតុល្យភាពក្នុងបរិស្ថាន
- ធ្វើការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងគម្រោងទាំងឡាយណាដែលមានបំភាយឧស្ម័ននេះទៅក្នុងបរិយាកាស។

## ២.៤.២. ការអនុវត្តយុទ្ធសាស្ត្រទី៣ក្នុងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ

គម្រោងដែលមានហានិភ័យពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៣ ត្រូវបានកំណត់តាមរយៈការពិនិត្យពិច័យ។

គម្រោង ដែលពាក់ព័ន្ធនឹងការសាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីស្រោចស្រពផ្ទៃដីលើសពី១០០ហិចតា ត្រូវចាត់ទុកជាគម្រោងមានចំណាត់ថ្នាក់ ក ដោយសារគម្រោងនេះត្រូវប្រើប្រាស់ទឹកសម្រាប់ប្រព័ន្ធស្រោចស្រព ដែលមានអាចធ្វើឱ្យខ្វះទឹកសម្រាប់អ្នកប្រើប្រាស់ដទៃទៀត ឬសម្រាប់បរិស្ថាន។ ក្នុងករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រឹក្សាយោបល់ជាមួយក្រសួងធនធានទឹក និងឧតុនិយមមុននឹងបន្តការអនុវត្ត។

គម្រោងមានលក្ខណៈដូចក្នុងតារាងខាងក្រោម ត្រូវចាត់ទុកជាគម្រោងមានចំណាត់ថ្នាក់ ខ។

| ជាគម្រោងដែលពាក់ព័ន្ធនឹង | មូលហេតុ |
|---|---|
| សំណង់ប្រព័ន្ធធារាសាស្ត្រថ្មីស្រោចស្រពផ្ទៃដីតិចជាង១០០ហិតាដែលពុំធ្លាប់មានការស្រោចស្រពកន្លងមក | ពិនិត្យមើលថា តើមានទឹកគ្រប់គ្រាន់សម្រាប់ប្រព័ន្ធនេះឬទេ និងមិននាំឱ្យមានកង្វះទឹកសម្រាប់អ្នកប្រើប្រាស់ដទៃ ឬសម្រាប់បរិស្ថានធម្មជាតិ |
| ការជួសជុល ឬកែលម្អប្រព័ន្ធធារាសាស្ត្រថ្មីស្រោចស្រពលើផ្ទៃដីតិចជាង ១០០ហិតា | |
| ការសាងសង់ ឬជួសជុលអាងស្តុកទឹកដែលមានផ្ទៃទឹកលើសពី១ហិតា (កម្ពស់តិចជាង១៥ម) | |
| ការប្រើប្រាស់ទឹកលើសពី១០%ពីអូរ ឬប្រឡាយដែលមាន? | |
| ការងារសាងសង់គម្រោងស្ថិតនៅជិតផ្ទះប្រជាពលរដ្ឋ ហាង សាលារៀន វត្តអារាម គ្លីនិក ឬកន្លែងមានមនុស្សច្រើនធ្វើចរាចរ? | ការងារសាងសង់អាចនាំឱ្យមានសម្លេង ឬបំពុលខ្យល់ និងប៉ះពាល់ជាអវិជ្ជមានដល់ប្រជាជនរស់នៅ ឬធ្វើការនៅក្បែរនោះ |
| ការងារសាងសង់គម្រោងនៅកន្លែងដែលមានចរន្តទឹក (ដូចជាក្នុងប្រឡាយ ឬកាត់ផ្លូវថ្នល់)? | ការងារសាងសង់អាចនាំឱ្យពុលទឹក និងប៉ះពាល់អវិជ្ជមានដល់អ្នកប្រើប្រាស់ |
| ការសាងសង់កន្លែងកែច្នៃផលិតផលកសិកម្មមានសមត្ថភាពលើសពី១តោន/ថ្ងៃ? | កន្លែងកែច្នៃអាចមានសំណល់រាវ និងរឹងដែលចាក់ចោលដោយមិនប្រុងប្រយ័ត្ន និងមិនមានសុវត្ថិភាព |
| ការសាសសង់ ឬជួសជុលទីកន្លែងចាក់សំណល់រឹង? | កន្លែងចាក់សំណល់រឹង នាំឱ្យពុលទឹក និងពុលខ្យល់ ប៉ះពាល់ដល់សហគមន៍ |
| គម្រោងដែលនាំឱ្យមានការបំពុលប្រភពទឹកក្នុងរយៈពេលវែង? | ផលប៉ះពាល់ជាអវិជ្ជមានដល់អ្នកប្រើប្រាស់ទឹក និងបរិស្ថាន |
| គម្រោងដែលនាំឱ្យមានប្រភពសំណល់រឹងរយៈពេលវែង ដូចជាប្លាស្ទិច? | ផលប៉ះពាល់អវិជ្ជមានដល់បរិស្ថានករណីសំណល់រឹងចាក់ចោលមិនសមស្រប |
| ការប្រើប្រាស់សារធាតុគីមីដែលមានគ្រោះថ្នាក់? | សារធាតុគីមីអាចប៉ះពាល់អវិជ្ជមានដល់ប្រជាជន និងបរិស្ថានធម្មជាតិ |

សម្រាប់គម្រោងដែលមានចំណាត់ថ្នាក់ ខ ហានិភ័យត្រូវវាយតម្លៃក្នុង ESIA និងវិធានការគ្រប់គ្រងហានិភ័យដែលត្រូវបញ្ចូលក្នុង ESMP ។

ជាការសំខាន់ ត្រូវយកចិត្តទុកដាក់ផលប៉ះពាល់លើហានិភ័យមានរយៈពេលវែង និងរយៈពេលខ្លី។

- ផលប៉ះពាល់រយៈពេលវែងនៅតែបន្តកើតមានឡើង បន្ទាប់ពីការអនុវត្តគម្រោងត្រូវបានបញ្ចប់។ ឧទាហរណ៍៖ គម្រោងធារាសាស្ត្រមួយបូមយកទឹកច្រើនហួសកម្រិតពីអូរ ឬបឹងដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់អ្នកប្រើប្រាស់ទឹក ឬលើបរិស្ថាន។
- ផលប៉ះពាល់រយៈពេលខ្លីបណ្តាលមកពីការអនុវត្តគម្រោងដោយផ្ទាល់ដូចជា ការសាងសង់ដែលអាចបង្កឱ្យមានសម្លេងខ្លាំង និងការបំពុលបណ្តាលមកពីធូលីដី។

| ឧទាហរណ៍នៃផលប៉ះពាល់រយៈពេលវែង | ឧទាហរណ៍នៃផលប៉ះពាល់រយៈពេលខ្លី |
|---|---|
| • គម្រោងជាវាសាស្ត្រត្រូវការប្រើប្រាស់ទឹកច្រើន ដូច្នេះនឹងនាំឱ្យខ្វះទឹកសម្រាប់អ្នកប្រើប្រាស់ ឬបរិស្ថានធម្មជាតិ<br>• ការសាងសង់លូកាត់ផ្លូវនឹងនាំឱ្យមានសំណឹកដី<br>• រោងចក្រកែច្នៃផលិតផលកសិកម្មនាំឱ្យមានការបំពុលខ្យល់ ឬការបំពុលទឹក<br>• គម្រោងប្រើប្រាស់សម្ភារ ឬសារធាតុប្លាស្ទិច (ដូចជាសំណាញ់ដែលប្រើប្រាស់សម្រាប់ការដាំដុះបន្លែ) ដែលត្រូវបោះចោលនៅពេលដែលសំណាញ់នោះចាស់<br>• ការចាក់ចោលទឹកកខ្វក់នាំឱ្យពុលទឹកក្នុងបឹង ក្នុងប្រឡាយតូចៗ ឬទឹកនៅក្រោមដី<br>• ម៉ាស៊ីនប្រើម៉ាស៊ូតសម្រាប់បូមទឹកបញ្ចេញផ្សែង និងឧស្ម័នកាបូនិចក្នុងបរិយាកាស។ | • ការងារសាងសង់នាំឱ្យបំពុលខ្សែទឹក<br>• ធូលីពីការសាសង់នាំឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋរស់នៅក្បែរនោះ<br>• សំឡេងនៃការសាងសង់នាំឱ្យរំខានដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរនោះ<br>• ចរាចរការសាងសង់នាំឱ្យខូចផ្លូវ<br>• ការបំពុលទឹក និងខ្យល់នៅកន្លែងសាងសង់<br>• សម្ភារសំណល់ពីការសាងសង់ដូចជា ថង់ប្លាស្ទិច...ដែលបោះចោលក្នុងបរិស្ថាន។ |

## ២.៥. យុទ្ធសាស្ត្រទី៤ ៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍

### ២.៥.១. វិសាលភាពនៃយុទ្ធសាស្ត្រទី៤

យុទ្ធសាស្ត្រទី៤រួមបញ្ចូលនូវតម្រូវការសំខាន់ៗដូចខាងក្រោម ៖

- វិភាគ និងបញ្ចៀសនូវរាល់ផលប៉ះពាល់លើសុខភាព និងសុវត្ថិភាព របស់ប្រជាពលរដ្ឋក្នុងអំឡុងពេលអនុវត្ត និងក្រោយពេលអនុវត្តគម្រោង
- បញ្ចៀស ឬកាត់បន្ថយកត្តានានា ដែលនាំឱ្យសហគមន៍ប្រឈមទៅនឹងជម្ងឺផ្សេងៗដែលមានផលប៉ះពាល់ទៅលើសុខភាពរបស់ប្រជាពលរដ្ឋដោយរួមបញ្ចូលទាំងជម្ងឺដែលបង្កឡើងដោយសំណល់គ្រោះថ្នាក់នានា ជំងឺឆ្លងតាមទឹក និងប្រព័ន្ធដង្ហើមជាដើម
- គ្រប់គ្រង និងរៀបចំសុវត្ថិភាពសារជាតុបង្កគ្រោះថ្នាក់ឱ្យបានជាអតិបរិមា ដែលបង្កការប្រឈមដល់សហគមន៍ ក៏ដូចជាគំរាមកំហែងដល់សុខភាព ឬអាយុជីវិតប្រជាពលរដ្ឋ និងកម្មករ
- រៀបចំវិធានការត្រៀមបង្កាចំពោះស្ថានភាពអាសន្នក្នុងកំឡុងពេលអនុវត្តគម្រោង នៅពេលដែលមានឧបទ្ទវហេតុ និងគ្រោះថ្នាក់ដែលបណ្តាលមកពីការធ្វេសប្រហែសក្នុងការអនុវត្តគម្រោង មកពីគ្រោះធម្មជាតិ អគ្គីភ័យ ការផ្ទុះ ឬការលេចធ្លាយនូវសារជាតុគីមីជាដើម
- វិភាគ និងកាត់បន្ថយហានិភ័យនានា ដែលអាចប៉ះពាល់ទៅលើសុវត្ថិភាពរបស់សហគមន៍ក្នុងអំឡុងពេលអនុវត្តគម្រោង និងក្រោយពេលបញ្ចប់គម្រោងដែលអាចបង្កឡើងដោយសម្ភារ បរិក្ខាសំណង់ ឬប្លង់បច្ចេកទេសសំណង់ ជាពិសេសផលប៉ះពាល់ទៅលើក្រុមជនងាយរងគ្រោះ ដូចជាស្ត្រី កុមារ ចាស់ជរា ជនពិការជាដើម
- ការពារសិទ្ធិសេរីភាពរបស់សហគមន៍ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់សកម្មភាពល្មើសនានា កំណត់មុខសញ្ញាល្មើស និងចាត់វិធានការសមស្រប ផ្អែកតាមគោលការណ៍ច្បាប់

- វិភាគ និងបញ្ចៀសឱ្យបានជាអតិបរិមានូវផលប៉ះពាល់ទៅលើប្រព័ន្ធអេកូឡូស៊ីដូចជា បាត់បង់តំបន់ទ្រនាប់នៃតំបន់ការពារ មានព្រៃកោងកាង ព្រៃឈើ ព្រៃលិចទឹក ឬធនធានទឹកសាបដែលជាការអាស្រ័យផលរបស់សហគមន៍។

## ២.៥.២. ការអនុវត្តយុទ្ធសាស្ត្រទី៤ក្នុងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ

គម្រោងដែលមានហានិភ័យពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៤ ត្រូវបានកំណត់តាមរយៈការពិនិត្យពិច័យ។

គម្រោងនានាដែលពាក់ព័ន្ធនឹងការសាងសង់ទំនប់ ឬអាងស្តុកទឹកដែលមានកម្ពស់លើសពី១៥ម៉ែត្រ ត្រូវបានចាត់ទុកជាគម្រោងមានចំណាត់ថ្នាក់ **ក** ដោយមូលហេតុថា ប្រសិនបើទំនប់នេះបាក់នឹងបង្កឱ្យមានទឹកទំនន់ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ប្រជាជន និងទ្រព្យសម្បត្តិរបស់ពួកគាត់។

សម្រាប់គម្រោងដែលមានចំណាត់ថ្នាក់ **ក** រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រឹក្សាយោបល់ជាមួយក្រសួងធនធានទឹក និងឧតុនិយម ដើម្បីអនុវត្តនីតិវិធីបន្ត។

គម្រោងទាំងឡាយដែលចាត់ចូលក្នុងចំណាត់ថ្នាក់ **ខ** ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៤ ជាគម្រោងដែលស្ថិតដូចក្នុងករណីខាងក្រោម ៖

| ជាគម្រោងដែលពាក់ព័ន្ធនឹង | មូលហេតុ |
|---|---|
| • ការសាងសង់ផ្លូវថ្មី | • ចំនួនគ្រោះថ្នាក់ចរាចរកើនឡើង |
| • កែលម្អ ឬពង្រីកផ្លូវដែលមានប្រវែងលើសពី១០ គ.ម. | • ចំនួនគ្រោះថ្នាក់កើនឡើង |
| • ការសាងសង់ ឬជួសជុលអាងស្តុកទឹកដែលមានផ្ទៃទឹកធំជាង១ហត (ប៉ុន្តែមានកម្ពស់តិចជាង១៥ម) | • គ្រោះថ្នាក់ដោយសារទំនប់បាក់ និងបង្កឱ្យមានទឹកជំនន់ |
| • ការងារសាងសង់គម្រោងស្ថិតនៅជិតផ្ទះប្រជាពលរដ្ឋ ហាងលក់ទំនិញ សាលារៀន វត្តអារាម គ្លីនិក ឬកន្លែងមានមនុស្សច្រើន កន្លែងមានចរាចរច្រើន? | • ប៉ះពាល់ដល់សុខភាពដោយសារធូលីដី<br>• គ្រោះថ្នាក់បង្កឡើងដោយសារម៉ាស៊ីនសម្រាប់សាងសង់នៅកន្លែងដែលមានមនុស្សច្រើន |
| • ការប្រើប្រាស់សារធាតុគីមីដែលមានគ្រោះថ្នាក់? | • គ្រោះថ្នាក់ដល់សុខភាពដោយសារមានសារធាតុគីមីដែលមានគ្រោះថ្នាក់ |
| • ទីតាំងគម្រោងដែលមានហានិភ័យខ្ពស់ ដោយហារមានទីតាំងនោះមានមីន និងគ្រាប់មិនទាន់ផ្ទុះ | • គ្រោះថ្នាក់ដល់កម្មករសំណង់ និងសហគមន៍ដោយសារការផ្ទុះគ្រាប់មីន |

សម្រាប់គម្រោងមានចំណាត់ថ្នាក់ ខ ហានិភ័យត្រូវវាយតម្លៃក្នុង ESIA ហើយវិធាននានាសម្រាប់ការគ្រប់គ្រងហានិភ័យត្រូវបញ្ចូលក្នុងផែនការ ESMP ។

**ឧទាហរណ៍ហានិភ័យពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៤**

- មីន ឬគ្រាប់មិនទាន់ផ្ទុះកប់ក្នុងកន្លែងសាងសង់
- ក្មេងៗលេងនៅក្បែរម៉ាស៊ីនសាងសង់
- ប្រជាជនបើកបរលឿនជាងមុនបន្ទាប់ពីមានផ្លូវល្អដែលនាំឱ្យមានគ្រោះថ្នាក់ច្រើនជាងមុន
- ទំនប់សាងសង់បានបាក់ និងនាំឱ្យមានទឹកជំនន់
- គម្រោងនាំឱ្យកសិករបង្កើនការប្រើប្រាស់ថ្នាំគីមីកសិកម្ម ដែលមានផលប៉ះពាល់មិនល្អដល់សុខភាព។

## ២.៦. យុទ្ធសាស្ត្រទី៥ ៖ លទ្ធកម្មដីធ្លី និងតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត

### ២.៦.១. វិសាលភាពនៃយុទ្ធសាស្ត្រទី៥

យុទ្ធសាស្ត្រទី៥រួមបញ្ចូលនូវសម្រួវការសំខាន់ៗដូចខាងក្រោម ៖

- ចៀសវាងឱ្យបាននូវរាល់ការបណ្ដេញចេញដោយបង្ខំ ការគំរាមកំហែង និងការផ្លាស់ទីលំនៅរបស់សហគមន៍
- ចៀសវាងឱ្យបាន នូវរាល់ការតាំងទីលំនៅរបស់សហគមន៍ដោយមិនមានការស្ម័គ្រចិត្ត
- សិក្សាពិចារណា ដោយប្រាកដប្រជាជាមួយប្រជាពលរដ្ឋលើលទ្ធកម្មដីធ្លី មានការបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត និងការទូទាត់សំណង
- ទូទាត់សំណងដល់ជនដែលត្រូវបានផ្លាស់ទីលំនៅដល់ជនដែលមានកម្មសិទ្ធិស្របច្បាប់ដោយសារការអនុវត្តគម្រោងដោយស្មើភាពគ្នា និងទទួលបានសំណងស្មើនឹងតម្លៃសេដ្ឋកិច្ចដែលត្រូវបាន បាត់បង់ដូចជា ដីធ្លី ទ្រព្យសម្បត្តិផ្សេងៗ ចំណូល និងស្ដារឡើងវិញនូវបរិស្ថានរស់នៅ និងសុខុមាលភាពដែលបានបាត់បង់
- ធ្វើឱ្យប្រសើរឡើងវិញនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងនោះ ដែលត្រូវបានផ្លាស់ទីលំនៅដោយសារតែការអនុវត្តគម្រោង
- ធានាឱ្យមានការផ្ដល់នូវសិទ្ធិកាន់កាប់ដីធ្លីដល់ជនដែលត្រូវបានផ្លាស់ទីលំនៅដោយស្របច្បាប់តាមរយៈការចេញប័ណ្ណកម្មសិទ្ធិជូន ឬសំណងជាសាច់ប្រាក់សម្រាប់ការរៀបចំប័ណ្ណកម្មសិទ្ធិ
- ធានាផ្ដល់ជូនទីលំនៅ និងទ្រព្យសម្បត្តិដែលបាត់បង់ដល់ជនដែលគ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់ហើយដែលត្រូវបានផ្លាស់ទីលំនៅដោយសារការអនុវត្តគម្រោង។

ផ្អែកតាមអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលខុសត្រូវក្នុងការគ្រប់គ្រង និងសំណងលទ្ធកម្មដីធ្លីសម្រាប់គម្រោងទាំងអស់ដែលមានមូលនិធិគាំទ្រពីដៃគូអភិវឌ្ឍន៍។ តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុម័តសំណងនានាដែលកំណត់ក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ គម្រោងណាមួយដែលតម្រូវឱ្យមានការផ្លាស់ប្ដូរទីលំនៅទ្រង់ទ្រាយធំ និងសំណងច្រើនសម្រាប់អ្នកប្រើប្រាស់ដីធ្លី រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រឹក្សាយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ២.៦.២. ការអនុវត្តយុទ្ធសាស្ត្រទី៥ក្នុងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ឧទាហរណ៍ផលប៉ះពាល់ជាអវិជ្ជមាននៃយុទ្ធសាស្ត្រទី៥**

- ប្រជាជនផ្លាស់ទីលំនៅពីកន្លែងធ្លាប់រស់នៅ
- ប្រជាជនផ្លាស់ទីកន្លែងនៃការប្រកបមុខរបរពីកន្លែងដើម
- ប្រជាជនបាត់បង់ដីកសិកម្ម
- ប្រជាជនបាត់បង់ដីដែលធ្លាប់ចិញ្ចឹមសត្វ ឬប្រមូលអនុផលព្រៃឈើ។

គម្រោងទាំងឡាយណាដែលតម្រូវឱ្យមានលទ្ធកម្មដីធ្លី (ការបរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត ឬដោយមានសំណង) ត្រូវបានកំណត់តាមរយៈការពិនិត្យពិច័យអំពីសុវត្ថិភាពបរិស្ថាន និងសង្គម។

គម្រោងណាមួយដែលទាមទារការផ្លាស់ទីលំនៅចាប់ពី១០គ្រួសារឡើងទៅ ត្រូវចាត់ទុកជាគម្រោងមានចំណាត់ថ្នាក់ **ក**។ ក្នុងករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រឹក្សាយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបន្តនីតិវិធីអនុវត្ត។

ជាមួយគ្នានេះដែរ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវប្រឹក្សាយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីគម្រោងត្រូវការសំណងលទ្ធកម្មដីធ្លីមានចំនួនច្រើន ទោះបីគម្រោងនេះពុំតម្រូវឱ្យមានការផ្លាស់ទីលំនៅចាប់ពី១០គ្រួសារក៏ដោយ ព្រោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកទទួលខុសត្រូវក្នុងការអនុម័តការវិភាជថវិកាជាមួយសម្រាប់សំណង។

គម្រោងដែលតម្រូវឱ្យមានលទ្ធកម្មដីធ្លី ប៉ុន្តែមានការផ្លាស់ទីលំនៅប្រជាជនតិចជាង១០ គ្រួសារ ត្រូវចាត់ចូលជាគម្រោងមានចំណាត់ថ្នាក់ **ខ** ។

សម្រាប់គម្រោងដែលមានចំណាត់ថ្នាក់ ខ ការធ្វើលទ្ធកម្មដីធ្លី និងការផ្លាស់ទីលំនៅ ត្រូវអនុវត្តតាមកិច្ចដំណើរការ និងនីតិវិធីដែលមានស្រាប់ដូចបានកំណត់ក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ (សៀវភៅភីម PIM)។ សេចក្តីសង្ខេបនៃកិច្ចដំណើរការនេះរួមមានដូចខាងក្រោម ៖

- ការសិក្សាដីធ្លីដឹកនាំដោយទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត
- ការឯកភាពជាមួយម្ចាស់ដី ឬអ្នករស់នៅលើដី
- ការរៀបចំរបាយការណ៍បរិច្ចាគដីដោយស្ម័គ្រចិត្ត
- ការទូទាត់សំណងក្នុងករណីចាំបាច់។

## ២.៧. យុទ្ធសាស្ត្រទី៦ ៖ *ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព*

### ២.៧.១. វិសាសភាពនៃយុទ្ធសាស្ត្រទី៦

យុទ្ធសាស្ត្រទី៦រួមបញ្ចូលនូវតម្រូវការសំខាន់ៗដូចខាងក្រោម ៖

- វាយតម្លៃ ឬកាត់បន្ថយនូវផលប៉ះពាល់ ដោយវិភាគ និងបញ្ចៀសឱ្យបានរាល់ផលប៉ះពាល់ទៅលើជីវចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី បើសិនជាមិនអាចជៀសបានទេ ត្រូវអនុវត្តវិធានការនានាដើម្បីកាត់បន្ថយនូវផលប៉ះពាល់ទាំងនោះឱ្យបានជាអតិបរិមា និងធ្វើឱ្យប្រសើរឡើងវិញនូវធនធានជីវចម្រុះ និងធនធានធម្មជាតិដែលមានជីវិតនៅក្នុងតំបន់ស្របទៅតាមច្បាប់
- លើកឡើងនូវវិធានការនានា ដើម្បីអភិរក្សតំបន់ជីវចម្រុះ ទោះបីជាមានការតាំងទីលំនៅ ឬការទន្ទ្រានដោយសកម្មភាពមនុស្សក្នុងតំបន់ការពារ ឬអភិរក្ស
- វិភាគលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលទទួលរងនូវផលប៉ះពាល់ដោយសារតែការអនុវត្តគម្រោង និងបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទាំងនោះជាអតិបរមា ឬធ្វើឱ្យនៅកម្រិតទាបបំផុតទៅលើប្រភេទកម្រមានដូចជា រុក្ខជាតិ និងសត្វដែលនៅក្នុងតំបន់អភិវឌ្ឍន៍នោះ

- មិនមានធ្វើការបម្លែង ឬធ្វើឱ្យផ្លាស់ប្តូរដែនជម្រកធម្មជាតិ ដែលមានស្រាប់ក្នុងតំបន់របស់សហគមន៍ឡើយ ដរាបណាមិនមានជម្រើសដ៏សមគួរណាមួយនោះទេ ត្រូវពិភាក្សាជាមួយអ្នកពាក់ព័ន្ធ និងត្រូវមានយន្តការកាត់បន្ថយផលប៉ះពាល់លើការបាត់បង់ជីវចម្រុះនោះ ដោយជាក់លាក់បំផុត
- ចៀសវាងដាច់ខាតការអនុវត្តគម្រោងនៅទីជម្រកសំខាន់ៗ ប្រសិនបើមិនមានជម្រើសប្រសើរណាមួយនោះទេ ការអនុវត្តគម្រោងត្រូវធានាមិនមានផលប៉ះពាល់ជាអវិជ្ជមានទៅលើជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងទីជម្រកទាំងនោះឡើយ ហើយមិនបង្កឱ្យមានគ្រោះថ្នាក់ដល់ប្រភេទសត្វ និងរុក្ខជាតិដែលងាយរងគ្រោះ ព្រមទាំងធានាឱ្យមានប្រព័ន្ធតាមដានមួយអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព
- គម្រោងមិនអាចអនុវត្តក្នុងតំបន់ការពារបានទេ លើកលែងតែសកម្មភាពនោះត្រូវបានអនុញ្ញាតដោយច្បាប់ និងធានាថាអ្នកពាក់ព័ន្ធទាំងអស់បានចូលរួមអនុវត្តបានពេញលេញតាមច្បាប់ និងបានខិតខំប្រឹងប្រែងខ្ពស់ក្នុងការរក្សានឹងធ្វើឱ្យប្រសើរឡើងនៅក្នុងតំបន់អភិរក្សនោះ
- ធានាថា សកម្មភាពដែលចូលរួមចំណែកក្នុងផលិតផលធនធានធម្មជាតិដែលមានជីវិត (ព្រៃឈើ ផលកសិកម្ម សត្វនិងរុក្ខជាតិ)ផលិតផលទាំងនោះត្រូវអោយសមស្របតាមស្តង់ដារជាតិ និងអន្តរជាតិស្តីពីការគ្រប់គ្រងដោយចីរភាព
- នៅក្នុងខ្សែច្រវ៉ាក់ផលិតកម្មលើធនធានជីវចម្រុះ និងធនធានធម្មជាតិដែលមានជីវិត ត្រូវធ្វើការត្រួតពិនិត្យ និងតាមដានជាប្រចាំដោយភ្នាក់ងារអនុវត្តការងារនេះ ដើម្បីធានាថា ធនធានធម្មជាតិ និងតំបន់អភិរក្សមិនត្រូវបានបំពាន និងធ្វើឱ្យរេចរឹលឡើយ។

## ២.៧.២. ការអនុវត្តយុទ្ធសាស្ត្រទី៦ក្នុងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ឧទាហរណ៍ផលប៉ះពាល់អវិជ្ជមាននៃយុទ្ធសាស្ត្រទី៦**

- គម្រោងអនុវត្តនៅក្នុងតំបន់ការពារធម្មជាតិ (ឧទ្យានជាតិ តំបន់អភិរក្សសត្វព្រៃ ព្រៃឈើ។ល។)
- គម្រោងបង្កគ្រោះថ្នាក់ដោយផ្ទាល់ដល់បរិស្ថានធម្មជាតិ រួមបញ្ចូលព្រៃឈើ តំបន់ដីសើម និងសត្វព្រៃ
- គម្រោងនាំឱ្យមានការកើនឡើងនូវសកម្មភាពប្រជាពលរដ្ឋ ដែលប៉ះពាល់ដល់បរិស្ថានធម្មជាតិ (ការបរបាញ់ ការនេសាទ ឬសកម្មភាពកសិកម្មក្នុងតំបន់ការពារ)
- គម្រោងនាំឱ្យមានការបង្ហូរទឹកចេញពីតំបន់ដីសើម
- គម្រោងនាំឱ្យកសិករផ្លាស់ប្តូរបច្ចេកទេសកសិកម្ម និងប្រើប្រាស់គីមីកាន់តែច្រើនដែលនាំឱ្យមានគ្រោះថ្នាក់ដល់សត្វ និងរុក្ខជាតិព្រៃដែលមានប្រយោជន៍។

គម្រោងទាំងឡាយដែលកពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៦ ត្រូវកំណត់តាមយរៈការពិនិត្យពិច័យ។

ក្នុងករណីមានផ្នែកណាមួយនៃគម្រោងស្ថិតនៅក្នុងតំបន់អភិរក្ស ឬតំបន់ការពារបរិស្ថាន គម្រោងនោះត្រូវចាត់ទុកជាគម្រោងមានចំណាត់ថ្នាក់ **ក**។ ក្នុងករណីនេះរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រឹក្សាយោបល់ជាមួយក្រសួងបរិស្ថាន ដើម្បីបន្តនីតិវិធីអនុវត្ត។

គម្រោងទាំងអស់ដែលមានចំណាត់ថ្នាក់ **ខ** នៃយុទ្ធសាស្ត្រទី៦ ជាគម្រោងដែលមានដូចករណីក្នុងតារាងខាងក្រោម ៖

| ជាគម្រោងដែលពាក់ព័ន្ធនឹង | មូលហេតុ |
|---|---|
| • គម្រោងដែលមានទីតាំងស្ថិតក្នុងបញ្ជីឃ្លាំមើលផ្នែកបរិស្ថាន របស់ គ.ជ.អ.ប. | • គម្រោងស្ថិតក្នុងតំបន់ការពារបរិស្ថាន |
| • គម្រោងដែលនឹងមានផលប៉ះពាល់ ៖<br>➢ ព្រៃធម្មជាតិ<br>➢ ព្រៃលិចទឹកធម្មជាតិ/ ព្រៃកោងកាង<br>➢ តំបន់ដីសើម<br>➢ តំបន់ព្រំប្រទល់ទឹកសាប-ទឹកប្រៃ | • ហានិភ័យនៃការបំផ្លិចបំផ្លាញតំបន់ការពារបរិស្ថាន |
| • ការសាងសង់ផ្លូវថ្មី | • ហានិភ័យដោយសារការសាងសង់ផ្លូវថ្មីនាំឱ្យបំផ្លាញបរិស្ថាន |
| • ការកែលម្អ ឬពង្រីកផ្លូវដែលមានប្រវែងលើសពី១០ គ.ម | • ហានិភ័យដោយសារការកែលម្អ ឬពង្រីកផ្លូវដែលនាំឱ្យបំផ្លាញបរិស្ថាន |
| • ការដាំដុះលើដីដែលមិនធ្លាប់មានការដាំដុះកន្លងមក | • ហានិភ័យដោយសារការពង្រីកដីសម្រាប់ដាំដំណាំនាំឱ្យបំផ្លាញបរិស្ថានធម្មជាតិ |
| • ការប៉ះពាល់ដល់តំបន់ព្រៃលិចទឹក | • ហានិភ័យដែលពាក់ព័ន្ធនឹងការបំផ្លាញព្រៃលិចទឹកធម្មជាតិ |
| • ការប៉ះពាល់ដល់តំបន់ព្រៃ (ដែលមិនមែនជាព្រៃលិចទឹក) | • ហានិភ័យដែលនាំឱ្យបំផ្លាញព្រៃធម្មជាតិ |

សម្រាប់គម្រោងទាំងអស់ដែលមានចំណាត់ថ្នាក់ ខ ហានិភ័យត្រូវវាយតម្លៃក្នុង ESIA និងវិធានការនានាសម្រាប់គ្រប់ហានិភ័យត្រូវបញ្ចូលក្នុងផែនការ ESMP។

## ២.៨. យុទសាស្ត្រទី៧ ៖ ជនជាតិដើមភាគតិច

### ២.៨.១. វិសាលភាពនៃយុទ្ធសាស្ត្រទី៧

យុទ្ធសាស្ត្រទី៧រួមបញ្ចូលនូវតម្រូវការសំខាន់ៗដូចខាងក្រោម ៖

- កំណត់ឱ្យបាននូវអត្តសញ្ញាណនៃជនជាតិដើមភាគតិច ធនធានធម្មជាតិ និងតំបន់រស់នៅរបស់ពួកគាត់ដែលទទួលរង នូវផលប៉ះពាល់ដោយសារគម្រោង និងធានាបានថាគម្រោងនឹងផ្តល់ផលប្រយោជន៍ដល់ជនជាតិដើមភាគតិច
- ចៀសវាងឱ្យបាននូវផលប៉ះពាល់ជាវិជ្ជមានទៅលើវប្បធម៌របស់ជនជាតិដើមភាគតិច បើសិនជាមិនអាចចៀសវាងបាន ត្រូវធានាកាត់បន្ថយផលប៉ះពាល់ទាំងនោះជាអតិបរមា និងត្រូវស្តារឡើងវិញ ឬប៉ះប៉ូវទៅលើសកម្មភាពនានាដែលប៉ះពាល់ដល់វប្បធម៌របស់ពួកគាត់
- ចៀសវាងឱ្យបាននូវការអនុវត្តគម្រោងដែលមានផលប៉ះពាល់ទៅលើទីសក្ការបូជា ឬដីប្រើប្រាស់របស់ជនជាតិដើមភាគតិច លើកលែងតែគម្រោងនោះបានសិក្សាស៊ីជម្រៅពីផលប៉ះពាល់ទាំងនោះ ហើយបានជូនដំណឹងអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច និងត្រូវធានាថា ជនជាតិដើមភាគតិច អាចអាស្រ័យផល ទទួលបានសំណង និងផលប្រយោជន៍សមស្របពីគម្រោងនោះ
- មិនអាចផ្លាស់ទីលំនៅរបស់ជនជាតិដើមភាគតិចពីទីតាំងចាស់របស់ពួកគាត់ ឬផ្លាស់ប្តូរធនធាន

ធម្មជាតិដែលពួកគាត់អាស្រ័យផលឡើយ លើកលែងតែពួកគាត់បានយល់ព្រម ដោយស្ម័គ្រចិត្ត

- ការអនុវត្តគម្រោងមិនត្រូវធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរទៅលើបេតិកភណ្ឌវប្បធម៌របស់ជនជាតិដើមភាគតិចឡើយ លើកលែងតែពួកគាត់យល់ព្រមផ្លាស់ប្តូរទីតាំងដោយស្ម័គ្រចិត្ត
- ចៀសវាងការប្រើប្រាស់វប្បធម៌ប្រពៃណីរបស់ជនជាតិដើមភាគតិច ដើម្បីធ្វើអាជីវកម្មនានា លើកលែងតែមានការឯកភាព និងទទួលបានអត្ថប្រយោជន៍សមស្របសម្រាប់លើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់
- រាល់ការរៀបចំអនុវត្តសកម្មភាពនានារបស់គម្រោង ត្រូវតែមានការចូលរួម និងពិភាក្សាជាមុនជាមួយជនជាតិដើមភាគតិច ពិសេសតំណាង និងមេភូមិរបស់ពួកគាត់។

គោលការណ៍នៃ **សេរីភាព ជាមុន** និង**ការសម្រេចចិត្តផ្អែកលើព័ត៌មាន** ត្រូវអនុវត្តចំពោះគ្រប់គម្រោងដែលនឹងប៉ះពាល់ដីធ្លី វប្បធម៌ ឬជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច។

**សេរីភាព ៖** មានន័យថា សហគមន៍ជនជាតិដើមភាគតិចឯកភាពជាមួយសំណើគម្រោងដោយស្ម័គ្រចិត្ត និងដោយគ្មានការបង្ខំ។

**ជាមុន ៖** មានន័យថា សហគមន៍ជនជាតិដើមភាគតិចត្រូវបានប្រឹក្សាយោបល់ និងផ្តល់នូវការឯកភាពរបស់ខ្លួនមុនគម្រោងត្រូវបានអនុម័ត និងមុនការចាប់ផ្តើមការអនុវត្ត។

**ផ្តល់ព័ត៌មាន ៖** មានន័យថា សហគមន៍ជនជាតិដើមភាគតិចមានព័ត៌មានពេញលេញអំពីគម្រោង និងផលប៉ះពាល់ដែលរំពឹងទុកមុនពួកគាត់ឯកភាព។ បញ្ហានេះអាចទាមទារនូវការផ្តល់នូវព័ត៌មានជាភាសារបស់សហគមន៍ជនជាតិដើមភាគតិច។

**ការសម្រេចចិត្ត ៖** ការសម្រេចចិត្តជាសមូហភាពនៃសមាជិកនានារបស់សហគមន៍ជនជាតិដើមភាគតិច តាមរយៈកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តតាមបែបប្រពៃណី។

### ២.៨.២. ការអនុវត្តយុទ្ធសាស្ត្រទី៧ក្នុងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ឧទាហរណ៍ផលប៉ះពាល់ជាអវិជ្ជមានពាក់ព័ន្ធនឹងយុទ្ធាសាស្ត្រទី៧**

- គម្រោងប្រើប្រាស់ដីដែលជាកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ឬដែលមានសារសំខាន់សម្រាប់ជីវិតរបស់ពួកគាត់
- គម្រោងមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់របស់សហគមន៍ជនជាតិដើមភាគតិច
- គម្រោងមានផលប៉ះពាល់ជាអវិជ្ជមានដល់វប្បធម៌ និងប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច
- សហគមន៍ជនជាតិដើមភាគតិចប៉ះពាល់ដោយសារគម្រោង ប៉ុន្តែពួកគាត់មិនត្រូវបានប្រឹក្សាយោបល់ និងផ្តល់នូវការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងផ្អែកលើព័ត៌មានច្បាស់លាស់ជាមុន (FPIC) ។

គម្រោងទាំងឡាយដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៧ ត្រូវកំណត់តាមរយៈការពិនិត្យពិច័យ។

គម្រោងណាមួយដែលស្ថិតក្នុងតំបន់នៃបញ្ជីឃ្លាំមើលរបស់ គ.ជ.អ.ប. អំពីជនជាតិដើមភាគតិចត្រូវបានចាត់ទុកជាគម្រោងមានចំណាត់ថ្នាក់ ខ។

គម្រោងណាមួយដែលមានស្ថិតក្នុងបញ្ជីឃ្លាំមើលរបស់ គ.ជ.អ.ប. ប៉ុន្តែ នឹងប៉ះពាល់ដល់សហគមន៍នៃជនជាតិដើមភាគតិច ដែលរស់នៅតាមបែបប្រពៃណី ត្រូវចាត់ទុកជាគម្រោងមានចំណាត់ថ្នាក់ ខ។

សម្រាប់គម្រោងទាំងឡាយដែលមានចំណាត់ថ្នាក់ ខ ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៧ នីតិវិធីសម្រាប់ការពារសិទ្ធិជនជាតិដើមភាគតិចត្រូវអនុវត្ត ស្របតាមនីតិវិធីដែលបានកំណត់ក្នុងសៀវភៅណែនាំភីម(PIM)ស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក។

កិច្ចដំណើរការសម្រាប់គម្រោងចំណាត់ថ្នាក់ ខ នៃយុទ្ធសាស្ត្រទី៧ ដែលប៉ះពាល់ដល់ជនជាតិដើមភាគតិចត្រូអនុវត្តដូចនីតិវិធីកំណត់ក្នុងសៀវភៅណែនាំ PIM។ នីតិវិធីទាំងនេះតម្រូវឱ្យអនុវត្តតាមជំហានដូចខាងក្រោម ៖

- កិច្ចប្រជុំផ្សព្វផ្សាយអំពីគម្រោងដល់ជនជាតិដើមភាគតិច
- កិច្ចប្រជុំពិភាក្សាជាមួយជនជាតិដើមភាគតិចអំពីផែនការគម្រោង
- របាយការណ៍អំពីវិធានការការពារជនជាតិដើមភាគតិច។

## ២.៩. យុទ្ធសាស្ត្រទី៨ ៖ បេតិកភណ្ឌវប្បធម៌

### ២.៩.១. វិសាលភាពនៃយុទ្ធសាស្ត្រទី៨

យុទ្ធសាស្ត្រទី៨រួមបញ្ចូលនូវតម្រូវការសំខាន់ៗដូចខាងក្រោម ៖

- កំណត់ និងចៀសវាងផលប៉ះពាល់វិជ្ជមានទៅលើបេតិកភណ្ឌវប្បធម៌រូបី(ទីតាំងបុរាណវិទ្យា ទីតាំងប្រវត្តិសាស្ត្រ) និងបេតិកភណ្ឌវប្បធម៌អរូបី(ទីតាំងជំនឿ និងទីសក្ការបូជា) ជាដើម
- អនុវត្តនូវច្បាប់បេតិកភណ្ឌ ដើម្បីធានាបាននូវការអភិរក្ស និងមិនបង្កនូវផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលពីការអនុវត្តគម្រោង
- ពិគ្រោះយោបល់ជាមួយអាជ្ញាធរពាក់ព័ន្ធ ដូចជាអាជ្ញាធរអប្សរា អាជ្ញាធរព្រះវិហារ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីកំណត់ឱ្យបាននូវសារប្រយោជន៍នៃបេតិកភណ្ឌវប្បធម៌ ដោយធៀបទៅនឹងផលប្រយោជន៍ដែលទទួលបានពីគម្រោង
- បង្កើតឱ្យមានប្រព័ន្ធការពារបេតិកភណ្ឌវប្បធម៌ ដែលត្រូវបានប្រទះឃើញក្នុងអំឡុងពេលអនុវត្តគម្រោង
- ធានាថាប្រជាពលរដ្ឋក្នុងសហគមន៍អាចចូលរួមការពារទីតាំងបេតិកភណ្ឌវប្បធម៌ ដែលស្ថិតនៅក្នុងទីតាំងអនុវត្តគម្រោង
- ហាមឃាត់ដាច់ខាតនូវរាល់ការធ្វើឱ្យខូចខាត ឬធ្វើឱ្យបាត់បង់បេតិកភណ្ឌវប្បធម៌ លើកលែងតែក្នុងករណីដែលត្រូវបានអនុញ្ញាតដោយច្បាប់
- រាល់ការប្រើប្រាស់នូវបេតិកភណ្ឌអរូបីសម្រាប់ធ្វើការផ្សព្វផ្សាយ ត្រូវមានកិច្ចសហការជាមួយសហគមន៍ដែលពាក់ព័ន្ធ។

### ២.៩.២. ការអនុវត្តយុទ្ធសាស្ត្រទី៨ក្នុងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ

| ឧទាហរណ៍ផលប៉ះពាល់អវិជ្ជមានពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៨ |
| --- |
| • ការងារសាងសង់ធ្វើឱ្យខូចខាតទីតាំងដែលមានសារសំខាន់ផ្នែកវប្បធម៌ ដូចជាប្រាសាទបូរាណ<br>• កំណប់សម្ភារវប្បធម៌ (ដូចជា រូបសំណាកបូរាណ) ដែលរកឃើញក្នុងអំឡុងការសាងសង់ និងមិនបានថែរក្សាត្រឹមត្រូវ<br>• ការសាងសង់នៅក្បែរទីតាំងបេតិកភណ្ឌវប្បធម៌ដែលមានផលប៉ះពាល់ជាអវិជ្ជមានដោយប្រយោលដូចជា ៖<br>✓ សម្លេងប៉ះពាល់ដល់ទីតាំង<br>✓ ការបំពុលប៉ះពាល់ដល់ទីតាំង<br>✓ ការផ្លាស់ប្តូរភាពស្រស់ស្អាតនៃតំបន់<br>• គម្រោងប៉ះពាល់ជាអវិជ្ជមានដល់បេតិកភណ្ឌវប្បធម៌អរូបិយ។ |

គម្រោងដែលមានហានិភ័យពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៨ ត្រូវកំណត់តាមរយៈការពិនិត្យពិច័យ។

គម្រោងទាំងឡាយណាដែលមានផលប៉ះពាល់ដោយផ្ទាល់ដល់ទីកន្លែង ដែលជាតំបន់ការពារវប្បធម៌ (ដូចជាប្រាសាទបូរាណ) ត្រូវចាត់ទុកជាគម្រោងមានចំណាត់ថ្នាក់ **ក**។

សម្រាប់គម្រោងដែលមានចំណាត់ថ្នាក់ **ក** នៃយុទ្ធសាស្ត្រទី៨ រដ្ឋបាលថ្នាក់ក្រោមជាតិយត្រូវប្រឹក្សាយោបល់ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬអាជ្ញាធរពាក់ព័ន្ធផ្សេងទៀតដែលទទួលទទួលខុសត្រូវក្នុងការអភិរក្សតំបន់វប្បធម៌។

គម្រោងមានចំណាត់ថ្នាក់ **ខ** ពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌ ប្រសិនបើ ៖

- គម្រោងពាក់ព័ន្ធនឹងការសាងសង់ក្នុងចម្ងាយ៥០០ម៉ែត្រនៃតំបន់ការពារវប្បធម៌
- គម្រោងនឹងប៉ះពាល់ដល់កន្លែងដែលមានសារសំខាន់ផ្នែកវប្បធម៌សម្រាប់ប្រជាជនដែលរស់នៅក្បែរទីនោះ។

សម្រាប់គម្រោងមានចំណាត់ថ្នាក់ **ខ** ហានិភ័យត្រូវវាយតម្លៃនៅក្នុង ESIA និងវិធានការនានាសម្រាប់គ្រប់គ្រងហានិភ័យត្រូវបញ្ចូលនៅក្នុងផែនការ ESMP។

# ៣. ការអនុវត្តគោលនយោបាយយេនឌ័រដោយរដ្ឋបាលថ្នាក់ក្រោមជាតិ

## ៣.១. តម្រូវការនានានៃគោលនយោបាយយេនឌ័រ

គោលនយោបាយនេះមានគោលបំណងលើកកម្ពស់ និងពង្រឹងសមភាពយេនឌ័រក្នុងក្របខ័ណ្ឌអនុវត្តកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

គម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវអនុវត្តអោយស្របតាមគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គោលនយោបាយយេនឌ័រ) ជាពិសេសយុទ្ធសាស្ត្រទី៨នៃគោលនយោបាយយេនឌ័រ៖ រៀបចំកម្មវិធីគម្រោង ផែនការសកម្មភាព និងថវិកាដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ ដែលពាក់ព័ន្ធជាមួយការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ។

យុទ្ធសាស្ត្រនៃគោលនយោបាយយេនឌ័រពាក់ព័ន្ធនឹងគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ៖

- **យុទ្ធសាស្ត្រទី១ ៖** បង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង
- **យុទ្ធសាស្ត្រទី៨ ៖** រៀបចំកម្មវិធី គម្រោង ផែនការសកម្មភាព និងថវិកាដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ ដែលពាក់ព័ន្ធជាមួយការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- **យុទ្ធសាស្ត្រទី១០ ៖** លើកកម្ពស់ និងគាំទ្រការរៀបចំផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈឆ្លើយតបទៅនឹងយេនឌ័រ
- **យុទ្ធសាស្ត្រទី១១ ៖** លើកកម្ពស់ការវិភាជថវិកាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈឆ្លើយតបទៅនឹងយេនឌ័រ។

ក្នុងការអនុវត្តជាក់ស្តែង តម្រូវការនេះមានន័យថា ៖

- ស្ត្រីត្រូវមានតួនាទី និងមតិយោបល់ពេញលេញក្នុងការរៀបចំគម្រោង និងថវិកា
- ផែនការ និងគម្រោងថវិកាត្រូវផ្តល់អាទិភាពខ្ពស់ចំពោះគម្រោងដែលផ្តល់ផលប្រយោជន៍ដល់ស្ត្រី
- ស្ត្រីត្រូវចូលរួមយ៉ាងសកម្មក្នុងការពិភាក្សាអំពីភាគីពាក់ព័ន្ធសម្រាប់រៀបចំគ្រោងការគម្រោង
- តម្រូវការនានារបស់ស្ត្រី ត្រូវបានយកចិត្តទុកដាក់ក្នុងការរៀបចំប្លង់គម្រោង (ឧទាហរណ៍៖គម្រោងផ្គត់ផ្គង់ទឹកស្អាត ស្ត្រីត្រូវបានប្រឹក្សាយោបល់អំពីទីតាំងសមស្របក្នុងការសាងសង់អណ្តូង ឬចំណុចទឹក)
- គណៈកម្មការគ្រប់គ្រងត្រូវមានស្ត្រីជាសមាជិក
- ស្ត្រីត្រូវមានឱកាសស្មើគ្នាក្នុងការទទួលបានការងារ និងចូលរួមជាអ្នកទទួលការក្នុងការអនុវត្តគម្រោង
- ស្ត្រីត្រូវទទួលបានប្រាក់ឈ្នួលស្មើនឹងបុរសសម្រាប់ការងារដូចគ្នា។

## ៣.២. គម្រោងវិជ្ជមានយេនឌ័រ

គម្រោងមានលក្ខណៈវិជ្ជមានចំពោះយេនឌ័រ គឺជាគម្រោងដែលលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី ស្របជាមួយនឹងគោលនយោបាយយេនឌ័រ។

គម្រោងមានលក្ខណៈវិជ្ជមានចំពោះយេនឌ័រ ត្រូវបញ្ជ្រាបយេនឌ័រនៅក្នុងដំណាក់កាលនីមួយៗនៃការកសាងផែនការ ការរៀបចំ និងការអនុវត្តគម្រោង។ មានលក្ខណៈវិនិច្ឆ័យចំនួន៥ សម្រាប់កំណត់គម្រោងមានលក្ខណៈវិជ្ជមានចំពោះយេនឌ័រ ៖

| | |
|---|---|
| **ការកសាងផែនការ** | • ស្ត្រីចូលរួមក្នុងការជ្រើសរើសគម្រោង<br>• ជ្រើសរើសគម្រោងដែលមានអាទិភាពខ្ពស់សម្រាប់ស្ត្រីក្នុងសហគមន៍ |
| **ការរៀបចំប្លង់គម្រោង** | • ស្ត្រីត្រូវបានប្រឹក្សាយោបល់អំពីគ្រោងការលម្អិតរបស់គម្រោង<br>• គ្រោងការលម្អិតរបស់គម្រោងរួមបញ្ចូលទិដ្ឋភាពជាក់លាក់ដែលឆ្លើយតបនឹងតម្រូវការស្ត្រី |
| **ផលប្រយោជន៍** | • ភាគរយស្ត្រីជាអ្នកទទួលផលមានចំនួនច្រើន<br>• ផលប្រយោជន៍សម្រាប់ស្ត្រីត្រូវបានកំណត់ច្បាស់លាស់ |

| | | |
|---|---|---|
| **ការដឹកនាំ** | • | គណៈកម្មការគ្រប់គ្រងគម្រោងមានស្ត្រីយ៉ាងតិច៤០% |
| | • | គណៈកម្មការគ្រប់គ្រងគម្រោងមានស្ត្រីកាន់មុខតំណែងដឹកនាំ |
| **ឱកាសនានា** | • | គម្រោងបង្កើតឱកាសផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រីដូចជា តាមរយៈការផ្តល់ការងារ ឬបង្កើតឱកាសថ្មីៗសម្រាប់ស្ត្រី ដើម្បីលើកកម្ពស់ជីវភាព តាមរយៈមុខរបរខ្នាតតូច។ |

## ៣.៧. ការពិនិត្យពិច័យយេនឌ័រ

ការពិនិត្យពិច័យយេនឌ័រ ត្រូវអនុវត្តសម្រាប់គម្រោងវិនិយោគទាំងអស់។ ការពិនិត្យពិច័យយេនឌ័រត្រូវអនុវត្ត ដោយប្រើប្រាស់ទម្រង់ការពិនិត្យពិច័យយេនឌ័រ។ លទ្ធផលនៃការពិនិត្យពិច័យយេនឌ័រ គឺជាពិន្ទុយេនឌ័រសម្រាប់គម្រោង។

សំណួរក្នុងទម្រង់ការពិនិត្យពិច័យយេនឌ័រមានលក្ខណៈសាមញ្ញ និងអាចឆ្លើយបានដោយគណៈកម្មការគ្រប់គ្រងគម្រោង។ សំណួរភាគច្រើនមានចម្លើយ បាទ ឬទេ។

កិច្ចដំណើរការការពិនិត្យពិច័យយេនឌ័រ ស្រដៀងគ្នានឹងកិច្ចដំណើរការការពិនិត្យពិច័យបរិស្ថាន និងសង្គម និងអាចអនុវត្តក្នុងពេលជាមួយគ្នា។ ទោះជាយ៉ាងណាក៏ដោយ យ៉ាងហោចត្រូវមានសមាជិក១រូបនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារចូលរួមការពិនិត្យពិច័យយេនឌ័រ។

ពិន្ទុយេនឌ័រត្រូវបានដាក់សម្រាប់សំណួរនីមួយៗនៅក្នុងទម្រង់ការពិនិត្យពិច័យយេនឌ័រ។ ក្នុងទម្រង់នេះមានសំណួរចំនួន១៣ ហើយសំណួរនីមួយៗអាចដាក់ពិន្ទុខ្ពស់បំផុត ៥ ឬ១០ពិន្ទុ។ ពិន្ទុសរុបខ្ពស់បំផុតគឺ ១០០ពិន្ទុ។

### ឧទាហរណ៍ ៖ ទម្រង់ការពិនិត្យពិច័យយេនឌ័រ

| ផ្នែក | សំណួរ | ចម្លើយ | ពិន្ទុ |
|---|---|---|---|
| **ការកសាងផែនការ** | តើតម្រូវការស្ត្រីត្រូវបានគិតគូរក្នុងការជ្រើសរើសគម្រោងឬទេ? | *បាទ* | បាទ = 5<br>*5* |
| | ក្នុងអំឡុងពេលនៃកសាងផែនការ តើក្រុមស្ត្រីត្រូវបានចូលរួមកំណត់អាទិភាពរបស់ស្ត្រីឬទេ? | *ទេ* | បាទ = 5<br>0 |
| | តើគម្រោងមានអាទិភាពខ្ពស់សម្រាប់ស្ត្រីក្នុងសហគមន៍ឬទេ? | *បាទ* | បាទ = 10<br>10 |
| **ការរៀបចំ** | តើស្ត្រីដែលទទួលផលប្រយោជន៍ពីគម្រោងត្រូវបានប្រឹក្សាយោបល់ឬទេ (ដោយឡែកពីបុរស) ក្នុងពេលរៀបចំគម្រោង? | *ទេ* | បាទ = 10<br>0 |
| | តើគម្រោងបានពិភាក្សាក្នុងកិច្ចប្រជុំរបស់គណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារដែរឬទេ? | *បាទ* | បាទ = 5<br>5 |
| | តើការរៀបចំគម្រោងមានផ្នែកជាក់លាក់ ដើម្បីលើកកម្ពស់ផលប្រយោជន៍ស្ត្រីឬទេ? | *ទេ* | បាទ= 10<br>0 |
| **ផលប្រយោជន៍** | ភាគរយស្ត្រីដែលទទួលផលពីគម្រោង? | *50%* | >40% = 5 |

| ផ្នែក | សំណួរ | ចម្លើយ | ពិន្ទុ |
|---|---|---|---|
| | | | > 60% = 10<br>5 |
| | តើទម្រង់ព័ត៌មានគម្រោងបានរៀបរាប់ពីវិធីសាស្ត្រដែលស្ត្រីនឹងទទួលផលប្រយោជន៍ពីគម្រោងឬទេ? | *ទេ* | បាទ = 5<br>0 |
| **ការដឹកនាំ** | តើប្រធានគណៈកម្មការគ្រប់គ្រងគម្រោងជាស្ត្រី? | *ទេ* | បាទ = 10<br>10 |
| | តើសមាជិកគណៈកម្មការគ្រប់គម្រោងជាស្ត្រីមានយ៉ាងហោច ៤០%ឬទេ? | *បាទ* | បាទ= 5<br>5 |
| **ឱកាស** | តើស្ត្រីទទួលបានឱកាសការងារដោយសមភាពដូចបុរសសម្រាប់ការងារក្នុងគម្រោង និងទទួលប្រាក់បៀវត្សស្មើគ្នាដូចបុរសឬទេ? | *បាទ* | បាទ= 5<br>5 |
| | តើគម្រោងនឹងបង្កើតឱកាសការងារសម្រាប់ស្ត្រីឬទេ? | *ទេ* | បាទ = 10<br>0 |
| | តើគម្រោងនឹងបង្កើតឱកាសការងារសម្រាប់ស្ត្រីក្នុងអាជីវកម្មឬទេ? | *ទេ* | បាទ = 10<br>0 |
| | **ពិន្ទុយេនឌ័រ** | | (ខ្ពស់បំផុត= 100)<br>45 |

គម្រោងមានពិន្ទុយេនឌ័រចំនួន៦០ពិន្ទុ ឬច្រើនជាងនេះ ត្រូវចាត់ទុកជាគម្រោងវិជ្ជមានយេនឌ័រ។

ក្នុងពេលអនាគត លេខាធិការដ្ឋាន គ.ជ.អ.ប. អាចពិចារណា និងផ្តល់ការលើកទឹកចិត្តនានាដូចជាការផ្តល់ថវិកាបន្ថែមដល់ថ្នាក់ក្រោមជាតិដែលអនុវត្តគម្រោងវិជ្ជមានយេនឌ័រ។ ក្នុងករណីនេះ ពិន្ទុយេនឌ័រអាចពិនិត្យដោយ គ.ក.ស.ក. ក្រុង ស្រុក (សម្រាប់គម្រោងឃុំ សង្កាត់) ឬ គ.ក.ស.ក. រាជធានី ខេត្ត (សម្រាប់គម្រោងក្រុង ស្រុក ខណ្ឌ)។

ពិន្ទុយេនឌ័រទាបបំផុតដែលអាចទទួលយកបាន គឺ៣០ពិន្ទុ។ ក្នុងករណី ពិន្ទុយេនឌ័រមានចំនួនតិចជាង៣០ពិន្ទុ រដ្ឋបាលថ្នាក់ក្រោមជាតិពិចារណាក្នុងការកែសម្រួលគម្រោង ដើម្បីបង្កើនពិន្ទុយេនឌ័រ។

*(**សម្គាល់** ៖ សំណួរនៅក្នុងទម្រង់ការពិនិត្យពិច័យយេនឌ័រ ពិន្ទុដែលត្រូវផ្តល់គម្រោងវិជ្ជមានយេនឌ័រ និងពិន្ទុយេនឌ័រដែលអាចទទួលយកបានអាចពិនិត្យ និងកែសម្រួលបន្ទាប់ពីការសាកល្បង)។*

# ៤. សុវត្ថិភាពបរិស្ថាន និងយេនឌ័រក្នុងកិច្ចដំណើរការអនុវត្តគម្រោង

## ៤.១. ទិដ្ឋភាពទូទៅ

ផ្នែកខាងលើបង្ហាញពីគោលការណ៍នានាសម្រាប់ធ្វើសមាហរណកម្មគោលនយោបាយ ESS និងគោលនយោបាយយេនឌ័រក្នុងការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ផ្នែកទី៤នេះបរិយាយអំពីសកម្មភាពនានា ដែលត្រូវអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិតាមដំណាក់កាលនីមួយៗនៃកិច្ចដំណើរការអនុវត្តគម្រោង។

## ៤.២. ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងនៅពេលចាប់ផ្តើមនៃកិច្ចដំណើរការអនុវត្តគម្រោង។ តួនាទីសំខាន់របស់គណៈកម្មការគ្រប់គ្រងគម្រោងរួមមាន ៖

- គ្រប់គ្រងការសិក្សា និងការរៀបចំគម្រោង
- រៀបចំសំណើគម្រោងដោយមានការគាំទ្រពីមន្ត្រីបច្ចេកទេស
- ពិនិត្យ និងអនុម័តសំណើគម្រោង

សមាជិកភាពគណៈកម្មការគ្រប់គ្រងឃុំ សង្កាត់ (កំណត់ក្នុងសៀវភៅភីម) រួមមាន ៖

- មេឃុំ ចៅសង្កាត់ ជាប្រធាន
- ជំទប់ទី១ឃុំ សង្កាត់ ជាអនុប្រធាន
- សមាជិកគណៈកម្មការលទ្ធកម្មឃុំ សង្កាត់ ជាសមាជិក
- តំណាងអ្នកទទួលផល០១រូបពីភូមិនីមួយៗដែលទទួលផលពីគម្រោងជាសមាជិក។ ប្រសិនបើមានក្រុមអ្នកប្រើប្រាស់ ដើម្បីទទួលខុសត្រូវក្នុងកិច្ចប្រតិបត្តិការ និងថែរក្សាលទ្ធផលគម្រោង ត្រូវមានតំណាងមកពីក្រុមទាំងនេះ
- ស្មៀនឃុំ សង្កាត់ ជាលេខាធិការ

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធានាថា យ៉ាងហោច៤០%នៃសមាជិកគណៈកម្មការគ្រប់គ្រងគម្រោងជាស្ត្រី។ ជាគោលការណ៍ យ៉ាងតិចត្រូវមានសមាជិកគណៈកម្មការគ្រប់គ្រងគម្រោង០២រូបជាស្ត្រី។

គណៈកម្មការគ្រប់គ្រងគម្រោង ត្រូវមានសមាជិក០២រូបទទួលការបានបណ្តុះបណ្តាលអំពី ESS ។

## ៤.៣. ការពិនិត្យពិច័យសុវត្ថិភាពបរិស្ថាន និងសង្គម

### ចំណុចជាគន្លឹះនៃកិច្ចដំណើរការពិនិត្យពិច័យគោលនយោបាយ ESS

| | |
|---|---|
| **គម្រោងណាខ្លះ?** | គម្រោងវិនិយោគទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តការពិនិត្យពិច័យអំពីបរិស្ថាន និងសង្គម |
| **អ្នកណាខ្លះចូលរួម?** | រដ្ឋបាលថ្នាក់ក្រោមជាតិ និងគណៈកម្មការគ្រប់គ្រងគម្រោង រួមជាមួយនឹងប្រជាជនមូលដ្ឋានដែលស្គាល់ច្បាស់ពីទីតាំងគម្រោង |
| **ត្រូវធ្វើអ្វីខ្លះ?** | បញ្ជាក់គម្រោងមានចំណាត់ថ្នាក់ ក ខ ឬ គ<br>កំណត់ការសិក្សាដែលត្រូវអនុវត្តបន្ត |
| **នៅពេលណា?** | នៅពេលចាប់ផ្តើមការរៀបចំគម្រោង<br>ប្រសិនបើប្លង់គម្រោងមានការផ្លាស់ប្តូរច្រើន ត្រូវពិនិត្យពិច័យឡើងវិញ |
| **នៅឯណា?** | នៅទីតាំងគម្រោង |
| **យ៉ាងដូចម្តេច?** | ទម្រង់ការពិនិត្យពិច័យមានសំណួរចំនួន៣០។ សំណួរនីមួយៗមានចម្លើយ បាទ ឬទេ |

ទម្រង់ពិនិត្យពិច័យ ESS (ទម្រង់៣) ត្រូវបំពេញសម្រាប់គម្រោងទាំងអស់។ ទម្រង់៣ ត្រូវរៀបចំដោយគណៈកម្មការគ្រប់គ្រងគម្រោងជាមួយជំនួយការបច្ចេកទេស និងសមាជិកសហគមន៍មូលដ្ឋានដែលនឹងប៉ះពាល់ដោយសារគម្រោង។ ទម្រង់៣អាចរៀបចំក្នុងពេលដំណាលគ្នាជាមួយទម្រង់១៤ អំពីព័ត៌មានគម្រោងក្នុងពេលប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធនានា។

លទ្ធផលនៃការពិនិត្យពិច័យ ESS ក្នុងទម្រង់៣ នឹងត្រូវ ៖

- កំណត់ចំណាត់ថ្នាក់ហានិភ័យគម្រោងជា ចំណាត់ថ្នាក់ ក ខ ឬគ
- ប្រសិនបើគម្រោងមានចំណាត់ថ្នាក់ ក បង្ហាញពីស្ថាប័នដែលត្រូវទាក់ទង ដើម្បីអនុវត្តការសិក្សាអំពីផលប៉ះពាល់
- ប្រសិនបើគម្រោងមានចំណាត់ថ្នាក់ ខ បង្ហាញអំពីនីតិវិធីវាយតម្លៃផលប៉ះពាល់ ESS ដែលត្រូវអនុវត្តសម្រាប់ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ESMP.

ទម្រង់៣រួមមានសំណួរជាច្រើនដែលសំណួរនីមួយៗត្រូវឆ្លើយ បាទ ឬទេ។ សំណួរទាំងអស់មានលក្ខណៈសាមញ្ញ។ សំណួរដែលឆ្លើយថា បាទ មានន័យថា ត្រូវការសិក្សាបន្ថែម។

ទម្រង់៣បែងចែកជា២ផ្នែក។ ផ្នែកទី១មាន៥សំណួរ។ ប្រសិនបើមានសំណួរណាមួយក្នុងផ្នែកទី១នេះមានចម្លើយ បាទ គម្រោងត្រូវចាត់ចំនាត់ថ្នាក់ ក (ហានិភ័យខ្ពស់)។

ផ្នែកទី២មាន២៥សំណួរ។ ប្រសិនបើ មានសំណួរណាមួយក្នុងផ្នែកទី២នេះមានចម្លើយ បាទ (ប៉ុន្តែសំណួរផ្សេងទៀតមានចម្លើយ ទេ) នោះគម្រោងនេះត្រូវចាត់ចំណាត់ថ្នាក់ ខ (ហានិភ័យមធ្យម)។

ប្រសិនបើ គម្រោងមានចំណាត់ថ្នាក់ ក ឃុំ សង្កាត់ត្រូវអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម (ESIA) ដោយប្រើប្រាស់ទម្រង់ ១៩.១ និងរៀបចំផែនការ ESMP (ទម្រង់១៩.២)។ បើមានសំណួរណាមួយក្នុងផ្នែកទី២នៃទម្រង់៣មានចម្លើយ បាទ ត្រូវបំពេញព័ត៌មានក្នុងកូឡោនចុងក្រោយខាងស្តាំដៃ។

| | | |
|---|---|---|
| ៨. តើគ្រោងស្ថិតនៅក្នុងតំបន់នៃបញ្ជីឃ្លាំមើលជនជាតិដើមភាគតិចឬទេ? | ទេ | យុទ្ធសាស្ត្រទី៧ |
| ៩. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ក្នុងចម្ងាយ៥០០មនៃកន្លែងដែលជាតំបន់ការពារវប្បធម៌ឬទេ? | បាទ | យុទ្ធសាស្ត្រទី៨ |
| ១០. តើគម្រោងប៉ះពាល់កន្លែងដែលមានសារសំខាន់ផ្នែកវប្បធម៌សម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់នោះឬទេ? | ទេ | យុទ្ធសាស្ត្រទី៨ |

**ទម្រង់ ១៩.១ យុទ្ធសាស្ត្រទី៨ ៖ បេតិកភណ្ឌវប្បធម៌**

| បញ្ហា | កម្រិត | | ទីតាំងលើផែនទី |
|---|---|---|---|
| ការងារសាងសង់នឹងនាំឱ្យខូចខាតដោយផ្ទាល់ដល់បេតិកភណ្ឌវប្បធម៌ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ការងារសាងសង់នឹងនាំឱ្យខូចខាតដល់បេតិកភណ្ឌវប្បធម៌ដែលកប់ក្នុងដី (មិនបានដឹង) | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

ប្រសិនបើ សំណួរទាំងអស់ក្នុងផ្នែកទី១ និងផ្នែកទី២មានចម្លើយ ទេ គម្រោងមានចំណាត់ថ្នាក់ គ និងពុំតម្រូវឱ្យមានការសិក្សាវាយតម្លៃអំពីផលប៉ះពាល់បន្ថែមទេ។

ទម្រង់៣ ត្រូវរៀបចំដោយគណៈកម្មការគ្រប់គ្រងគម្រោងជាមួយជំនួយការបច្ចេកទេស និងសមាជិកសហគមន៍មូលដ្ឋាន ដែលនឹងប៉ះពាល់ដោយសារគម្រោង។ ទម្រង់៣អាចរៀបចំក្នុងពេលដំណាលគ្នាជាមួយទម្រង់១៤អំពីព័ត៌មានគម្រោងក្នុងពេលប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធនានា។

ទម្រង់៣ត្រូវពិនិត្យដោយទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត។ ប្រសិនបើ ទីចាត់ការផែនការ និងវិនិយោគយល់ឃើញថា ចម្លើយនានាក្នុងទម្រង់៣បំពេញមិនបានត្រឹមត្រូវ នោះទីចាត់ការអាចបន្តពិនិត្យលទ្ធផលនៃការពិនិត្យពិច័យ និងធ្វើការណែនាំឃុំ សង្កាត់ពាក់ព័ន្ធកែតម្រូវឱ្យបានសមស្រប។

**ទម្រង់ទី៣ ៖ ឧទាហរណ៍**

**ទម្រង់ទី៣ ៖ ការពិនិត្យពិច័យហានិភ័យបរិស្ថាន និងសង្គម**

| | |
|---|---|
| **រាជធានី ខេត្ត ៖** កំពង់ចាម | **រដ្ឋបាលឃុំ សង្កាត់ ៖** ឫស្សីស្រុក |
| **ក្រុង ស្រុក ខណ្ឌ ៖** ស្រីសន្ធរ | **កូដឃុំ សង្កាត់ ៖** ០៣១៤១១ |
| **ឈ្មោះគម្រោង ៖** ជួសជុលផ្លូវក្រាលគ្រួសក្រហមពីភូមិ ក ទៅភូមិ ខ ក្នុងឃុំ ឫស្សីស្រុក | |
| **សង្ខេបអំពីគម្រោង ៖** ជួសជុលផ្លូវក្រាលគ្រួសក្រហមប្រវែង២,៥ គ.ម សាងសង់លូមូលថ្មីចំនួន២ | |

ផ្នែកទី១ ត្រូវឆ្លើយសំណួរពីសំណួរទី១ដល់សំណួរទី៥។ ចម្លើយអាចជា បាទ ឬទេ។ ប្រសិនបើចម្លើយ **បាទ** គម្រោងត្រូវស្ថិតក្នុងហានិភ័យដែលមានចំណាត់ថ្នាក់ ក។ ក្នុងណីនេះ ម្ចាស់គម្រោងត្រូវទំនាក់ទំនងស្ថាប័នទទួលខុសត្រូវ ដើម្បីផ្តល់យោបល់សម្រាប់ការអនុវត្តបន្ត។

| **សំណួរ** | **បាទ/ ទេ** | **ស្ថាប័នទំនាក់ទំនង (ក្នុងករណីចម្លើយ បាទ)** |
|---|---|---|
| ១. តើមានផ្នែកណាមួយនៃគម្រោងដែលស្ថិតក្នុងតំបន់អភិរក្ស ឬតំបន់ស្នូលនៃតំបន់ការពារបរិស្ថានឬទេ? | ទេ | ក្រសួងបរិស្ថាន |
| ២. តើគម្រោងប៉ះពាល់ដោយផ្ទាល់ដល់កន្លែងការពារវប្បធម៌ (ដូចជាប្រាសាទបូរាណ) ឬទេ? | ទេ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ៣. តើគម្រោងតម្រូវឱ្យមានការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋច្រើនជាង១០គ្រួសារឬទេ? | ទេ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលំនៅដ្ឋាន) |
| ៤. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ប្រព័ន្ធធារាសាស្ត្រថ្មី ដើម្បីស្រោចស្រពផ្ទៃដីលើសពី១០០ហិតា ដែលមិនធ្លាប់ស្រោចស្រពកន្លងមកឬទេ? | ទេ | ក្រសួងធនធានទឹក និងឧតុនិយម |
| ៥. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ទំនប់ ឬអាងស្តុកទឹកដែលមានកម្ពស់លើសពី១៥ម (វាស់ពីបាតមកកំពូល) ឬទេ? | ទេ | ក្រសួងធនធានទឹក និងឧតុនិយម |

ផ្នែកទី២ ៖ ឆ្លើយសំណួរ ៦-៣០។ ចម្លើយអាច បាទ ឬទេ។ ក្នុងករណីមានចម្លើយណាមួយ បាទ (ប៉ុន្តែចម្លើយពីសំណួរទី១-៥ ទេ) នោះគម្រោងមានចំណាត់ថ្នាក់ ខ។ ដូច្នេះ ត្រូវមានការសិក្សាបន្ថែម ផ្អែកលើសំណួរ។ ប្រសិនបើ ចម្លើយពីសំណួរ ១-៥ និងសំណួរទាំងអស់ពី៦-៣០ ជា ទេ នោះគម្រោងមាន ចំណាត់ថ្នាក់ គ និងពុំចាំបាច់សិក្សាបន្ថែមទេ។

| សំណួរ | បាទ/ទេ | ការសិក្សាបន្តករណីចម្លើយ "បាទ" |
|---|---|---|
| ៦. ទីតាំងគ្រោងស្ថិតក្នុងបញ្ជីឃ្លាំមើលផ្នែកបរិស្ថានរបស់ គ.ជ.អ.ប. ឬទេ? | ទេ | យុទ្ធសាស្ត្រទី៦ |
| ៧. គម្រោងនឹងមានផលប៉ះពាល់ទាំងនេះឬទេ ៖<br>➢ ព្រៃធម្មជាតិ<br>➢ ព្រៃលិចទឹកធម្មជាតិ/ ព្រៃកោងកាង<br>➢ តំបន់ដីសើម<br>➢ តំបន់ព្រំប្រទល់ទឹកសាប-ទឹកប្រៃ | ទេ | យុទ្ធសាស្ត្រទី៦ |
| ៨. ទីតាំងគម្រោងស្ថិតក្នុងបញ្ជីឃ្លាំមើលផ្នែកជនជាតិដើមភាគតិចឬទេ? | ទេ | យុទ្ធសាស្ត្រទី៧ |
| ៩. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់នៅកន្លែងមានចម្ងាយ៥០០មនៃកន្លែងការពារវប្បធម៌ឬទេ? | បាទ | យុទ្ធសាស្ត្រទី៨ |
| ១០. តើគម្រោងប៉ះពាល់កន្លែងដែលមានសារៈសំខាន់ផ្នែកវប្បធម៌សម្រាប់ប្រជាពលរដ្ឋរស់នៅទីនោះឬទេ? | ទេ | យុទ្ធសាស្ត្រទី៨ |
| ១១. តើគម្រោងត្រូវការលទ្ធកម្មដីធ្លីរួមបញ្ចូលទាំងការបរិច្ចាគដីដោយស្ម័គ្រចិត្ត? | ទេ | យុទ្ធសាស្ត្រទី៥ |
| ១២. តើគម្រោងពាក់ព័ន្ធនឹងការសង់ផ្លូវថ្មីឬទេ? | ទេ | យុទ្ធសាស្ត្រទី៤,៥,៦ |
| ១៣. តើគម្រោងពាក់ព័ន្ធនឹងការកែលម្អ និងពង្រីកផ្លូវមានប្រវែងលើសពី១០ គ.ម ឬទេ? | ទេ | យុទ្ធសាស្ត្រទី៤,៥,៦ |
| ១៤. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ប្រព័ន្ធធារាសាស្ត្រថ្មី ដើម្បីស្រោចស្រពផ្ទៃដីតិចជាង១០០ហិតាដែលមិនធ្លាប់ស្រោចស្រពកន្លងមកឬទេ? | ទេ | យុទ្ធសាស្ត្រទី៣,៦ |
| ១៥. តើគម្រោងពាក់ព័ន្ធនឹងជួសជុល ឬកែលម្អប្រព័ន្ធធារាសាស្ត្រ ដើម្បីស្រោចស្រពផ្ទៃដីច្រើនជាង១០០ហិតាឬទេ? | ទេ | យុទ្ធសាស្ត្រទី៣,៦ |
| ១៦. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ ឬជួសជុលអាងស្តុកទឹកដែលមានផ្ទៃទឹកធំជាង១ហិតា(ទំនប់មានកម្ពស់ទាបជាង១៥ម) ឬទេ? | ទេ | យុទ្ធសាស្ត្រទី៣,៤,៦ |
| ១៧. តើគម្រោងតម្រូវឱ្យមានការសាងសង់ក្បែរផ្ទះប្រជាពលរដ្ឋ តូបលក់ដូរ សាលារៀន វត្តអារាម គ្លីនិក ឬកន្លែងមានមនុស្សច្រើនផ្សេងទៀត ឬនៅលើផ្លូវមានចរាចរច្រើនឬទេ? | បាទ | យុទ្ធសាស្ត្រទី៣,៤ |
| ១៨. តើគម្រោងតម្រូវឱ្យមានការសាងសង់ផ្លូវបង្វែរទឹកណាមួយ (កន្លែងដែលទឹកនឹងហូរនៅពេលសាងសង់ ដូចជាប្រឡាយទឹកកាត់ផ្លូវ) ឬទេ? | បាទ | យុទ្ធសាស្ត្រទី៣ |
| ១៩. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់រោងចក្រកែច្នៃផលិតផលកសិកម្មដែលមានសមត្ថភាពលើសពី១តោនក្នុង១ថ្ងៃឬទេ? | ទេ | យុទ្ធសាស្ត្រទី៣ |
| ២០. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ ឬកែលម្អកន្លែងចាក់កាកសំណល់រឹងឬទេ? | ទេ | យុទ្ធសាស្ត្រទី៣ |

| សំណួរ | បាទ/ទេ | ការសិក្សាបន្ត ករណីចម្លើយ "បាទ" |
|---|---|---|
| ២១. តើគម្រោងនឹងយកទឹកចេញលើសពី១០%នៃទឹកក្នុងអូរ ឬប្រឡាយដែលកំពុងមានបច្ចុប្បន្នឬទេ? | ទេ | យុទ្ធសាស្ត្រទី៣ |
| ២២. តើគម្រោងនឹងប៉ះពាល់ការផ្គត់ផ្គង់ទឹកប្រើប្រាស់ដោយគ្រួសារឬទេ? | ទេ | យុទ្ធសាស្ត្រទី៣ |
| ២៣. តើគម្រោងនឹងនាំឱ្យបំពុលប្រភពទឹកក្នុងរយៈពេលវែងឬទេ? | ទេ | យុទ្ធសាស្ត្រទី៣ |
| ២៤. តើគម្រោងនឹងក្លាយជាប្រភពកាកសំណល់រឹងដូចជា ប្លាស្ទិចក្នុងរយៈពេលវែងឬទេ? | ទេ | យុទ្ធសាស្ត្រទី៣ |
| ២៥. តើគម្រោងតម្រូវឱ្យមានការប្រើប្រាស់សារធាតុគីមីដែលមានគ្រោះថ្នាក់ឬទេ? | ទេ | យុទ្ធសាស្ត្រទី៣,៤ |
| ២៦. តើការអនុវត្តគម្រោងត្រូវការកម្លាំងពលកម្មលើសពី៥០នាក់ ឬកម្លាំងពលកម្មលើសពី១០នាក់ក្នុងរយៈពេល៣ខែឬទេ? | ទេ | យុទ្ធសាស្ត្រទី២ |
| ២៧. តើគម្រោងតម្រូវជួលសមាជិកសហគមន៍ ដើម្បីធ្វើការងារមានគ្រោះថ្នាក់ ដែលពួកគេមិនបានបណ្តុះបណ្តាលឬទេ? | ទេ | យុទ្ធសាស្ត្រទី២ |
| ២៨. តើគម្រោងពាក់ព័ន្ធនឹងការដាំដំណាំនៅលើដីដែលមិនធ្លាប់ប្រើប្រាស់សម្រាប់ការដាំដុះពីមុនឬទេ? | ទេ | យុទ្ធសាស្ត្រទី៦ |
| ២៩. តើគម្រោងពាក់ព័ន្ធនឹងការរៀបចំដីធ្លីដែលកំពុងប្រើប្រាស់សម្រាប់ដាំដំណាំបច្ចុប្បន្នដើម្បីប្រើប្រាស់សម្រាប់គោលបំណងផ្សេងឬទេ? | ទេ | យុទ្ធសាស្ត្រទី៦ |
| ៣០. តើគម្រោងស្ថិតនៅក្នុងតំបន់មានហានិភ័យខ្ពស់ដែលមានមីន និងសំណល់យុទ្ធភណ្ឌមិនទាន់ផ្ទុះឬទេ? | ទេ | យុទ្ធសាស្ត្រទី៤ |

ថ្ងៃ................ខែ.............ឆ្នាំ...........ព.ស.២៥៦...

.............ថ្ងៃទី............ខែ.............ឆ្នាំ២០....

មេឃុំ ចៅសង្កាត់

ថ្ងៃ.................ខែ.............ឆ្នាំ...........ព.ស.២៥៦...

............... ថ្ងៃទី.............ខែ...........ឆ្នាំ២០....

ជំនួយការបច្ចេកទេស

## ៩.៩. ការពិនិត្យពិច័យយេនឌ័រ

### ចំណុចជាគន្លឹះនៃកិច្ចដំណើរការពិនិត្យពិច័យយេនឌ័រ

| | |
|---|---|
| **គម្រោងណា?** | គម្រោងវិនិយោគទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តការពិនិត្យពិច័យយេនឌ័រ |
| **អ្នកទទួលខុសត្រូវ?** | រដ្ឋបាលថ្នាក់ក្រោមជាតិ និងគណៈកម្មការគ្រប់គ្រងគម្រោង រួមជាមួយនឹងប្រជាជនមូលដ្ឋានដែលស្គាល់ច្បាស់ពីទីតាំងគម្រោង។ យ៉ាងហោចណាស់ ត្រូវមានសមាជិក១រូបនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារចូលរួម។ |
| **ធ្វើអ្វីខ្លះ?** | គណនាពិន្ទុយេនឌ័រ<br>**បញ្ជាក់ ៖** តើគម្រោងមានពិន្ទុយេនឌ័រដែលអាចទទួលយកបានឬទេ?<br>**កំណត់ ៖** តើជាគម្រោងមានយេនឌ័រអវិជ្ជមានឬទេ? |

| | |
|---|---|
| **នៅពេលនា?** | នៅពេលចាប់ផ្ដើមការរៀបចំគម្រោង ប្រសិនបើ ប្លង់គម្រោងមានការផ្លាស់ប្ដូរច្រើន ត្រូវពិនិត្យពិច័យឡើងវិញ |
| **នៅឯណា?** | នៅទីតាំងគម្រោង |
| **យ៉ាងដូចម្ដេច?** | ទម្រង់ការពិនិត្យពិច័យមានសំណួរចំនួន១៣។ សំណួរនីមួយៗមានចម្លើយ បាទ ឬ ទេ។ |

## ៤.៤.១. កិច្ចដំណើរការពិនិត្យពិច័យយេនឌ័រ

ការពិនិត្យពិច័យយេនឌ័រ ត្រូវអនុវត្តចំពោះគម្រោងវិនិយោគទាំងអស់។ ការពិនិត្យពិច័យយេនឌ័រ ត្រូវអនុវត្តដោយប្រើប្រាស់ទម្រង់អំពីការពិនិត្យពិច័យយេនឌ័រ។ លទ្ធផលនៃការពិនិត្យពិច័យយេនឌ័រ គឺជាពិន្ទុយេនឌ័រសម្រាប់គម្រោងនោះ។

សំណួរក្នុងទម្រង់នៃការពិនិត្យពិច័យយេនឌ័រមានលក្ខណៈសាមញ្ញ និងអាចឆ្លើយបានដោយគណៈកម្មការគ្រប់គ្រងគម្រោង។ សំណួរភាគច្រើនមានចម្លើយ បាទ ឬទេ។

កិច្ចដំណើរការការពិនិត្យពិច័យយេនឌ័រ មានលក្ខណៈស្រដៀងគ្នានឹងកិច្ចដំណើរការការពិនិត្យពិច័យបរិស្ថាននិងសង្គម និងអាចអនុវត្តបានក្នុងពេលជាមួយគ្នា។ ទោះជាយ៉ាងណាក៏ដោយ យ៉ាងហោចណាស់ត្រូវមានសមាជិក១រូបនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារចូលរួមការពិនិត្យពិច័យយេនឌ័រ។

ពិន្ទុយេនឌ័រ ត្រូវបានដាក់សម្រាប់សំណួរនីមួយៗនៅក្នុងទម្រង់ការពិនិត្យពិច័យយេនឌ័រ។ ក្នុងទម្រង់នេះមានសំណួរចំនួន១៣ ហើយសំណួរនីមួយៗអាចដាក់ពិន្ទុខ្ពស់បំផុត៥ ឬ១០ពិន្ទុ។ ពិន្ទុសរុបខ្ពស់បំផុតគឺ១០០ពិន្ទុ។

ការពិនិត្យពិច័យយេនឌ័រ ត្រូវអនុវត្តសម្រាប់គម្រោងវិនិយោគទាំងអស់។ ការពិនិត្យពិច័យយេនឌ័រ ត្រូវអនុវត្តដោយប្រើប្រាស់ទម្រង់ការពិនិត្យពិច័យយេនឌ័រ។ លទ្ធផលនៃការពិនិត្យពិច័យយេនឌ័រ គឺជាពិន្ទុយេនឌ័រសម្រាប់គម្រោងនោះ។

### ឧទាហរណ៍ការពិនិត្យពិច័យយេនឌ័រ

| ផ្នែក | សំណួរ | មម្លើយ | ពិន្ទុ |
|---|---|---|---|
| **ការកសាងផែនការ** | តើតម្រូវការស្ត្រីត្រូវបានគិតគូរក្នុងការជ្រើសរើសគម្រោងឬទេ? | បាទ | បាទ = 5<br>*5* |
| | ក្នុងអំឡុងពេលនៃការកសាងផែនការ តើក្រុមស្ត្រីត្រូវបានចូលរួមកំណត់អាទិភាពរបស់ស្ត្រីឬទេ? | ទេ | បាទ = 5<br>*0* |
| | តើគម្រោងមានអាទិភាពខ្ពស់សម្រាប់ស្ត្រីក្នុងសហគមន៍ឬទេ? | បាទ | បាទ = 10<br>*10* |
| **ការរៀបចំ** | តើស្ត្រីដែលទទួលផលប្រយោជន៍ពីគម្រោងត្រូវបានប្រឹក្សាយោបល់ឬទេ (ដោយឡែកពីបុរស) ក្នុងពេលរៀបចំគម្រោង? | ទេ | បាទ = 10<br>*0* |
| | តើគម្រោងបានពិភាក្សាក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារដែរឬទេ? | បាទ | បាទ = 5<br>*5* |

| ផ្នែក | សំណួរ | មន្ត្រីយ | ពិន្ទុ |
|---|---|---|---|
| | តើការរៀបចំគម្រោងមានផ្នែកជាក់លាក់ដើម្បីលើកកម្ពស់ផលប្រយោជន៍ស្ត្រីឬទេ? | ទេ | បាទ= 10<br>*0* |
| **ផលប្រយោជន៍** | ភាគរយស្ត្រីទទួលផលពីគម្រោង? | *50%* | >40% = 5<br>> 60% = 10<br>*5* |
| | តើទម្រង់ព័ត៌មានគម្រោងរៀបរាប់ពីវិធីសាស្ត្រនានាដែលស្ត្រីនឹងទទួលផលប្រយោជន៍ពីគម្រោងឬទេ? | ទេ | បាទ= 5<br>*0* |
| **ការដឹកនាំ** | ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងជាស្ត្រី? | ទេ | បាទ = 10<br>*10* |
| | តើមានសមាជិកគណៈកម្មការគ្រប់គម្រោងជាស្ត្រីមានយ៉ាងហោច៤០%ឬទេ? | បាទ | បាទ= 5<br>*5* |
| **ឱកាស** | តើស្ត្រីទទួលបានឱកាសការងារដោយសមភាពដូចបុរសសម្រាប់ការងារក្នុងគម្រោង និងទទួលប្រាក់បៀវត្សរ៍ស្មើគ្នាដូចបុរសឬទេ? | បាទ | បាទ = 5<br>*5* |
| | តើគម្រោងនឹងបង្កើតឱកាសការងារសម្រាប់ស្ត្រីឬទេ? | ទេ | បាទ = 10<br>*0* |
| | តើគម្រោងនឹងបង្កើតឱកាសការងារសម្រាប់ស្ត្រីក្នុងអាជីវកម្មឬទេ? | ទេ | បាទ= 10<br>*0* |
| | **ពិន្ទុយេនឌ័រ** | | (ខ្ពស់បំផុត= 100)<br>*45* |

គម្រោងមានពិន្ទុយេនឌ័រចំនួន៦០ពិន្ទុ ឬច្រើនជាងនេះ ត្រូវបានចាត់ទុកជាគម្រោងវិជ្ជមានយេនឌ័រ។

ក្នុងពេលអនាគត លេខាធិការដ្ឋាន គ.ជ.អ.ប. អាចពិចារណា និងផ្តល់ការលើកទឹកចិត្តនានាដូចជាការផ្តល់ថវិកាបន្ថែមសម្រាប់ថ្នាក់ក្រោមជាតិដែលអនុវត្តគម្រោងវិជ្ជមានយេនឌ័រ។ ក្នុងករណីនេះ ពិន្ទុយេនឌ័រអាចពិនិត្យដោយ គ.ក.ស.ក. ក្រុង ស្រុក (សម្រាប់គម្រោងឃុំ សង្កាត់) ឬគ.ក.ស.ក. រាជធានី ខេត្ត (សម្រាប់គម្រោងក្រុង ស្រុក ខណ្ឌ)។

ពិន្ទុយេនឌ័រទាបបំផុតដែលអាចទទួលយកបាន គឺ៣០ពិន្ទុ។ ប្រសិនបើ ពិន្ទុយេនឌ័រមានចំនួនតិចជាង៣០ពិន្ទុ រដ្ឋបាលថ្នាក់ក្រោមជាតិពិចារណាក្នុងការកែសម្រួលគម្រោង ដើម្បីបង្កើនពិន្ទុយេនឌ័រ។

### ៤.៤.២. ការតាមដានការពិនិត្យពិច័យយេនឌ័រ

បន្ទាប់ពីការពិនិត្យពិច័យយេនឌ័រត្រូវបានបញ្ចប់ គណៈកម្មការគ្រប់គ្រងគម្រោងត្រូវពិនិត្យលទ្ធផលនៃការពិនិត្យពិច័យគម្រោងជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ។

ក្នុងករណីពិន្ទុយេនឌ័រមានចំនួនតិចជាង៣០ពិន្ទុ គណៈកម្មការគ្រប់គ្រងគម្រោងត្រូវរកមធ្យោបាយដើម្បីបង្កើនពិន្ទុយេនឌ័រឱ្យបានយ៉ាងហោចណាស់៣០ពិន្ទុ។

ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើគម្រោងមានពិន្ទុយេនឌ័រមានច្រើនជាង៣០ពិន្ទុហើយក៏ដោយក៏គណៈកម្មការគ្រប់គ្រងគម្រោង និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ត្រូវសិក្សា និងពិនិត្យមើលអំពីមធ្យោបាយនានា ដើម្បីបង្កើនពិន្ទុយេនឌ័របន្ថែមទៀតដូចជា ការបង្កើនពិន្ទុយេនឌ័រតាមរយៈ ៖

- ការរៀបចំកិច្ចប្រជុំជាមួយស្ត្រីជាអ្នកទទួលផលពីគម្រោង ដើម្បីធានាឱ្យស្ត្រីអាចទទួលផលប្រយោជន៍ពីគម្រោងបានកាន់តែច្រើន
- ការពិភាក្សាជាមួយមន្ត្រីគាំទ្របច្ចេកទេស ឬវិស្វករគម្រោង ដើម្បីកែសម្រួលប្លង់គម្រោងឱ្យមានលក្ខណៈសមស្របចំពោះស្ត្រី
- ការបង្កើនចំនួនស្ត្រីក្នុងគណៈកម្មការគ្រប់គ្រងគម្រោង។ល។

## ៩.៥. ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម

**ចំណុចជាគន្លឹះនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម (ESIA)**

| | |
|---|---|
| គម្រោងមួយណា? | គម្រោងដែលមានចំណាត់ថ្នាក់ ខ ដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី២ ទី៣ ទី៤ ទី៦ និង/ឬ ទី៨នៃគោលនយោបាយ ESS |
| អ្នកទទួលខុសត្រូវ? | ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>មន្ត្រីបច្ចេកទេស<br>ប្រជាជនប៉ះពាល់ដោយសារគម្រោង |
| ធ្វើអ្វីខ្លះ? | កំណត់ហានិភ័យបរិស្ថាន និងសង្គម |
| នៅពេលណា? | បន្ទាប់ពីការសិក្សាបច្ចេកទេសសម្រាប់គម្រោង |
| នៅទីណា? | នៅទីតាំងគម្រោង |
| ធ្វើដូចម្ដេច? | ទម្រង់១៩.១ នៃ ESIA មានផ្នែកដោយឡែកសម្រាប់យុទ្ធសាស្ត្រ ESS នីមួយៗ<br>ផែនទីបរិស្ថាន និងសង្គម |

### ៩.៥.១. អំពីការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម

ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវអនុវត្តដោយមានការចូលរួមពីប្រជាជនមូលដ្ឋាន និងផ្អែកជាសំខាន់លើចំណេះដឹងមូលដ្ឋានអំពីទីតាំងគម្រោង និងតម្រូវការរបស់ពួកគាត់។

ការវាយតម្លៃ ESIA ត្រូវអនុវត្តចំពោះគម្រោងទាំងអស់ដែលមានចំណាត់ថ្នាក់ ខ បន្ទាប់ពីការពិនិត្យពិច័យ ដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រណាមួយនៃ ESS ដូចខាងក្រោម ៖

- **យុទ្ធសាស្ត្រទី២ ៖** ពលកម្ម និងលក្ខខណ្ឌការងារ។

- **យុទ្ធសាស្ត្រទី៣ ៖** ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន។
- **យុទ្ធសាស្ត្រទី៤ ៖** សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍។
- **យុទ្ធសាស្ត្រទី៦ ៖** ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព។
- **យុទ្ធសាស្ត្រទី៨ ៖** បរតិកកណ្ឌវប្បធម៌។

សម្រាប់យុទ្ធសាស្ត្រទី២ ទី៣ ទី៤ ទី៦ និងទី៨ ការវាយតម្លៃផលប៉ះពាល់បរិសស្ថាន និងសង្គម ត្រូវប្រើប្រាស់នីតិវិធីមួយ និងក្នុងទម្រង់តែមួយ។

ចំពោះគម្រោងទាំងឡាយដែលមានចំណាត់ថ្នាក់ ខ និងមានការពាក់ព័ន្ធជាមួយនឹងយុទ្ធសាស្ត្រទី៥ស្តីពីលទ្ធកម្មដីធ្លី និងការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្ត ត្រូវអនុវត្តតាមកិច្ចដំណើរការដោយឡែកសម្រាប់ការរៀបចំរបាយការណ៍លទ្ធកម្មដីធ្លី។

គម្រោងទាំងឡាយដែលមានផលប៉ះពាល់ជាអវិជ្ជមានដល់ជនជាតិដើមភាគតិច (យុទ្ធសាស្ត្រទី៧) ត្រូវអនុវត្តតាមកិច្ចដំណើរការដោយឡែកសម្រាប់ការរៀបចំរបាយការណ៍ជនជាតិដើមភាគតិច។

គម្រោងទាំងឡាយដែលមានចំណាត់ថ្នាក់ គ (ហានិភ័យបរិស្ថាន និងសង្គមមានកម្រិតទាប) ពុំចាំបាច់អនុវត្ត ESIA ទេ។

### ៤.៥.២. អ្នកទទួលខុសត្រូវសម្រាប់ ESIA

មន្ត្រីទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ទទួលខុសត្រូវក្នុងការអនុវត្ត ESIA ដោយមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋានដែលទទួលផលប៉ះពាល់ពីគម្រោង។ ប្រជាជនផ្សេងទៀត ក៏ត្រូវលើកទឹកចិត្តឱ្យចូលរួមក្នុងការអនុវត្ត ESIA នេះដែរ។ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុង ESIA ត្រូវមានតំណាងមកពីក្រុមនានា ដូចជា ក្រុមយុវជន ចាស់ជរា កសិករ ស្ត្រី ព្រះសង្ឃ។ល។

ចំពោះគម្រោងទាំងឡាយណា ដែលស្ថិតនៅក្នុងបញ្ជីនៃតំបន់មានភាពងាយរងគ្រោះចំពោះផលប៉ះពាល់បរិស្ថាន ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវចុះពិនិត្យដល់ទីតាំងគម្រោង និងផ្តល់ការណែនាំក្នុងការអនុវត្ត ESIA និងការរៀបចំផែនការ ESMP។

### ៤.៥.៣. ទីកន្លែងអនុវត្ត ESIA

ESIA ត្រូវអនុវត្តនៅទីតាំងគម្រោង ឬក្បែរទីតាំងគម្រោង ជាកន្លែងដែលមានភាពងាយស្រួលសម្រាប់ប្រជាជនចូលរួមកិច្ចប្រជុំ និងអនុវត្ត។

### ៤.៥.៤. ការផ្សព្វផ្សាយអំពីគម្រោងជូនប្រជាជន

ដំហានទីមួយនៃកិច្ចប្រជុំ ESIA គឺការផ្សព្វផ្សាយព័ត៌មានអំពីគម្រោង ដើម្បីឱ្យប្រជាជនយល់ដឹងច្បាស់លាស់អំពីគម្រោងនេះមានដូចជា ៖

- សមិទ្ធផលគម្រោង

- ការអនុវត្តគម្រោង
- លទ្ធផលរំពឹងទុកពីគម្រោង
- មូលហេតុសំខាន់ៗដែលតម្រូវឱ្យអនុវត្ត ESIA សម្រាប់គម្រោង
- លទ្ធផលនៃ ESIA ដែលជាផែនការ ESMP។ ផែនការនេះអាចផ្លាស់ប្តូរបាន មុននឹងត្រូវរៀបចំបញ្ចប់ និងអនុវត្ត។

### ៤.៥.៥. ផែនទីបរិស្ថាន និងសង្គម

បន្ទាប់ពីការផ្សព្វផ្សាយអំពីគម្រោងជូនប្រជាជន ត្រូវរៀបចំផែនទីបរិស្ថាន និងសង្គម នៃគម្រោងជាមួយប្រជាជន។ ផែនការនេះត្រូវរៀបចំផ្អែកលើផែនទីគម្រោងនៅក្នុងទម្រង់ព័ត៌មានគម្រោង។

កិច្ចដំណើរការក្នុងការរៀបចំផែនទីបរិស្ថាន និងសង្គមរបស់គម្រោងមានដូចខាងក្រោម ៖

- គូរផែនទីគម្រោងនៅលើក្រដាសផ្ទាំងធំ ដើម្បីឱ្យប្រជាជនងាចមើលឃើញ និងចូលរួមផ្តល់យោបល់
- ពិភាក្សាជាមួយប្រជាជន ដើម្បីបញ្ចូលព័ត៌មានសំខាន់ៗនៅក្នុងផែនទី
- ចម្លងផែនទីទៅក្នុងក្រដាស A4 ដើម្បីភ្ជាប់ជាមួយផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។

ព័ត៌មានសំខាន់នៅលើផែនទីរួមមាន ៖

១. ភូមិសាស្ត្រដី ៖ ជម្រាល តំបន់រាប
២. ប្រភេទដី ៖ សំណឹកខ្លាំង សំណឹកតិច និងគ្មានសំណឹក
៣. តំបន់បៃតង និងការប្រើប្រាស់ដី ជាពិសេសតំបន់ព្រៃ និងតំបន់ដីសើម
៤. តំបន់មានសារសំខាន់ផ្នែកវប្បធម៌
៥. ផ្លូវដែលអាចចូលទៅការដ្ឋាន
៦. ប្រភពទឹក
៧. កម្រិតទឹកជំនន់នៅលើផ្លូវ
៨. តំបន់លំនៅដ្ឋាន និងប្រភពទឹកសម្រាប់ប្រើប្រាស់
៩. តំបន់ការពារ
១០. តំបន់ដីរេចរឹល
១១. តំបន់ជនជាតិដើមភាគតិច

**ការប្រើប្រាស់និមិត្តសញ្ញានៅលើផែនទី**

| និមិត្តសញ្ញា | អត្ថន័យ |
|---|---|
|  | ជម្រាលចោត (លើសពី៥%) |
|  | ជំរាល (តិចជាង៥%) |
|  | សំណឹក |

| | |
|---|---|
|  | វាលស្រែ |
|  | ចំការសម្រាប់ដំណាំប្រចាំឆ្នាំ |
|  | ដើមឈើហូបផ្លែ |
|  | វាលស្មៅ |
|  | ព្រៃបម្រុងទុក |
|  | ព្រៃរបោះដែលមានដើមឈើខ្ពស់ៗ |
|  | ផ្ទះ |
|  | មានទឹកពេញមួយឆ្នាំ |
|  | ពុំមានទឹកពេញមួយឆ្នាំ |
|  | ទីកន្លែងវប្បធម៌ |
|  | ផ្លូវអាចទៅដល់ការដ្ឋាន |
|  | តំបន់ការពារកំណត់ដោយថ្នាក់ជាតិ និងថ្នាក់ខេត្ត |
|  | តំបន់ជីវចម្រុះកំណត់ដោយក្រសួងបរិស្ថាន |
|  | តំបន់ជនជាតិដើមភាគតិច |

ផែនទីបរិស្ថាន និងសង្គម (ឧទាហរណ៍)




## ៤.៥.៦. ការបំពេញទម្រង់វាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម

បន្ទាប់ពីការគូរផែនទីបរិស្ថាន និងសង្គម ត្រូវអនុវត្ត ESIA ជាមួយប្រជាពលរដ្ឋ ដោយប្រើប្រាស់ទម្រង់ ១៩.១។ ព័ត៌មានសំខាន់ក្នុងទម្រង់ ១៩.១ រួមមាន ៖

- ព័ត៌មានទូទៅអំពីគម្រោង
- ផលប៉ះពាល់នៃពលកម្ម និងលក្ខខណ្ឌការងារ (សម្រាប់គម្រោងទាំងឡាយដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី២ស្តីពីពលកម្ម និងលក្ខខណ្ឌការងារ)
- ប្រសិទ្ធភាពធនធាន និងការគ្រប់គ្រងការបំពុលបរិស្ថាន (សម្រាប់គម្រោងទាំងឡាយដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៣ស្តីពីប្រសិទ្ធភាពធនធាន និងការគ្រប់គ្រងការបំពុលបរិស្ថាន)
- សុខភាព សុវត្ថិភាព និងសុខុមាលភាព (សម្រាប់គម្រោងទាំងឡាយដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៤ស្តីពីសុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍)
- ជីវចម្រុះ និងធនធានធម្មជាតិមានជីវិត (សម្រាប់គម្រោងទាំងឡាយដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៦ស្តីពី ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព)
- បេតិកភណ្ឌវប្បធម៌ (សម្រាប់គម្រោងទាំងឡាយដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៨ស្តីពីបេតិកភណ្ឌវប្បធម៌)
- អនុសាសន៍ចុងក្រោយ (គម្រោងទាំងអស់)។

ផ្នែកនីមួយៗនៃទម្រង់១៩.១ ជាបញ្ជីនៃប្រភេទផលប៉ះពាល់ដែលមានសក្តានុពលផ្នែកបរិស្ថាន និងសង្គមពាក់ព័ន្ធនឹងការអនុវត្តគម្រោង។ ផ្នែកមួយចំនួនបែងចែកជាផលប៉ះពាល់រយៈពេលវែង និងផលប៉ះ

ពាល់រយៈពេលខ្លី។

សម្រាប់បញ្ហានីមួយៗដែលមានក្នុងបញ្ជីនេះ មន្ត្រីទទួលខុសត្រូវ ត្រូវពន្យល់អំពីអត្ថន័យ និងឯកភាពជាមួយប្រជាជនមូលដ្ឋានប្រសិនបើបញ្ហាទាំងនេះកើតមានឡើង។ ការពិភាក្សា និងឯកភាពគ្នាត្រូវផ្ដោតលើការចាត់ចំណាត់ថ្នាក់ផលប៉ះពាល់ ខ្លាំង ឬមធ្យម ឬទាប ឬពុំមាន។

អត្ថន័យជាក់ស្ដែងនៃផលប៉ះពាល់ខ្លាំង ឬផលប៉ះពាល់មធ្យម អាស្រ័យលើទស្សនៈរបស់ប្រជាជនមូលដ្ឋានអំពីកម្រិតនៃផលប៉ះពាល់ដែលអាចទទួលយកបាន។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅផលប៉ះពាល់ខ្លាំងជាផលប៉ះពាល់មិនអាចទទួលយកបាន។ ក្នុងករណីមានបញ្ហាណាមួយត្រូវបានកំណត់ថាមាន ផលប៉ះពាល់ខ្លាំង ចាំបាច់ត្រូវកំណត់វិធានការគ្រប់គ្រងហានិភ័យ ដើម្បីកាត់បន្ថយផលប៉ះពាល់នោះមកក្នុង កម្រិតមធ្យម ។ កិច្ចការនេះ ត្រូវធ្វើឡើងក្នុងជំហានបន្ទាប់ តាមរយៈការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។

ចំពោះបញ្ហានានាដែលបានកំណត់ថា មានផលប៉ះពាល់ខ្លាំង ឬផលប៉ះពាល់មធ្យម កន្លែងដែលមានផលប៉ះពាល់នោះត្រូវកំណត់នៅក្នុងផែនទី។ កន្លែងនីមួយៗត្រូវដាក់សម្គាល់ដោយដាក់ជាអក្សរ ឬជាលេខ។ ឧទាហរណ៍ ការខូចខាតដែលបណ្ដាលមកពីការកាយដី (ការជីក) នៅកន្លែង ក ឬកន្លែង ខ ។ ក្នុងករណីនេះ ត្រូវសរសេរ ក ឬ ខ នៅក្នុងកូឡោនចុងក្រោយគេនៃបញ្ជីវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម និងកំណត់សម្គាល់កន្លែងនោះជា ក ឬ ខ នៅផែនទីបរិស្ថាន។

| | |
|---|---|
| **រាជធានី ខេត្ត ៖** កំពង់ចាម | **រដ្ឋបាលឃុំ សង្កាត់ ៖** ឫស្សីស្រុក |
| **ក្រុង ស្រុក ខណ្ឌ ៖** ស្រីសន្ធរ | **កូដឃុំ សង្កាត់ ៖** ០៣១៤១១ |
| **ឈ្មោះគម្រោង ៖** ជួសជុលផ្លូវក្រាលគ្រួសក្រហមពីភូមិ ក ទៅភូមិ ខ ក្នុងឃុំ ឫស្សីស្រុក | |
| **សង្ខេបអំពីគម្រោង ៖** ជួសជុលផ្លូវក្រាលគ្រួសក្រហមប្រវែង២,៥ គ.ម សាងសង់លូថ្មីចំនួន២ | |
| **កាលបរិច្ឆេទនៃការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម**<br>០១/០២/២០២... | **មន្ត្រីទទួលបន្ទុកការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម** AA<br>(ទីចាត់ការផែនការ និងវិនិយោគ) |
| **ទីតាំងវិភាគ**<br>ភូមិ ក និងដើរវិភាគនៅលើផ្លូវ | **ចំនួនប្រជាពលរដ្ឋចូលរួម ៖**<br>២៥ |

## ការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គមដែលត្រូវការ (ផ្អែកលើទម្រង់ទី៣)

| យុទ្ធសាស្ត្របរិស្ថាន និងសង្គម | បាទ / ទេ |
|---|---|
| យុទ្ធសាស្ត្រទី២ ៖ ពលកម្ម និងលក្ខខណ្ឌការងារ | ទេ |
| យុទ្ធសាស្ត្រទី៣ ៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន | បាទ |
| យុទ្ធសាស្ត្រទី៤ ៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍ | ទេ |
| យុទ្ធសាស្ត្រទី៦ ៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព | ទេ |
| យុទ្ធសាស្ត្រទី៨ ៖ បេតិកភណ្ឌវប្បធម៌ | ទេ |

## យុទ្ធសាស្ត្រទី២ ៖ ពលកម្ម និងលក្ខខណ្ឌការងារ

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| អ្នកទទួលការមិនមានយុត្តិធម៌សម្រាប់កម្មករដែលជួលពីសហគមន៍មូលដ្ឋាន | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| អ្នកទទួលការមិនផ្តល់ឱកាសស្មើគ្នា និងប្រាក់ខែស្មើគ្នាចំពោះការងារដូចគ្នាដល់ស្ត្រី ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិច | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| អ្នកទទួលការមិនផ្តល់លក្ខខណ្ឌការងារដែលមានសុខភាព និងសុវត្ថិភាពដល់កម្មករ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| អ្នកទទួលការយកកម្មករច្រើននាក់មកពីខាងក្រៅ។ កម្មករទាំងនោះមិនមានកន្លែងរស់នៅល្អ និងមានអនាម័យដែលនាំឱ្យមានការបំពុលបរិស្ថាន | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| អ្នកទទួលការយកកម្មករច្រើនមកពីខាងក្រៅ និងនាំឱ្យមានបញ្ហាជាមួយសហគមន៍មូលដ្ឋាន។ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## យុទ្ធសាស្ត្រទី៣ ៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន

### ផលប៉ះពាល់រយៈពេលវែងបង្កដោយគម្រោង

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| ផលប៉ះពាល់ខ្លាំងក្លាលើអ្នកប្រើប្រាស់ទឹកដោយសារទាញយកទឹកមកប្រើប្រាស់ច្រើនហួសកម្រិតកំណត់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ផលប៉ះពាល់ខ្លាំងក្លាលើធនធានធម្មជាតិដោយសារទាញយកមកប្រើប្រាស់ច្រើនហួសកម្រិតកំណត់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បំផ្លាញចរន្តទឹក | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បង្កឱ្យមានសំណឹក ឬបាត់បង់ជីជាតិដីសម្រាប់កសិកម្ម | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បង្កឱ្យមានសំណឹកជម្រាលភ្នំ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ធុំក្លិនអាក្រក់ ឬបំពុលខ្យល់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| សំណល់មិនមែនជីវៈ (ដូចជាថង់ប្លាស្ទិច) | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បំពុលផ្ទៃទឹក (អូរ បឹង...) ដោយសារទឹកហូរពីកន្លែងសាងសង់គម្រោង | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បំពុលទឹកក្រោមដីដោយសារការជ្រាបទឹកពីកន្លែងសាងសង់ចូលក្នុងដី | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បង្កើនបរិមាណទឹកកខ្វក់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## យុទ្ធសាស្ត្រទី៣ ៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន

## ផលប៉ះពាល់រយៈពេលខ្លីដោយសារគម្រោង

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| ការបំពុលទឹកក្នុងពេលសាងសង់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងបង្កឱ្យមានធូលីក្នុងពេលសាងសង់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងបង្កឱ្យសម្លេងខ្លាំងក្នុងពេលសាងសង់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងបង្កឱ្យសំណល់រឹងពីការសាងសង់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ចរាចរក្នុងអំឡុងពេលសាងសង់នាំឱ្យបំផ្លាញផ្លូវដែលប្រើប្រាស់សម្រាប់ចូលទៅកន្លែងសាងសង់គម្រោង | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| ការសាងសង់នាំឱ្យមានការបំផ្លាញរយៈពេលខ្លីដល់ដីកសិកម្ម និងដំណាំនានា | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ការបំពុលផ្ទៃទឹកដោយសារទឹកហូរចេញពីកន្លែងសាងសង់គម្រោង | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ធុំក្លិនអាក្រក់ ឬការបំពុលខ្យល់ ការបំពុលបរិយាកាស | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងបង្កឱ្យមានសំណល់មិនមែនជីវៈ (ដូចជា ថង់ប្លាស្ទិច) | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បរិមាណទឹកកខ្វក់មានការកើនឡើងដោយសារគម្រោង | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## យុទ្ធសាស្ត្រទី៤ ៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| ការសាងសង់នឹងអាចប៉ះពាល់គ្រាប់មីន និងសំណល់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនាំឱ្យមានគ្រោះថ្នាក់ដល់កម្មករ និងសហគមន៍ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ហានិភ័យនៃការសាងសង់នាំឱ្យមានគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ផ្លូវដែលបានជួសជុលល្អនាំឱ្យការបើកបរក្នុងល្បឿនលឿនជាមុន និងនាំឱ្យមានគ្រោះថ្នាក់ច្រើនជាងមុន | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ទំនប់ដែលបានសាងសង់ដោយគម្រោងអាចបាក់ និងនាំឱ្យមានគ្រោះថ្នាក់ដល់សហគមន៍មូលដ្ឋាន | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| កសិករបានបង្កើនការប្រើប្រាស់ថ្នាំគីមីកសិកម្មដែលនាំឱ្យមានផលប៉ះពាល់មិនល្អដល់សុខភាពរបស់ពួកគាត់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## យុទ្ធសាស្ត្រទី៦ ៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| គម្រោងប៉ះពាល់ដោយផ្ទាល់ដល់សត្វព្រៃ និងបំផ្លាញលំនៅសត្វព្រៃ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យបង្កើនសកម្មភាពការងាររបស់ប្រជាពលរដ្ឋ ដែលនាំឱ្យប៉ះពាល់ដល់សត្វព្រៃ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងប៉ះពាល់ដោយផ្ទាល់ដល់ធនធាននេសាទ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យបង្កើនសកម្មភាពរបស់ប្រជាពលរដ្ឋ ដែលនាំឱ្យប៉ះពាល់ដល់ធនធាននេសាទ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងប៉ះពាល់ដោយផ្ទាល់ដល់ព្រៃធម្មជាតិ និងព្រៃលិចទឹក | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យបង្កើនសកម្មភាពរបស់ប្រជាពលរដ្ឋ ដែលនាំឱ្យប៉ះពាល់ដល់ព្រៃធម្មជាតិ និងព្រៃលិចទឹក | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យមានការបង្ហូរទឹកចេញពីតំបន់ដីសើម | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យប្រជាពលរដ្ឋកែប្រែដីព្រៃ ព្រៃលិចទឹក និងតំបន់ដីសើមទៅជាដីកសិកម្ម | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យមានការផ្លាស់ប្តូរវិធីសាស្ត្រកសិកម្មដែលនាំឱ្យបំផ្លាញត្រី កង្កែប និងសត្វ រុក្ខជាតិមានប្រយោជន៍ដទៃទៀតរស់នៅក្នុងដីកសិកម្ម | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## យុទ្ធសាស្ត្រទី៨ ៖ បេតិកភណ្ឌវប្បធម៌

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| ការសាងសង់នាំឱ្យខូចខាតដោយផ្ទាល់ដល់កន្លែងបេតិកភណ្ឌវប្បធម៌ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| ផ្អែកលើចំណេះដឹងប្រជាពលរដ្ឋ និងបទពិសោធន៍ពីមុននៃតំបន់នេះ ការងារសាងសង់អាចរកឃើញវត្ថុបេតិកភណ្ឌវប្បធម៌ដែលកប់ក្នុងដី | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនឹងប៉ះពាល់ជាអវិជ្ជមានដល់តំបន់បេតិកភណ្ឌវប្បធម៌ (ដូចជាសម្លេងឬ ការបំពុល ឬការផ្លាស់ប្តូរភាពស្រស់ស្អាតនៃតំបន់) | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនឹងប៉ះពាល់ជាអវិជ្ជមានដល់វប្បធម៌របស់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## អនុសាសន៍នៃការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម

| ល.រ | បរិយាយ | ជ្រើសរើសចម្លើយចំនួន១ |
|---|---|---|
| 1 | គម្រោងនឹងមានផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន និងសង្គមដែលមិនអាចទទួលយកបាន | |
| 2 | គម្រោងនឹងមានផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន និងសង្គមជាមធ្យម។ ការអនុវត្ត និងការត្រួតពិនិត្យផែនការ ESMP កាត់បន្ថយផលប៉ះពាល់នៅក្នុងកម្រិតមួយដែលអាចទទួលយកបាន។ | |
| 3 | គម្រោងនឹងមិនមានផលប៉ះពាល់ជាអវិជ្ជមានផ្នែកបរិស្ថាន និងសង្គមគួរឱ្យកត់សម្គាល់នោះទេ | |

**ឧបសម្ព័ន្ធដែលត្រូវភ្ជាប់ ៖**

- ទម្រង់ទី៣ ៖ ការពិនិត្យពិច័យបរិស្ថាន និងសង្គម
- ផែនទីបរិស្ថាន និងសង្គម ផែនការ ESMP
- បញ្ជីអ្នកចូលរួមការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម
- កំណត់ហេតុកិច្ចប្រជុំការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម

ថ្ងៃ...............ខែ............ឆ្នាំ..........ព.ស.២៥៦...
.........ថ្ងៃទី............ខែ...............ឆ្នាំ.............

**មេឃុំ ចៅ សង្កាត់**

ថ្ងៃ................ខែ............ឆ្នាំ...........ព.ស.២៥៦...
.............ថ្ងៃទី............ខែ...............ឆ្នាំ........

**មន្ត្រីទទួលបន្ទុក**

## ៩.៦. ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម

**ចំណុចជាគន្លឹះនៃការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP)**

| | |
|---|---|
| គម្រោងមួយណា? | គម្រោងដែល ESIA កំណត់ហានិភ័យខ្ពស់ ឬមធ្យម |
| អ្នកទទួលខុសត្រូវ? | ទីចាត់ការផែនការ និងវិនិយោគ រាជធានី ខេត្ត<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>មន្ត្រីបច្ចេកទេស<br>ប្រជាជនប៉ះពាល់ដោយសារគម្រោង |
| អ្វី (គោលបំណង)? | ឯកភាពលើវិធានការនានាសម្រាប់ហានិភ័យដែលបានកំណត់នៅក្នុង ESIA |
| នៅពេលណា? | បន្ទាប់ពីការរៀបចំ ESIA |
| នៅទីណា? | នៅទីតាំងគម្រោង |
| ធ្វើដូចម្តេច? | ទម្រង់ ESIA និងផែនទីបរិស្ថាន និងសង្គមរបស់គម្រោង<br>ទម្រង់១៩.២ នៃផែនការ ESMP |

ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ទម្រង់១៩.២ នៃ ESMP) ត្រូវរៀបចំដោយមានការពិភាក្សាជាមួយប្រជាជនដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ដោយសារគម្រោង។ បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងផលប៉ះពាល់បរិស្ថាន និងសង្គមដែលបានកំណត់ជា ផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យម ឬផលប៉ះពាល់ទាប នៅក្នុងការវាយតម្លៃ ESIA (ទម្រង់ ១៩.១) ត្រូវបង្ហាញនៅក្នុងផែនការ ESMP (ទម្រង់ ១៩.២) ដែលមានជួរមួយសម្រាប់ដាក់បញ្ហាមួយ។

សម្រាប់ផលប៉ះពាល់ជាអវិជ្ជមាននីមួយៗ កិច្ចប្រជុំត្រូវឯកភាព និងកត់ត្រានៅលើទម្រង់ ៖

- វិធានការគ្រប់គ្រងហានិភ័យសមស្រប ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន។ វិធានការគ្រប់គ្រងហានិភ័យអាចរួមបញ្ចូលនូវការផ្លាស់ប្តូរនានាចំពោះប្លង់គម្រោង ការអនុវត្ត ឬការរៀបចំសម្រាប់កិច្ចប្រតិបត្តិការ និងការថែរក្សាគម្រោង។ វិធានការគ្រប់គ្រងហានិភ័យក៏អាចបញ្ចូលផលប្រយោជន៍សម្រាប់ប្រជាពលរដ្ឋដែលទទួលផលប៉ះពាល់ជាអវិជ្ជមានពីគម្រោង
- ពេលណា (ពេលវេលានៃវិធានការគ្រប់គ្រង)។ ជាទូទៅ វិធានការគ្រប់គ្រងហានិភ័យ ត្រូវអនុវត្តមុនពេល ក្នុងអំឡុងពេល ឬក្រោយពេលបញ្ចប់គម្រោង
- ការទទួលខុសត្រូវ។ អ្នកអនុវត្តវិធានការគ្រប់គ្រង? ឧទាហរណ៍ វិធានការគ្រប់គ្រងអាចជាការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីបច្ចេកទេស ឬអ្នកទទួលការ។ ប្រសិនបើវិធានការគ្រប់គ្រងត្រូវអនុវត្តក្នុងអំឡុងពេលសាងសង់គម្រោង នោះការអនុវត្តវិធានការ គឺជាការទទួលខុសត្រូវរបស់អ្នលទទួលការ។ ក្នុងករណីនេះ វិធានការគ្រប់គ្រងត្រូវបញ្ចូលក្នុងកិច្ចសន្យាជាមួយអ្នកទទួលការ

- ទំហំនៃផលប៉ះពាល់បន្ទាប់ពីវិធានការគ្រប់គ្រងហានិភ័យ។ ជាទូទៅ វិធានការនៃការគ្រប់គ្រងហានិភ័យត្រូវកាត់បន្ថយទំហំផលប៉ះពាល់។ ឧទាហរណ៍ ប្រសិនបើគម្រោងផ្លូវនឹងមានផលប៉ះពាល់ធំនៃសំណឹកដី នោះវិធានការគ្រប់គ្រង (ការផ្លាស់ប្តូរប្លង់ជាផ្លូវបង្វៀរ) អាចកាត់បន្ថយផលប៉ះពាល់មកកម្រិតមធ្យម។ ប្រសិនបើ ហានិភ័យនៅតែមានកម្រិតខ្ពស់ បន្ទាប់ពីអនុវត្តវិធានការគ្រប់គ្រង គួរលុបគម្រោងចោល។

## ឧទាហរណ៍ទម្រង់ ១៩.២ ៖ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម

<table>
<tr><td colspan="2">រាជធានី ខេត្ត<br>កំពង់ចាម</td><td colspan="2">ក្រុង ស្រុក ខណ្ឌ<br>ស្រីសន្ធរ</td><td>ឃុំ សង្កាត់<br>ឫស្សីស្រុក</td><td>លេខឃុំ សង្កាត់ ៖<br>031411</td></tr>
<tr><td colspan="6">ឈ្មោះគម្រោង ៖ ជួសជុលផ្លូវដីពីភូមិ កទីភូមិ ខ ក្នុងឃុំឫស្សីស្រុក</td></tr>
<tr><td colspan="2">ចម្លងពីទម្រង់ ១៩.១</td><td>វិធានការគ្រប់គ្រង</td><td>ពេលវេលា</td><td>ការទទួលខុសត្រូវ</td><td>ទំហំផលប៉ះពាល់បន្ទាប់ពីបន្ធូរបន្ថយ</td></tr>
<tr><td>ប្រភេទផលប៉ះពាល់អវិជ្ជមាន</td><td>ទំហំផលប៉ះពាល់</td><td></td><td></td><td></td><td></td></tr>
<tr><td>ខូចខាតប្រភពទឹក</td><td>មធ្យម</td><td>ដាក់លូថ្មីដើម្បីការពារសំណឹកពីផ្នែកខាងលើ និងខាងក្រោមខ្សែទឹក</td><td>ការរៀបចំ<br>ការសាងសង់</td><td>វិស្វករ<br>អ្នកទទួលការ</td><td>តូច</td></tr>
<tr><td>សំណឹកជម្រាលភ្នំ</td><td>មធ្យម</td><td>សង់ប្រឡាយការពារសំណឹកជម្រាលភ្នំ</td><td>ការរៀបចំ<br>ការសាងសង់</td><td>អ្នកទទួលការ</td><td>តូច</td></tr>
<tr><td>បំពុលទឹកក្នុងពេលសាងសង់</td><td>មធ្យម</td><td>សាងសង់នៅរដូវប្រាំង<br>ដាក់លូបណ្តោះអាសន្ននៅកន្លែងសាងសង់</td><td>ការសាងសង់</td><td>វិស្វករ<br>អ្នកទទួលការ</td><td>តូច</td></tr>
<tr><td>បំពុលធូលីក្នុងពេលសាងសង់</td><td>មធ្យម</td><td>ស្រោចទឹកដើម្បីការពារធូលីហុយនៅក្បែរសាលា និងផ្ទះ</td><td>ការសាងសង់</td><td>អ្នកទទួលការ</td><td>តូច</td></tr>
<tr><td>បំពុលសម្លេងក្នុងពេលសាងសង់</td><td>មធ្យម</td><td>មិនធ្វើការងារនៅពេលយប់</td><td>ការសាងសង់</td><td>អ្នកទទួលការ</td><td>តូច</td></tr>
<tr><td>សំណល់រឹងពីការសាងសង់</td><td>មធ្យម</td><td>ត្រួតពិនិត្យ និងកាយកាកសំណល់រឹង</td><td>ការសាងសង់</td><td>អ្នកទទួលការ</td><td>តូច</td></tr>
<tr><td>ចរាចរសាងសង់ខូចផ្លូវទៅការដ្ឋានគម្រោង</td><td>មធ្យម</td><td>គ្មានការដឹកជញ្ជូនធ្ងន់នៅរដូវវស្សា</td><td>ការសាងសង់</td><td>អ្នកទទួលការ</td><td>តូច</td></tr>
<tr><td>ការសាងសង់ខូចដីកសិកម្ម និងដំណាំរយៈពេលខ្លី</td><td>មធ្យម</td><td>ចរចារជាមួយកសិករអំពីដីដែលត្រូវការនៅក្បែរផ្លូវ</td><td>ការសាងសង់</td><td>អ្នកទទួលការ</td><td>តូច</td></tr>
<tr><td>បំពុលទឹកលូហូរចេញពីកន្លែងសាងសង់</td><td>មធ្យម</td><td>ត្រួតពិនិត្យសំណល់រាវ និងគីមីនៅកន្លែងសាងសង់</td><td>ការសាងសង់</td><td>អ្នកទទួលការ</td><td>តូច</td></tr>
</table>

ថ្ងៃ...............ខែ............ឆ្នាំ...........ព.ស.២៥៦...
....................ថ្ងៃទី..........ខែ...............ឆ្នាំ...........

មេឃុំ ចៅសង្កាត់

ថ្ងៃ................ខែ............ឆ្នាំ...........ព.ស.២៥៦...
..............ថ្ងៃទី..........ខែ...............ឆ្នាំ...............

មន្ត្រីបច្ចេកទេស

### ៤.៦.១. អនុសាសន៍នៃការវិភាគបរិស្ថាន និងសង្គម និងផែនការគ្រប់គ្រង

ផ្នែកចុងក្រោយនៃទម្រង់ទី១៩.១ ពាក់ព័ន្ធនឹងអនុសាសន៍ ត្រូវបំពេញសម្រាប់គម្រោងទាំងអស់បន្ទាប់ពីបានរៀបចំផែនការ ESMP (ទម្រង់១៩.២)។

អនុសាសន៍មួយក្នុងចំណោមអនុសាសន៍ខាងក្រោមត្រូវជ្រើសរើស ៖

- គម្រោងនឹងមិនមានផលប៉ះពាល់ជាអវិជ្ជមានផ្នែកបរិស្ថាន និងសង្គម ដែលមិនអាចទទួលយកបាន (ធំ ឬមធ្យម)
- ត្រូវការវិធានការគ្រប់គ្រងហានិភ័យ រួមបញ្ចូលទាំងការផ្លាស់ប្តូរប្លង់គម្រោង ដើម្បីកាត់បន្ថយផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមមកត្រឹមកម្រិតដែលអាចទទួលយកបាន
- ត្រូវការវិធានការគ្រប់គ្រងហានិភ័យ រួមបញ្ចូលទាំងការផ្លាស់ប្តូរការអនុវត្តគម្រោង ដើម្បីកាត់ បន្ថយផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមមកត្រឹមកម្រិតដែលអាចទទួលយកបាន
- ត្រូវការវិធានការគ្រប់គ្រងហានិភ័យ រួមបញ្ចូលទាំងការផ្លាស់ប្តូរកិច្ចប្រតិបត្តិការ និងការថែរក្សាគម្រោង ដើម្បីកាត់បន្ថយផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមមកត្រឹមកម្រិតដែលអាចទទួលយកបាន
- គម្រោងនឹងបណ្តាលឱ្យមានផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមធ្ងន់ធ្ងរ ដែលមិនអាចកាត់បន្ថយតាមរយៈវិធានការគ្រប់គ្រងហានិភ័យ។ ដូច្នេះគម្រោងត្រូវលុបចោល។

បន្ទាប់ពីបញ្ចប់ ESIA រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្ញើរបាយការណ៍ និងឧបសម្ព័ន្ធនានា (រួមបញ្ចូលទាំងទម្រង់ ៣ ទម្រង់១៩.១ ទម្រង់ ១៩.២ ផែនទីបរិស្ថាន និងសង្គម និងរបាយការណ៍អ្នកចូលរួមប្រជុំ) ទៅទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ដើម្បីពិនិត្យ និងផ្តល់យោបល់។

### ៤.៦.២. ការពិនិត្យការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម

បន្ទាប់ពីទទួលបាន ESIA និង ESMP ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ទីចាត់ការផែនការវិនិយោគរាជធានី ខេត្ត ត្រូវពិនិត្យអំពីភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃរបាយការណ៍នេះ។

ក្នុងការពិនិត្យមើល ប្រសិនបើរកឃើញថា ESIA មានភាពមិនត្រឹមត្រូវ និងខ្វះខាតព័ត៌មានដែលត្រូវការ ដើម្បីសម្រួល ឬបំពេញ ទីចាត់ការផែនការ និងវិនិយោគ រាជធានី ខេត្ត ត្រូវផ្តល់ព័ត៌មានជាលាយលក្ខអក្សរដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបង្ហាញឱ្យបានច្បាស់អំពីចំណុចខ្វះខាតនានាដែលត្រូវកែតម្រូវ។ បន្ទាប់ពីបានកែតម្រូវ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្ញើរបាយការណ៍ ESIA ជូនទីចាត់ការផែនការ និងវិនិយោគ រាជធានី ខេត្ត។

ក្នុងការពិនិត្យមើល ប្រសិនបើរកឃើញថា ESIA មានភាពគ្រប់គ្រាន់ និងត្រឹមត្រូវ ទីចាត់ការផែនការ និងវិនិយោគ រាជធានី ខេត្ត ត្រូវផ្ញើ ESIA និង ESMP មួយច្បាប់ទៅឱ្យមន្ទីរបរិស្ថានរាជធានី ខេត្ត សម្រាប់ការធ្វើសវនកម្មបច្ចេកទេស។

មន្ទីរបរិស្ថាន រាជធានី ខេត្ត មានសិទ្ធិក្នុងការបដិសេធក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីទទួលបានរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងសង្គម។

ប្រសិនបើមន្ទីរបរិស្ថានមានបំណងបដិសេធរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងសង្គម មន្ទីរបរិស្ថាន ត្រូវផ្ញើព័ត៌មានជាលាយលក្ខអក្សរទៅទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត។

ក្នុងរយៈពេល១៥ថ្ងៃ បើពុំមានការបដិសេធទេ មានន័យថា របាយការណ៍វិភាគ ESIA ត្រូវបានធ្វើសវនកម្មបច្ចេកទេសពេញលេញដោយមន្ទីរបរិស្ថាន។

សម្រាប់គម្រោងទាំងឡាយដែលមានទីតាំងនៅក្នុងឃុំ សង្កាត់ ដែលស្ថិតនៅក្នុងបញ្ជីនៃតំបន់ងាយរងគ្រោះចំពោះផលប៉ះពាល់បរិស្ថាន និងសង្គម ទីចាត់ការផែនការ និងវិនិយោគ រាជធានី ខេត្ត ត្រូវ ផ្ញើរបាយការណ៍ ESIA និងឧបសម្ព័ន្ធនៃរបាយការណ៍នេះជាឯកសារអេឡិចត្រូនិចជូនក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីពិនិត្យ និងផ្តល់យោបល់ មុននឹងផ្ញើរបាយការណ៍ ESIA ទៅឱ្យមន្ទីរបរិស្ថាន រាជធានី ខេត្ត ពិនិត្យ និងផ្តល់យោបល់។ ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. មានរយៈពេល១០ថ្ងៃ ដើម្បីពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ ESIA បន្ទាប់ពីទទួលបាករបាយការណ៍នេះ។ ក្នុងការពិនិត្យមើល ប្រសិនបើរកឃើញមានចំណុចខ្វះខាត ឬការបំពេញមិនបានត្រឹមត្រូវ ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវផ្តល់ព័ត៌មានឱ្យទីចាត់ការផែនការ និងវិនិយោគ រាជធានី ខេត្ត តាមរយៈ អ៊ីម៉ែលក្នុងរយៈពេល១០ថ្ងៃ។ សំណើគម្រោងមិនអាចផ្ញើជូនមន្ទីរ អង្គភាព ដើម្បីធ្វើសវនកម្មបច្ចេកទេសមុនពេលរបាយការណ៍ ESIA ទទួលបានឯកភាពពីក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ឡើយ។

### ៤.៧. ការសិក្សាដីធ្លី

ប្រសិនបើ លទ្ធផលនៃការពិនិត្យពិច័យ (ទម្រង់ ៣) បង្ហាញថា គម្រោងមានចំណាត់ថ្នាក់ ខ ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៥ស្តីពីលទ្ធកម្មដីធ្លី និងតាំងទីលំនៅដោយមិនស្ម័គ្រចិត្តនៃគោលនយោបាយ ESS ចាំបាច់ត្រូវអនុវត្តការសិក្សាដីធ្លី ស្របតាមសេចក្តីណែនាំដែលបានកំណត់នៅក្នុងសៀវភៅភីម (PIM) នៃមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក។

### ៤.៨. របាយការណ៍ស្តីពីសិទ្ធិជនជាតិដើមភាគតិច

ប្រសិនបើ លទ្ធផលនៃការពិនិត្យពិច័យ (ទម្រង់ ៣) បង្ហាញថា គម្រោងមានចំណាត់ថ្នាក់ ខ ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៧ស្តីពីជនជាតិដើមភាគតិចនៃគោលនយោបាយ ESS ចាំបាច់ត្រូវអនុវត្តការសិក្សាអំពីសិទ្ធិជនជាតិដើមភាគតិច ស្របតាមនសេចក្តីណែនាំដែលបានកំណត់នៅក្នុងសៀវភៅភីម (PIM)នៃមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក។

## ៤.៩. ទម្រង់ព័ត៌មានគម្រោង

កិច្ចដំណើរការបំពេញទម្រង់ព័ត៌មានគម្រោងមានរៀបរាប់នៅក្នុងសៀវភៅភីម(PIM)នៃគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងមូលនិធិក្រុង ស្រុក។

ទោះជាយ៉ាងណាក៏ដោយ ទម្រង់ព័ត៌មានគម្រោងត្រូវបង្ហាញអំពីលទ្ធផលនៃការពិនិត្យពិច័យហានិភ័យបរិស្ថាន និងសង្គម។

**ផ្នែកទី៣ ៖ លទ្ធផលនៃការពិនិត្យពិច័យហានិភ័យបរិស្ថាន និងសង្គម**

| | |
|---|---|
| **ចំណាត់ថ្នាក់ហានិភ័យនៃគម្រោងពាក់ព័ន្ធនឹងហានិភ័យបរិស្ថាន និងសង្គម?** | ចំណាត់ថ្នាក់ ក ឬ ខ អាស្រ័យលើលទ្ធផលនៃការពិនិត្យពិច័យផ្នែកបរិស្ថាន និងសង្គម |
| **ប្រសិនបើ គម្រោងមានចំណាត់ថ្នាក់ ក** | • មូលហេតុដែលនាំឱ្យគម្រោងមានចំណាត់ថ្នាក់ ក ផ្អែកលើសំណួរដែលឆ្លើយក្នុងទម្រង់៣ (បាទ) សំណួរទី១-៥។<br>• ក្រសួងទទួលខុសត្រូវបញ្ហានេះ (បង្ហាញក្នុងទម្រង់៣)<br>• កាលបរិច្ឆេទដែលក្រសួងទទួលខុសត្រូវដាក់ចេញលិខិតអនុម័តគម្រោង ដើម្បីបន្តនីតិវិធី។ |
| **ប្រសិនបើ គម្រោងមានចំណាត់ថ្នាក់ ខ និងតម្រូវឱ្យមានការសិក្សាផលប៉ះពាល់បរិស្ថាន និងសង្គម?** | យុទ្ធសាស្ត្របរិស្ថាន និងសង្គមពីយុទ្ធសាស្ត្រទី២-៨ ដែលពាក់ព័ន្ធនឹងគម្រោង ផ្អែកលើទម្រង់ទី៣ |

## ៤.១០. ការអនុវត្ត ESMP របាយការណ៍សិក្សាដីធ្លី និងរបាយការណ៍ជនជាតិដើមភាគតិច

### ៤.១០.១. មុនពេលអនុវត្តគម្រោង

វិធានការនានានៃការគ្រប់គ្រងហានិភ័យក្នុងផែនការ ESMP ឬនៅក្នុងរបាយការណ៍សិក្សាដីធ្លី ឬរបាយការណ៍ស្តីពីជនជាតិដើមភាគតិច អាចរួមបញ្ចូលនូវវិធានការនានាដែលត្រូវបំពេញ មុនពេលគម្រោងត្រូវបានចាប់ផ្តើមអនុវត្ត។

ឧទាហរណ៍ ការគ្រប់គ្រងហានិភ័យអាចតម្រូវឱ្យមានការផ្លាស់ប្តូរចំពោះការរៀបចំគម្រោង។ ឧទាហរណ៍ គម្រោងមួយខ្សែអាចត្រូវបានផ្លាស់ប្តូរ ដើម្បីចៀសវាងផលប៉ះពាល់កន្លែងដែលមានសារៈសំខាន់សម្រាប់បរិស្ថាន។

មន្ត្រីគាំទ្របច្ចេកទេស ឬវិស្វករទទួលខុសត្រូវក្នុងការផ្លាស់ប្តូរ។

គណៈកម្មការគ្រងគ្រងគម្រោង ត្រូវពិនិត្យថា ការផ្លាស់ប្តូរនានាត្រូវបានអនុវត្ត ស្របតាមផែនការ ESMP។

វិធានការនៃការគ្រប់គ្រងហានិភ័យមួយទៀតដែលត្រូវបំពេញមុនការអនុវត្តគម្រោង រួមបញ្ចូលនូវសំណងសម្រាប់លទ្ធកម្មដីធ្លី។ សំណងដែលបានឯកភាពគ្នាផ្អែកលើលទ្ធផលនៃការសិក្សាដីធ្លី ត្រូវ

ទូទាត់មុនពេលអនុវត្តគម្រោង រួមបញ្ចូលទាំងកិច្ចព្រមព្រៀងមិនផ្លូវការសម្រាប់សំណង (ឧទាហរណ៍ អនុញ្ញាតឱ្យម្ចាស់អាជីវកម្មផ្លាស់ប្តូរទីតាំងរបស់ខ្លួនទៅទីតាំងថ្មី) ដែលបានឯកភាពនៅក្នុងកិច្ចព្រមព្រៀងការបរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត។

## ៤.១០.២. វិធានការគ្រប់គ្រងហានិភ័យក្នុងអំឡុងពេលអនុវត្តគម្រោង

គណៈកម្មការគ្រប់គ្រងគម្រោង មន្រ្តីគាំទ្របច្ចេកទេស និងអ្នកទទួលការទទួលខុសត្រូវក្នុងការធានាការគ្រប់គ្រងបរិស្ថាន និងសង្គមឱ្យបានល្អក្នុងអំឡុងពេលអនុវត្តគម្រោង។ ជាធម្មតាការគ្រប់គ្រងបរិស្ថាន និងសង្គម មានសារសំខាន់សម្រាប់កិច្ចសន្យាសាងសង់ ប៉ុន្តែកិច្ចសន្យាឧបករណ៍-សម្ភារ និងសេវានានា ក៏អាចមានហានិភ័យផ្នែកបរិស្ថាន ឬសង្គមផងដែរ។

ការគ្រប់គ្រងបរិស្ថាន និងសង្គមបានដែលល្អមានន័យថា ជាការអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋាននានានៃព្រះរាជាណាចក្រកម្ពុជា និងការអនុវត្តតាមគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមរបស់ គ.ជ.អ.ប.។

លក្ខខណ្ឌស្តង់ដារនៃកិច្ចសន្យាសម្រាប់កិច្ចសន្យាការងារ (ទម្រង់ ៥០.១) កំណត់ការទទួលខុសត្រូវរបស់អ្នកទទួលការក្នុងការអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋាននានាអំពីការងារ សុខភាព និងសុវត្ថិភាព កិច្ចការពារបរិស្ថាន កិច្ចការពារការបំពុល និងកិច្ចការពារបេតិកភណ្ឌវប្បធម៌។ អ្នកទទួលការត្រូវសាងសង់លើដីសាធារណៈ ឬដីផ្សេងទៀត ដែលបានកំណត់ដោយម្ចាស់គម្រោង។ ប្រសិនបើអ្នកទទួលការត្រូវការប្រើប្រាស់ជាបណ្តោះអាសន្ននូវដីឯកជនក្នុងពេលសាងសង់ អ្នកទទួលការត្រូវចរចារជាមួយម្ចាស់ដី សម្រាប់ការអនុញ្ញាត និងសំណង់។ ម្ចាស់គម្រោង និងមន្រ្តីគាំទ្របច្ចេកទេស ត្រូវពិនិត្យការអនុវត្តតាមលក្ខខណ្ឌកិច្ចសន្យាទាំងនេះ និងមិនត្រូវអនុម័តការទូទាត់ណាមួយរហូតដល់ពេលលក្ខ ខណ្ឌទាំងនេះត្រូវបានអនុវត្ត។

សម្រាប់គម្រោងដែលមានចំណាត់ថ្នាក់ ក ឬចំណាត់ថ្នាក់ ខ ផែនការ ESMP ត្រូវផ្តល់ឱ្យអ្នកទទួលការជាផ្នែកមួយនៃឯកសារកិច្ចសន្យា។ អ្នកទទួលការត្រូវអាន និងយល់ពី ESMP និងត្រូវអនុវត្តវិធានការគ្រប់គ្រងហានិភ័យនានាដែលជាការទទួលខុសត្រូវរបស់អ្នកទទួលការ។ ម្ចាស់គម្រោង និងមន្រ្តីបច្ចេកទេសត្រូវពិនិត្យការអនុវត្តតាម ESMP មុនការអនុម័តការទូទាត់ឱ្យអ្នកទទួលការ។

ក្នុងអំឡុងពេលអនុវត្តគម្រោង គណៈកម្មការគ្រប់គ្រងគម្រោង និងមន្រ្តីបច្ចេកទេស ត្រូវពិនិត្យការអនុវត្តតាម ESMP និងលក្ខខណ្ឌកិច្ចសន្យានានា តាមមធ្យោបាយដូចគ្នានឹងការពិនិត្យការអនុវត្តតាមផ្នែកបច្ចេកទេសនានានៃកិច្ចសន្យា។

ក្នុងករណីមានប្រជាពលរដ្ឋ ដែលទទួលផលប៉ះពាល់ដោយសារគម្រោងប្តឹងអំពីផលប៉ះពាល់ជាអវិជ្ជមាន គណៈកម្មការគ្រប់គ្រងគម្រោងត្រូវចាត់វិធានការសមស្រប ដើម្បីស៊ើបអង្កេតបណ្តឹងនោះ។ ប្រជាពលរដ្ឋក៏មានសិទ្ធិដាក់បណ្តឹងរបស់ខ្លួនទៅការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ឬការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ឬអាចប្តឹងដោយផ្ទាល់ទៅលេខាធិការដ្ឋាន គ.ជ.អ.ប.។

ក្នុងករណីមាន ព្រឹត្តិការណ៍មិនបានគ្រោងទុកណាមួយកើតមានឡើងក្នុងអំឡុងពេលអនុវត្ត គម្រោងដែលនាំឱ្យប៉ះពាល់ជាអវិជ្ជមានផ្នែកបរិស្ថាន និងសង្គម រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តល់ព័ត៌មានជូនអាជ្ញាធរពាក់ព័ន្ធ និងក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

# ៥. តួនាទីលេខាធិការដ្ឋាន គ.ជ.អ.ប.

## ៥.១. ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប.

ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ជាយន្តការមួយដែលបង្កើតឡើងដើម្បីត្រួតពិនិត្យ និងផ្តល់ប្រឹក្សាអំពីការអនុវត្តគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំបញ្ជីនៃតំបន់ដែលមានភាពងាយរងគ្រោះផ្នែកបរិស្ថាន(ឃុំសង្កាត់ដែលស្ថិតនៅក្នុងតំបន់ដែលងាយរងផលប៉ះពាល់ផ្នែកបរិស្ថាន) និងបញ្ជីតំបន់ជនជាតិដើមភាគតិច (ភូមិដែលមានជនជាតិដើមភាគតិចចំនួន លើសពី៥%នៃចំនួនប្រជាជនសរុបក្នុងភូមិ) ដើម្បីដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងអនុម័ត។ គ.ជ.អ.ប. នឹងផ្ញើបញ្ជីទាំង២នេះជូនរាជធានី ខេត្ត ដែលពាក់ព័ន្ធ និងផ្សព្វផ្សាយតាមរយៈវេបសាយរបស់ គ.ជ.អ.ប. (https://www.ncdd.gov.kh)។ រាជធានី ខេត្ត ត្រូវផ្ញើបញ្ជីទាំង២នេះជូនឃុំ សង្កាត់ដែលពាក់ព័ន្ធ។

ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីនៃតំបន់ដែលងាយទទួលផលប៉ះពាល់ផ្នែកបរិស្ថាន និងបញ្ជីតំបន់ជនជាតិភាគតិចជាប្រចាំ។

បញ្ជីនៃតំបន់ដែលងាយទទួលផលប៉ះពាល់ផ្នែកបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពផ្អែកលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- ភូមិសាស្ត្រទាំងអស់ ឬពាក់កណ្តាលនៃឃុំ សង្កាត់គ្របដណ្តប់ដោយព្រៃធម្មជាតិ
- ភូមិសាស្ត្រឃុំ សង្កាត់ដែលគ្របដណ្តប់ដោយដីសើម ឬព្រៃឈើដែលមានទំហំ១០% ឬច្រើនជាងផ្ទៃដីសរុបរបស់ឃុំ សង្កាត់
- មានការកំណត់ដោយថ្នាក់រាជធានី ខេត្ត ឬថ្នាក់ជាតិជាតំបន់ការពារ តំបន់ព្រៃការពារ តំបន់អភិរក្សត្រីទឹកសាប ឬទឹកប្រៃ ឬតំបន់អភិរក្សផ្នែកមនុស្សវិទ្យា
- តំបន់ជីវចម្រុះដែលកំណត់សម្រាប់ជាកន្លែងរស់នៅរបស់សត្វជិតផុតពូជ
- តំបន់ដែលគម្រោងពីបានអនុវត្ត និងនាំឱ្យមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ
- ជាភូមិដែលមានជនជាតិដើមភាគតិចរស់នៅចំនួនច្រើនជាង៥%នៃចំនួនប្រជាជនសរុបក្នុងភូមិ។

សម្រាប់គម្រោងឃុំ សង្កាត់នានាដែលមានទីតាំងស្ថិតក្នុងបញ្ជីនៃតំបន់ដែលរងផលប៉ះពាល់ផ្នែកបរិស្ថាន ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវ ៖

- ពិនិត្យមើលឡើងវិញលើការពិនិត្យមើលអំពីតម្រូវការសម្រាប់ការសិក្សាផលប៉ះពាល់ផ្នែកបរិស្ថាននៃគម្រោងនានា ដើម្បីបញ្ជាក់ពីសក្តានុពលនៃផលប៉ះពាល់ផ្នែកបរិស្ថានរបស់គម្រោងទាំងនេះ
- ពិនិត្យមើលនៅទីតាំងគម្រោង ផ្តល់ប្រឹក្សាយោបល់អំពីការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងពិនិត្យមើលការវាយតម្លៃបរិស្ថាន និងឧបសម្ព័ន្ធនានានៃគម្រោងដែលបានពិនិត្យឡើងវិញបង្ហាញថា គម្រោងមានសក្តានុពលនៃផលប៉ះពាល់បរិស្ថាន (ជាពិសេស គម្រោងផ្លូវថ្មី ប្រព័ន្ធធារាសាស្ត្រថ្មី ទំនប់ថ្មី អាងស្តុកទឹកថ្មី ឬប្រឡាយថ្មី) មុនពេលគម្រោងនេះទទួលបានសវនកម្មបច្ចេកទេស។

សម្រាប់គម្រោងឃុំ សង្កាត់ទាំងឡាយដែលមានទីតាំងស្ថិតក្នុងភូមិក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិច ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវ ៖

- ពិនិត្យមើលឡើងវិញលើការពិនិត្យមើលអំពីតម្រូវការ សម្រាប់ការរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចនៃគម្រោងនានា ដើម្បីកំណត់អំពីសក្តានុពលនៃផលប៉ះពាល់របស់គម្រោងទាំងនេះលើជនជាតិដើមភាគតិច និង
- ពិនិត្យរបាយការណ៍នៃវិធានការនានា ដើម្បីការពារសុវត្ថិភាពជនជាតិដើមភាគតិច។

ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវអនុវត្តការសិក្សា និងការវាយតម្លៃប្រចាំឆ្នាំអំពីផលប៉ះពាល់ដីធ្លីដែលបណ្តាលមកពីការអនុវត្តគម្រោងឃុំ សង្កាត់។

## ៩.២. ក្រុមការងារយេនឌ័រនៃលេខាធិការដ្ឋាន គ.ជ.អ.ប.

ការអនុវត្តគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិស្ថិតក្រោមការពិនិត្យមើល និងការសម្របសម្រួលរបស់ក្រុមការងារយេនឌ័រនៃ គ.ជ.អ.ប. ដែលដឹកនាំដោយក្រសួងកិច្ចការនារី និងរួមមានសមាជិកជាតំណាងមកពីក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប.។

ក្រុមការងារយេនឌ័រ ទទួលខុសត្រូវក្នុងការពិនិត្យមើលការធ្វើសមាហរណកម្មនៃគោលនយោបាយយេនឌ័រក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក។ ក្នុងដំណាក់កាលសាកល្បងនូវសេចក្តីណែនាំនេះ ក្រុមការងារយេនឌ័រមានការទទួលខុសត្រូវដូចខាងក្រោម ៖

- អនុម័តគម្រោងការក្នុងការសាកល្បង
- អនុម័តលក្ខណៈវិនិច្ឆ័យសម្រាប់ការគណនាពិន្ទុយេនឌ័រ កំណត់អំពីគម្រោងមានភាពវិជ្ជមានផ្នែកយេនឌ័រ និងកំណត់ពិន្ទុទាបបំផុតនៃយេនឌ័រដែលអាចទទួលយកបាន
- គាំទ្រការអភិវឌ្ឍសមត្ថភាពសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងមូលនិធិក្រុង ស្រុក

- ត្រួតពិនិត្យការអនុវត្តគោលនយោបាយយេនឌ័រក្នុងគម្រោងមូលនិធិឃុំ សង្កាត់ និង គម្រោងមូលនិធិក្រុង ស្រុក
- ក្នុងករណី មានការផ្តល់ការលើកទឹកចិត្តណាមួយដល់គម្រោងដែលមានភាពវិជ្ជមាន ផ្នែកយេនឌ័រ ក្រុមការងារត្រូវពិនិត្យ និងអនុម័តនូវការផ្តល់ការលើកទឹកចិត្តនោះ ផ្អែក លើពិន្ទុយេនឌ័រ
- ពិនិត្យមើលមេរៀនដែលទទួលបានពីការសាកល្បង និងរៀបចំសំណើនានាសម្រាប់ ការបញ្ជ្រាបគោលនយោបាយយេនឌ័រ ទៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង មូលនិធិឃុំ សង្កាត់ និងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក

កិច្ចប្រតិបត្តិការផ្នែករដ្ឋបាលរបស់ក្រុមការងារយេនឌ័រនៃ គ.ជ.អ.ប. ជាការទទួលខុសត្រូវរបស់ សមាជិកក្រុមការងារដែលជាបុគ្គលិកលេខាធិការដ្ឋាន គ.ជ.អ.ប. និងត្រូវរាយការណ៍ជូនប្រធានក្រុម ការងារ។

## ៦. ការត្រួតពិនិត្យ និងការវាយតម្លៃ ESMP

គណៈកម្មការគ្រប់គ្រងគម្រោងទទួលខុសត្រូវត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងហានិភ័យ បរិស្ថាន និងសង្គម និងយត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ការត្រួត ពិនិត្យមានគោលបំណងដូចខាងក្រោម ៖

- វិធានការគ្រប់គ្រងហានិភ័យនានាក្នុងផែនការ ESMP ត្រូវបានអនុវត្តត្រឹមត្រូវ
- កិច្ចព្រមព្រៀងលទ្ធកម្មដីធ្លី ឬកិច្ចព្រមព្រៀងស្តីពីការបរិច្ចាគដីធ្លីដោយស្ម័គ្រចិត្តបាន អនុវត្តត្រឹមត្រូវ
- វិធានការការពារជនជាតិដើមភាគតិចបានអនុវត្តត្រឹមត្រូវ
- អ្នកទទួលការអនុវត្តតាមគោលនយោបាយក្នុងសុវត្ថិភាពបរិស្ថាន និងសង្គមដែលមាន ចែងក្នុងលក្ខខណ្ឌកិច្ចសន្យា។

ប្រសិនបើ គម្រោងត្រូវបានជ្រើសរើសសម្រាប់សវនកម្ម ការអនុវត្តវិធានការគ្រប់គ្រងហានិភ័យ បរិស្ថាន និងសង្គមត្រូវបញ្ចូលជាផ្នែកមួយនៃការធ្វើសវនកម្មនេះ។

ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ត្រូវជ្រើសរើសសំណាកគំរូនៃក្រុង ស្រុក និងឃុំ សង្កាត់ក្នុងឆ្នាំនីមួយៗ ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តវិធានការគ្រប់គ្រងហានិភ័យសុវត្ថិភាព បរិស្ថាន និងសង្គម។ របាយការណ៍វាយតម្លៃត្រូវចែករំលែកជាមួយក្រុមការងារសុវត្ថិភាពបរិស្ថាន និង សង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប.។

ក្រុមការងារសុវត្ថិភាពបរិស្ថាន និងសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ក៏ត្រូវជ្រើសរើស សំណាកគំរូនៃគម្រោងសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃក្នុងឆ្នាំនីមួយៗផងដែរ។

# ៧. ការសម្រុះសម្រួលដោះស្រាយបណ្តឹង

## ៧.១. គោលការណ៍

ប្រជាពលរដ្ឋ ឬភាគីពាក់ព័ន្ធមានសិទ្ធិប្តឹងអំពីផលប៉ះពាល់ជាអវិជ្ជមានដែលបណ្តាលមកពីគម្រោងវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមានបណ្តឹងពាក់ព័ន្ធនឹង ៖

- គោលនយោបាយ ESS ដែលអនុវត្តមិនបានត្រឹមត្រូវ នាំឱ្យប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន ឬសង្គមនៃគម្រោង
- គោលនយោបាយយេនឌ័រដែលអនុវត្តមិនបានត្រឹមត្រូវ បណ្តាលឱ្យមានគុណវិបត្តិដល់ស្ត្រីដែលជាលទ្ធផលនៃគម្រោង។

ខាងក្រោមជាគោលការណ៍ ដែលត្រូវអនុវត្តសម្រាប់សម្រោះសម្រួលដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងបញ្ហាបរិស្ថាននិងសង្គម និងយេនឌ័រ ៖

- ប្រជាពលរដ្ឋដែលប៉ះពាល់ជាអវិជ្ជមានដោយសារគម្រោងមានសិទ្ធិដាក់បណ្តឹង
- ប្រជាជនទទួលបានព័ត៌មានអំពីការដាក់បណ្តឹង និងកិច្ចដំណើរការស៊ើបអង្កេត
- បណ្តឹងទាំងអស់ត្រូវបានទទួល កត់ត្រា និងស៊ើបអង្កេត
- វិធានការសមស្របត្រូវបានអនុវត្ត ប្រសិនបើបណ្តឹងមានភាពពិតប្រាកដ
- កិច្ចដំណើរការត្រូវបានចងក្រងជាឯកសារ និងអាចធ្វើសវនកម្ម
- ប្រជាជនដែលដាក់បណ្តឹងត្រូវបានការពារពីអំពើសងសឹកណាមួយ។

ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទទួលខុសត្រូវក្នុងការសម្រុះសម្រួលដោះស្រាយបណ្តឹងអំពីសុវត្ថិភាពបរិស្ថាននិងសង្គម និងអំពីយេនឌ័រក្នុងការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ប្រជាជនក៏មានសិទ្ធិដាក់បណ្តឹងដោយផ្ទាល់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប. លើគម្រោងដែលទទួលថវិកាពីលេខាធិការដ្ឋាន គ.ជ.អ.ប.។

## ៧.២. ការសម្រុះសម្រួលដោះស្រាយបណ្តឹងដោយការិយាល័យប្រជាពលរដ្ឋ

ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទទួលខុសត្រូវក្នុងការទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងអំពីសុវត្ថិភាពបរិស្ថាននិងសង្គម និងអំពីយេនឌ័រក្នុងការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណី ស្រុកដែលពុំទាន់មានការិយាល័យប្រជាពលរដ្ឋ ការិយាល័យប្រជាពលរដ្ឋខេត្តជាអ្នកទទួលខុសត្រូវ។

ការិយាល័យប្រជាពលរដ្ឋ ត្រូវអនុវត្តតាមនីតិវិធីដែលបានកំណត់ក្នុងការសម្រោះសម្រួលដោះស្រាយបណ្តឹងដែលពាក់ព័ន្ធនឹងសុវត្ថិភាពបរិស្ថាននិងសង្គម និងអំពីយេនឌ័រក្នុងការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

បុគ្គលិកការិយាល័យប្រជាពលរដ្ឋ នឹងទទួលបាននូវការបណ្តុះបណ្តាលអំពីគោលនយោបាយសុវត្ថិភាពបរិស្ថាននិងសង្គម និងគោលនយោបាយយេនឌ័រក្នុងការអនុវត្តគម្រោង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីតម្រូវការនានានៃគោលនយោបាយទាំងនេះ។

ក្នុងករណី ការិយាល័យប្រជាពលរដ្ឋទទួលបានបណ្តឹងអំពីសុវត្ថិភាពបរិស្ថាន និងសង្គម ប៉ុន្តែពុំមានជំនាញគ្រប់គ្រាន់ក្នុងការស៊ើបអង្កេតបណ្តឹងនេះ ការិយាល័យប្រជាពលរដ្ឋអាច ៖

- ស្នើសុំទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តធ្វើជាទីប្រឹក្សាក្នុងការស៊ើបអង្កេតបណ្តឹង
- ស្នើសុំមន្ទីរ អង្គភាពជំនាញរាជធានី ខេត្តពាក់ព័ន្ធ (ដូចជាមន្ទីរបរិស្ថាន) ផ្តល់ប្រឹក្សាយោបល់អំពីការស៊ើបអង្កេតបណ្តឹង
- ស្នើសុំក្រុមការងារសុវត្ថិភាពបរិស្ថាន និង សង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ផ្តល់ប្រឹក្សាយោបល់អំពីការស៊ើបអង្កេតបណ្តឹង។

ក្នុងករណី ការិយាល័យប្រជាពលរដ្ឋទទួលបានបណ្តឹងអំពីការអនុវត្តគោលនយោបាយយេនឌ័រ ប៉ុន្តែពុំមានជំនាញគ្រប់គ្រាន់ក្នុងការស៊ើបអង្កេតបណ្តឹងនេះ ការិយាល័យប្រជាពលរដ្ឋអាច ៖

- ស្នើសុំ គ.ក.ស.ក. រាជធានី ខេត្តធ្វើជាទីប្រឹក្សាក្នុងការស៊ើបអង្កេតបណ្តឹង
- ស្នើសុំមន្ទីរកិច្ចការនារីរាជធានី ខេត្តផ្តល់ប្រឹក្សាយោបល់អំពីការស៊ើបអង្កេតបណ្តឹង
- ស្នើសុំក្រុមការងារសុវត្ថិភាពបរិស្ថាន និង សង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ផ្តល់ប្រឹក្សាយោបល់អំពីការស៊ើបអង្កេតបណ្តឹង។

ក្នុងករណី ការិយាល័យប្រជាពលរដ្ឋទទួលបានបណ្តឹងអំពីគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គម ឬគោលនយោបាយយេនឌ័រក្នុងការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ ការិយាល័យប្រជាពលរដ្ឋត្រូវធ្វើរបាយការណ៍មួយច្បាប់អំពីការស៊ើបអង្កេតជូនលេខាធិការដ្ឋាន គ.ជ.អ.ប.។

## ៧.៣. ការសម្រុះសម្រួលដោះស្រាយបណ្តឹងដោយលេខាធិការដ្ឋាន គ.ជ.អ.ប.

ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិដាក់បណ្តឹងរបស់ខ្លួនដោយផ្ទាល់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប. ដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងផលប៉ះពាល់ជាអវិជ្ជមានផ្នែកបរិស្ថាន និងសង្គម និងបញ្ហានានាពាក់ព័ន្ធនឹងគោលនយោបាយយេនឌ័រ។

បណ្តឹងនានាដែលបានដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវសម្របសម្រួលដោះស្រាយដោយក្រុមការងារសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។

បណ្តឹងនានាអាចធ្វើឡើងតាមរយៈ ៖

- ប្រអប់បណ្តឹងនៅការិយាល័យលេខាធិការដ្ឋាន គ.ជ.អ.ប.
- ផ្ញើលិខិតជូនក្រុមការងារសម្រុះសម្រួលដោះស្រាយបណ្តឹងលេខាធិការដ្ឋាន គ.ជ.អ.ប
- ផ្ញើអ៊ីម៉ែលជូនក្រុមការងារសម្រុះសម្រួលដោះស្រាយបណ្តឹងលេខាធិការដ្ឋាន គ.ជ.អ.ប.

- ផ្ញើលិខិតជូនក្រុមការងារសម្រុះសម្រួលដោះស្រាយបណ្តឹងលេខាធិការដ្ឋាន គ.ជ.អ.ប
- ទូរស័ព្ទទៅក្រុមការងារសម្រុះសម្រួលដោះស្រាយបណ្តឹងលេខាធិការដ្ឋាន គ.ជ.អ.ប.ឬ បុគ្គលិកណាមួយនៃលេខាធិការដ្ឋាន គ.ជ.អ.ប.
- សរសេរជូនក្រុមការងារសម្រុះសម្រួលដោះស្រាយបណ្តឹងលេខាធិការដ្ឋាន គ.ជ.អ.ប.

ក្នុងករណីបណ្តឹងត្រូវបានធ្វើឡើងតាមរយៈបុគ្គលិកណាម្នាក់របស់លេខាធិការដ្ឋាន គ.ជ.អ.ប. បុគ្គលិកនោះ ត្រូវរាយការណ៍ជូនក្រុមការងារសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីតាមដាន។

បណ្តឹងនានាអាចធ្វើឡើងជាលក្ខណៈអណាមិក។ ចំពោះបណ្តឹងដែលធ្វើឡើងដោយមានឈ្មោះ និងព័ត៌មានសម្រាប់ទំនាក់ទំនងច្បាស់លាស់ ក្រុមការងារសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវឆ្លើយតបអំពីការទទួលបានបណ្តឹងឱ្យបានឆាប់ ដើម្បីជានាថាបណ្តឹងត្រូវបានយកចិត្តទុកដាក់ក្នុងការសម្រុះសម្រួលដោះស្រាយ។

# ឧបសម្ព័ន្ធ ៖ ទម្រង់សុវត្ថិភាពបរិស្ថាននិងសង្គម និងយេនឌ័រ

## ទម្រង់ទី៣ ៖ ការពិនិត្យពិច័យហានិភ័យបរិស្ថាន និងសង្គម

| | |
|---|---|
| រាជធានី ខេត្ត ៖ | រដ្ឋបាលឃុំ សង្កាត់ ៖ |
| ក្រុង ស្រុក ខណ្ឌ ៖ | កូដឃុំ សង្កាត់ ៖ |
| ឈ្មោះគម្រោង ៖ | |
| សង្ខេបអំពីគម្រោង ៖ | |

ផ្នែកទី១ ឆ្លើយសំណួរពី១-៥។ ចម្លើយអាចជា បាទ ឬទេ។ ប្រសិនបើចម្លើយ បាទ គម្រោងស្ថិតក្នុងហានិភ័យចំណាត់ថ្នាក់ ក។ ម្ចាស់គម្រោងត្រូវទំនាក់ទំនងស្ថាប័នទទួលខុសត្រូវ ដើម្បីផ្តល់យោបល់ក្នុងការអនុវត្តបន្ត។

| សំណួរ | បាទ/ទេ | ស្ថាប័នទំនាក់ទំនង (ក្នុងករណីចម្លើយ បាទ) |
|---|---|---|
| ១. តើមានផ្នែកណាមួយនៃគម្រោងស្ថិតក្នុងតំបន់អភិរក្ស ឬតំបន់ស្នូលនៃតំបន់ការពារបរិស្ថានឬទេ? | | ក្រសួងបរិស្ថាន |
| ២. តើគម្រោងប៉ះពាល់ដោយផ្ទាល់ដល់កន្លែងការពារវប្បធម៌ (ដូចជាប្រាសាទបុរាណ) ឬទេ? | | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ៣. តើគម្រោងតម្រូវឱ្យមានការផ្លាស់ប្តូរកន្លែងរស់នៅរបស់ប្រជាពលរដ្ឋច្រើនជាង១០គ្រួសារឬទេ? | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលំនៅដ្ឋាន) |
| ៤. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ប្រព័ន្ធធារាសាស្ត្រថ្មី ដើម្បីស្រោចស្រពផ្ទៃដីលើពី១០០ហតដែលមិនធ្លាប់ស្រោចស្រពកន្លងមកឬទេ? | | ក្រសួងធនធានទឹក និងឧតុនិយម |
| ៥. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ទំនប់ស្តុកទឹកដែលមានកម្ពស់លើសពី១៥មឬទេ? | | ក្រសួងធនធានទឹក និងឧតុនិយម |

ផ្នែកទី២ ៖ ឆ្លើយសំណួរទី៦-៣០។ ចម្លើយអាច បាទ ឬទេ។ ក្នុងករណីមានចម្លើយណាមួយ បាទ (ប៉ុន្តែ ចម្លើយពីសំណួរទី១-៥ ទាំងអស់ក្នុងផ្នែកទី១ គឺ ទេ) នោះគម្រោងមានចំណាត់ថ្នាក់ ខ។ ដូច្នេះត្រូវមានការសិក្សាបន្ថែមផ្នែកលើសំណួរ។ ប្រសិនបើ ចម្លើយពីសំណួរទី១-៥ និងសំណួរទាំងអស់ពី៦-៣០ មានចម្លើយ ទេ នោះគម្រោងមានចំណាត់ថ្នាក់ គ និងពុំចាំបាច់មានការសិក្សាបន្ថែមទៀតទេ។

| សំណួរ | បាទ/ទេ | ការសិក្សាបន្តករណីចម្លើយ "បាទ" |
|---|---|---|
| ៦. តើទីតាំងគ្រោងស្ថិតក្នុងបញ្ជីឃ្លាំមើលផ្នែកបរិស្ថានរបស់ គ.ជ.អ.ប. ឬទេ? | | យុទ្ធសាស្ត្រទី៦ |
| ៧. តើគម្រោងនឹងមានផលប៉ះពាល់ទាំងនេះឬទេ ៖<br>➢ ព្រៃធម្មជាតិ<br>➢ ព្រៃលិចទឹកធម្មជាតិ/ ព្រៃកោងកាង | | យុទ្ធសាស្ត្រទី៦ |

| សំណួរ | បាទ/ទេ | ការសិក្សាបន្ត ករណីចម្លើយ "បាទ" |
|---|---|---|
| ➢ តំបន់ដីសើម<br>➢ តំបន់ព្រៃប្រទល់ទឹកសាប-ទឹកប្រៃ | | |
| ៨. តើទីតាំងគ្រោងស្ថិតក្នុងបញ្ជីឃ្លាំមើលផ្នែកជនជាតិដើមភាគតិចឬទេ? | | យុទ្ធសាស្ត្រទី៧ |
| ៩. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់នៅកន្លែងដែលមានចម្ងាយ៥០០មក្នុងកន្លែងការពារវប្បធម៌ឬទេ? | | យុទ្ធសាស្ត្រទី៨ |
| ១០. តើគម្រោងប៉ះពាល់កន្លែងដែលមានសារសំខាន់ផ្នែកវប្បធម៌សម្រាប់ប្រជាពលរដ្ឋដែលរស់នៅទីនោះឬទេ? | | យុទ្ធសាស្ត្រទី៨ |
| ១១. តើគម្រោងត្រូវការលទ្ធកម្មដីធ្លីរួមបញ្ចូលទាំងការបរិច្ចាគដីដោយស្ម័គ្រចិត្តឬទេ? | | យុទ្ធសាស្ត្រទី៥ |
| ១២. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ផ្លូវថ្មីឬទេ? | | យុទ្ធសាស្ត្រទី៤,៥,៦ |
| ១៣. តើគម្រោងពាក់ព័ន្ធនឹងការកែលម្អ និងពង្រីកផ្លូវមានប្រវែងលើសពី១០ គ.មឬទេ? | | យុទ្ធសាស្ត្រទី៤,៥,៦ |
| ១៤. តើគម្រោងពាក់ព័ន្ធនឹងការសង់ប្រព័ន្ធធារាសាស្ត្រថ្មី ដើម្បីស្រោចស្រពផ្ទៃដីតិចជាង១០០ហតដែលមិនធ្លាប់ស្រោចស្រពកន្លងមកឬទេ? | | យុទ្ធសាស្ត្រទី៣,៦ |
| ១៥. តើគម្រោងពាក់ព័ន្ធនឹងជួសជុល ឬកែលម្អប្រព័ន្ធធារាសាស្ត្រ ដើម្បីស្រោចស្រពផ្ទៃដីច្រើនជាង១០០ហតឬទេ? | | យុទ្ធសាស្ត្រទី៣,៦ |
| ១៦. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ ឬជួសជុលអាងស្តុកទឹកដែលមានផ្ទៃទឹកធំជាង១ហត (ទំនប់មានកម្ពស់ទាបជាង១៥ម)ឬទេ? | | យុទ្ធសាស្ត្រទី៣,៤,៦ |
| ១៧. តើគម្រោងតម្រូវឱ្យមានការសាងសង់នៅក្បែរផ្ទះប្រជាពលរដ្ឋ ហាងលក់ដូរ សាលារៀន វត្តអារាម គ្លីនិក ឬកន្លែងមានមនុស្សច្រើន ឬនៅលើផ្លូវមានចរាចរច្រើនឬទេ? | | យុទ្ធសាស្ត្រទី៣,៤ |
| ១៨. តើគម្រោងតម្រូវឱ្យមានការសាងសង់ផ្លូវបង្វែរទឹកណាមួយ (កន្លែងដែលទឹកនឹងហូរនៅពេលសាងសង់ ដូចជាប្រឡាយទឹកកាត់ផ្លូវ)ឬទេ? | | យុទ្ធសាស្ត្រទី៣ |
| ១៩. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់រោងចក្រកែច្នៃផលិតផលកសិកម្មដែលមានសមត្ថភាពផលិតលើសពី១តោនក្នុង១ថ្ងៃឬទេ? | | យុទ្ធសាស្ត្រទី៣ |
| ២០. តើគម្រោងពាក់ព័ន្ធនឹងការសាងសង់ ឬកែលម្អកន្លែងចាក់សំណល់រឹងឬទេ? | | យុទ្ធសាស្ត្រទី៣ |
| ២១. តើគម្រោងនឹងយកចេញលើសពី១០%នៃទឹកក្នុងអូរ ឬប្រឡាយដែលកំពុងមានបច្ចុប្បន្នឬទេ? | | យុទ្ធសាស្ត្រទី៣ |
| ២២. តើគម្រោងនឹងប៉ះពាល់ការផ្គត់ផ្គង់ទឹកដែលប្រើប្រាស់ដោយគ្រួសារឬទេ? | | យុទ្ធសាស្ត្រទី៣ |
| ២៣. តើគម្រោងនឹងនាំឱ្យបំពុលប្រភពទឹកក្នុងរយៈពេលវែងឬទេ? | | យុទ្ធសាស្ត្រទី៣ |
| ២៤. តើគម្រោងនឹងក្លាយជាប្រភពសំណល់រឹងដូចជា ថង់ប្លាស្ទិចក្នុងរយៈពេលវែងឬទេ? | | យុទ្ធសាស្ត្រទី៣ |
| ២៥. តើគម្រោងតម្រូវឱ្យមានការប្រើប្រាស់សារធាតុគីមីដែលមានគ្រោះថ្នាក់ឬទេ? | | យុទ្ធសាស្ត្រទី៣,៤ |

| សំណួរ | បាទ/ទេ | ការសិក្សាបន្តករណីចម្លើយ "បាទ" |
|---|---|---|
| ២៦. តើការអនុវត្តគម្រោងត្រូវការកម្លាំងពលកម្មលើសពី៥០នាក់ ឬកម្លាំងពលកម្មលើសពី ១០នាក់ក្នុងរយៈពេល៣ខែឬទេ? | | យុទ្ធសាស្ត្រទី២ |
| ២៧. តើគម្រោងមានជួលសមាជិកសហគមន៍ ដើម្បីធ្វើការងារមានគ្រោះថ្នាក់ដែលពួកគាត់មិនដែលបានបណ្តុះបណ្តាលឬទេ? | | យុទ្ធសាស្ត្រទី២ |
| ២៨. តើគម្រោងពាក់ព័ន្ធនឹងការដាំដុះដំណាំនៅលើដីដែលមិនធ្លាប់ប្រើប្រាស់សម្រាប់ការដាំដុះពីមុនដែរឬទេ? | | យុទ្ធសាស្ត្រទី៦ |
| ២៩. តើគម្រោងពាក់ព័ន្ធនឹងការរៀបចំដីធ្លីដែលកំពុងប្រើប្រាស់សម្រាប់ដាំដំណាំបច្ចុប្បន្ន ដើម្បីប្រើប្រាស់សម្រាប់គោលបំណងផ្សេងឬទេ? | | យុទ្ធសាស្ត្រទី៦ |
| ៣០. តើគម្រោងស្ថិតនៅក្នុងតំបន់មានហានិភ័យខ្ពស់ដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះឬទេ? | | យុទ្ធសាស្ត្រទី៤ |

## ទម្រង់ពិនិត្យពិច័យយេនឌ័រ

| ផ្នែក | សំណួរ | ចម្លើយ | ពិន្ទុ |
|---|---|---|---|
| **ការកសាងផែនការ** | តើតម្រូវការស្ត្រីត្រូវបានគិតគូរក្នុងការជ្រើសរើសគម្រោងឬទ? | | បាទ = 5 |
| | ក្នុងអំឡុងពេលកសាងផែនការ តើក្រុមស្ត្រីត្រូវបានចូលរួមក្នុងការកំណត់អាទិភាពរបស់ស្ត្រីឬទេ? | | បាទ = 5 |
| | តើគម្រោងមានអាទិភាពខ្ពស់សម្រាប់ស្ត្រីក្នុងសហគមន៍ឬទេ? | | បាទ = 10 |
| **ការរៀបចំ** | តើស្ត្រីដែលទទួលផលប្រយោជន៍ពីគម្រោងត្រូវបានប្រឹក្សាយោបល់ឬទេ (ប្រឹក្សាដោយឡែកពីបុរស) ក្នុងពេលរៀបចំគម្រោង? | | បាទ = 10 |
| | តើគម្រោងបានពិភាក្សាក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារដែរឬទេ? | | បាទ = 5 |
| | តើការរៀបចំគម្រោងមានផ្នែកជាក់លាក់ ដើម្បីលើកកម្ពស់ផលប្រយោជន៍ដល់ស្ត្រីឬទេ? | | បាទ= 10 |
| **ផលប្រយោជន៍** | ចំនួនភាគរយស្ត្រីទទួលផលពីគម្រោង? | | >40% = 5<br>> 60% = 10 |
| | តើទម្រង់ព័ត៌មានគម្រោងរៀបរាប់ពីវិធីសាស្ត្រដែលស្ត្រីនឹងទទួលផលប្រយោជន៍ពីគម្រោងឬទេ? | | បាទ= 5 |
| **ការដឹកនាំ** | ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងជាស្ត្រី? | | បាទ = 10 |
| | សមាជិកគណៈកម្មការគ្រប់គម្រោងជាស្ត្រីមានយ៉ាងហោច៤០%ឬទេ? | | បាទ= 5 |
| **ឱកាស** | តើស្ត្រីទទួលបានឱកាសការងារដោយសមភាពដូចបុរសសម្រាប់ការងារក្នុងគម្រោង និងទទួលប្រាក់បៀវត្សរ៍ស្មើគ្នាដូចបុរសឬទេ? | | បាទ = 5 |
| | តើគម្រោងនឹងបង្កើតឱកាសការងារសម្រាប់ស្ត្រីឬទេ? | | បាទ = 10 |
| | តើគម្រោងនឹងបង្កើតឱកាសការងារសម្រាប់ស្ត្រីក្នុងអាជីវកម្មឬទេ? | | បាទ= 10 |
| | **ពិន្ទុយេនឌ័រ** | | (ខ្ពស់បំផុត= 100) |

## ទម្រង់ ១៩.១ ៖ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម

| | |
|---|---|
| រាជធានី ខេត្ត ៖ | រដ្ឋបាលឃុំ សង្កាត់ ៖ |
| ក្រុង ស្រុក ខណ្ឌ ៖ | កូដឃុំ សង្កាត់ ៖ |
| ឈ្មោះគម្រោង ៖ | |
| សង្ខេបអំពីគម្រោង ៖ | |
| ការបរិច្ឆេទនៃការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម | មន្ត្រីទទួលបន្ទុកការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម |
| ទីតាំងវិភាគ | ចំនួនប្រជាពលរដ្ឋចូលរួម ៖ |

## ការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គមដែលត្រូវការ (ផ្អែកលើទម្រង់ទី៣)

| យុទ្ធសាស្ត្របរិស្ថាន និងសង្គម | បាទ/ ទេ |
|---|---|
| យុទ្ធសាស្ត្រទី២ ៖ ពលកម្ម និងលក្ខខណ្ឌការងារ | |
| យុទ្ធសាស្ត្រទី៣ ៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន | |
| យុទ្ធសាស្ត្រទី៤ ៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍ | |
| យុទ្ធសាស្ត្រទី៦ ៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព | |
| យុទ្ធសាស្ត្រទី៨ ៖ បេតិកភណ្ឌវប្បធម៌ | |

## យុទ្ធសាស្ត្រទី២ ៖ ពលកម្ម និងលក្ខខណ្ឌការងារ

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| អ្នកទទួលការមិនមានយុត្តិធម៌សម្រាប់កម្មករដែលជួលពីសហគមន៍មូលដ្ឋាន | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| អ្នកទទួលការមិនផ្ដល់ឱកាសស្មើគ្នា និងប្រាក់ខែស្មើគ្នាចំពោះការងារដូចគ្នា ដល់ស្ត្រី ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិច | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| អ្នកទទួលការមិនផ្ដល់នូវលក្ខខណ្ឌការងារដែលមានសុខភាព និងសុវត្ថិភាព ដល់កម្មករ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| អ្នកទទួលការយកកម្មករច្រើននាក់មកពីខាងក្រៅ។ កម្មករទាំងនោះមិនមានកន្លែងរស់នៅសមស្រប និងមានអនាម័យដែលនាំឱ្យមានការបំពុលបរិស្ថាន | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| អ្នកទទួលការយកកម្មករច្រើននាក់មកពីខាងក្រៅ និងនាំឱ្យមានបញ្ហាជាមួយសហគមន៍មូលដ្ឋាន។ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## យុទ្ធសាស្ត្រទី៣ ៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន

## ផលប៉ះពាល់រយៈពេលវែងដោយសារគម្រោង

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| ផលប៉ះពាល់ខ្លាំងក្លាមកលើអ្នកប្រើប្រាស់ទឹកដោយសារទាញយកទឹកច្រើនហួសកម្រិតកំណត់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ផលប៉ះពាល់ខ្លាំងក្លាលើធនធានធម្មជាតិដោយសារទាញយកធនធានមកប្រើប្រាស់ច្រើនហួសកម្រិតកំណត់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនឹងបំផ្លាញចរន្តទឹក | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| សំណឹក ឬបាត់បង់ដីជាតិដីសម្រាប់កសិកម្ម | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| សំណឹកជំរេលភ្នំ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ធុំក្លិនអាក្រក់ ឬបំពុលខ្យល់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| សំណល់មិនមែនជីវៈ (ដូចជា ថង់ប្លាស្ទិច) | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ការបំពុលផ្ទៃទឹក (អូរ បឹង...) ដោយសារទឹកហូរចេញពីកន្លែងសាងសង់គម្រោង | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បំពុលទឹកក្រោមដីដោយសារទឹកសើមចេញពីកន្លែងសាងសង់ចូលទៅក្នុងដី | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បង្កើនបរិមាណទឹកកខ្វក់ដោយសារគម្រោង | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## យុទ្ធសាស្ត្រទី៣ ៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន

## ផលប៉ះពាល់រយៈពេលខ្លីដោយសារគម្រោង

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| ការបំពុលទឹកក្នុងអំឡុងពេលសាងសង់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងបង្កឱ្យមានធូលីហុយក្នុងបរិយាកាសក្នុងអំឡុងពេលសាងសង់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងបង្កឱ្យមានសម្លេងខ្លាំងក្នុងអំឡុងពេលសាងសង់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យមានសំណល់រឹងដែលកើតចេញពីការសាសង់ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ចរាចរក្នុងអំឡុងពេលសាងសង់នាំឱ្យបំផ្លាញផ្លូវដែលប្រើប្រាស់សម្រាប់ចូលទៅកន្លែងសាងសង់គម្រោង | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ការសាងសង់នាំឱ្យបំផ្លាញដីសម្រាប់កសិកម្ម និងដីសម្រាប់ដំណាំក្នុងរយៈពេលខ្លី | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បំពុលផ្ទៃទឹកដោយសារមានទឹកហូរចេញពីកន្លែងសាងសង់គម្រោង | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ធុំក្លិនអាក្រក់ ឬការបំពុលខ្យល់បង្កឡើងដោយគម្រោង | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| សំណល់មិនមែនជីវៈ (ដូចជា ថង់ប្លាស្ទិច) | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| បរិមាណទឹកកខ្វក់មានការកើនឡើងដោយសារគម្រោង | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## យុទ្ធសាស្ត្រទី៤ ៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| ការសាងសង់នឹងប៉ះពាល់គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះនាំឱ្យមានគ្រោះថ្នាក់ដល់កម្មករ និងសហគមន៍ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ហានិភ័យនៃការសាងសង់នាំឱ្យមានគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ផ្លូវបានជួសជុលល្អនាំឱ្យការបើកបរក្នុងល្បឿនលឿនជាមុន និងនាំឱ្យមានគ្រោះថ្នាក់ច្រើនជាងមុន | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ទំនប់បានសាងសង់ដោយគម្រោងអាចបាក់ និងនាំឱ្យមានគ្រោះថ្នាក់ដល់សហគមន៍មូលដ្ឋាន | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| កសិករបង្កើនការប្រើប្រាស់ថ្នាំគីមីកសិកម្មដែលនាំឱ្យមានផលប៉ះពាល់មិនល្អដល់សុខភាព | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## យុទ្ធសាស្ត្រទី៦ ៖ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| គម្រោងប៉ះពាល់ដោយផ្ទាល់ដល់សត្វព្រៃ និងបំផ្លាញលំនៅសត្វព្រៃ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យបង្កើនសកម្មភាពរបស់ប្រជាពលរដ្ឋ ដែលនាំឱ្យប៉ះពាល់ដល់សត្វព្រៃ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងប៉ះពាល់ដោយផ្ទាល់ដល់ធនធាននេសាទ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យបង្កើនសកម្មភាពរបស់ប្រជាពលរដ្ឋ ដែលនាំឱ្យប៉ះពាលើដល់ធនធាននេសាទ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងប៉ះពាល់ដោយផ្ទាល់ដល់ព្រៃធម្មជាតិ និងព្រៃលិចទឹក | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| គម្រោងនាំឱ្យបង្កើនសកម្មភាពរបស់ប្រជាពលរដ្ឋ ដែលនាំឱ្យប៉ះពាល់ដល់ព្រៃធម្មជាតិ និងព្រៃលិចទឹក | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យមានការបង្ហូរទឹកចេញពីតំបន់ដីសើម | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យប្រជាពលរដ្ឋកែប្រែដីព្រៃ ព្រៃលិចទឹក និងតំបន់ដីសើមទៅជាដីកសិកម្ម | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនាំឱ្យមានការផ្លាស់ប្តូរវិធីសាស្ត្រកសិកម្មដែលនាំឱ្យបំផ្លាញត្រី កង្កែប និងសត្វ រុក្ខជាតិមានប្រយោជន៍ដទៃទៀតរស់នៅក្នុងដីកសិកម្ម | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## យុទ្ធសាស្ត្រទី៨ ៖ បេតិកភណ្ឌវប្បធម៌

| បញ្ហា | កម្រិត | | ទីតាំងនៅលើផែនទី |
|---|---|---|---|
| ការសាងសង់នាំឱ្យខូចខាតដោយផ្ទាល់ដល់កន្លែងបេតិកភណ្ឌវប្បធម៌ | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| ផ្អែកលើចំណេះដឹងប្រជាពលរដ្ឋ និងបទពិសោធន៍ពីមុននៃតំបន់នេះ ការងារសាងសង់អាចរកឃើញវត្ថុបេតិកភណ្ឌវប្បធម៌ដែលកប់ក្នុងដី | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនឹងប៉ះពាល់ជាអវិជ្ជមានដល់តំបន់បេតិកភណ្ឌវប្បធម៌ (ដូចជា សម្លេង ឬ ការបំពុល ឬការផ្លាស់ប្តូរភាពស្រស់ស្អាតនៃតំបន់) | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |
| គម្រោងនឹងប៉ះពាល់ជាអវិជ្ជមានដល់វប្បធម៌របស់ប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍មូលដ្ឋាន | ផលប៉ះពាល់ខ្លាំង | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិច ឬគ្មាន | | |

## អនុសាសន៍នៃការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម

| ល.រ | បរិយាយ | ជ្រើសរើសចម្លើយចំនួន១ |
|---|---|---|
| ១. | គម្រោងនឹងមានផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន និងសង្គមដែលមិនអាចទទួលយកបាន | |
| ២. | គម្រោងនឹងមានផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន និងសង្គមជាមធ្យម។ ការអនុវត្ត និងការត្រួតពិនិត្យផែនការ ESMP កាត់បន្ថយផលប៉ះពាល់នៅក្នុងកម្រិតមួយដែលអាចទទួលយកបាន។ | |
| ៣. | គម្រោងនឹងមិនមានផលប៉ះពាល់ជាអវិជ្ជមានផ្នែកបរិស្ថាន និងសង្គមគួរឱ្យកត់សម្គាល់នោះទេ | |

**ឧបសម្ព័ន្ធដែលត្រូវភ្ជាប់ ៖**

- ទម្រង់ទី៣ ៖ ការពិនិត្យពិច័យបរិស្ថាន និងសង្គម
- ផែនទីបរិស្ថាន និងសង្គម ផែនការ ESMP
- បញ្ជីអ្នកចូលរួមការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម
- កំណត់ហេតុកិច្ចប្រជុំការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គម

ថ្ងៃ............ខែ...........ឆ្នាំ..........ព.ស.២៥៦... ថ្ងៃ..........ខែ...........ឆ្នាំ...........ព.ស.២៥៦..

ថ្ងៃទី............ខែ...............ឆ្នាំ................. ថ្ងៃទី............ខែ..............ឆ្នាំ.................

មេឃុំ ចៅ សង្កាត់ មន្ត្រីទទួលបន្ទុក

ឧទាហរណ៍ ៖ ទម្រង់ ១៩.២ ៖ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម

| | | | | | |
|---|---|---|---|---|---|
| រាជធានី ខេត្ត | | ក្រុង ស្រុក ខណ្ឌ ៖ | | ឃុំ សង្កាត់ ៖ | លេខឃុំ សង្កាត់ ៖ |
| ឈ្មោះគម្រោង ៖ | | | | | |
| ចម្លងពីទម្រង់ ១៩.១ | | វិធានការគ្រប់គ្រង | ពេលវេលា | ការទទួលខុសត្រូវ | ទំហំផលប៉ះពាល់បន្ទាប់ពីបន្ធូរបន្ថយ |
| ប្រភេទផលប៉ះពាល់អវិជ្ជមាន | ទំហំផលប៉ះពាល់ | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ថ្ងៃ...............ខែ............ឆ្នាំ..........ព.ស.២៥៦...
ថ្ងៃទី............ខែ..............ឆ្នាំ................

មេឃុំ ចៅសង្កាត់

ថ្ងៃ...............ខែ............ឆ្នាំ..........ព.ស.២៥៦...
ថ្ងៃទី............ខែ..............ឆ្នាំ................

មន្ត្រីបច្ចេកទេស

គោលនយោបាយ
Policy

ការគ្រប់គ្រងការបំពុលបរិស្ថាន
Pollution Management

ការសម្រុះសម្រួលដោះស្រាយបណ្តឹង
Complaint Handling

សុវត្ថិភាពបរិស្ថាន និងសង្គម
Environmental and Social Safeguard

ការរៀបចំផែនការ
Planing

ជនជាតិដើមភាគតិច
Indigenous People

សមភាពយេនឌ័រ
Gender

រដ្ឋបាលថ្នាក់ក្រោមជាតិ
Sub-National Administration

ចីរភាព
Sustainable

លទ្ធកម្មដីធ្លី និងតាំងទីលំនៅ
Land Acquisition and Resettlement

ពលកម្ម និងលក្ខខណ្ឌការងារ
Labour and Working Conditions

បរិយាប័ន្ន
inclusiveness

ការប្រែប្រួលអាកាសធាតុ
Climate Change

រៀបចំ និងបោះពុម្ពដោយ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.
www.ncdd.gov.kh

គជអប
NCDD

គាំទ្រដោយ៖

UNCDF
Unlocking Public and Private Finance for the Poor

LoCAL
LOCAL CLIMATE ADAPTIVE LIVING FACILITY